00850992



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 08-Oct-2012, 10:21
CMS/CFO: Krystal THOMPSON

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>
# <u>ជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង</u>

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី១១៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក ដារ អានសាន

លោក ម៉ាតេអូ គ្រីប៉ា
*(Mr. Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ាត់

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី
*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ
*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស
*(Mr. Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡោ ជុនធី

លោក វ៉េន ពៅ

លោកស្រី ម៉ាទីន ហ្សាកកាំង
*(Ms. Martine JACQUIN)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ
*(Ms.Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្ល សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក វ៉េង ហ៊ត់ | ខ្មែរ |
| លោក អេនឌ្រូ អ៊ីនូហ្សី | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក សេង រិទ្ធី (មេធាវីប្រឹក្សាសាក្សី) | ខ្មែរ |
| លោក មាស វឿន (TCW-428) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក មាស ធឿន** (TCW-428)

សួរដោយលោកប្រធានអង្គជំនុំ ផ្តើមពី៖ .......... ទំព័រ ៦២

សួរដោយលោក វ៉េង ហ៊ាត់ ផ្តើមពី៖ .......... ទំព័រ ៦៧

សួរដោយលោក ថារីក អាប់ឌុលឡាក់ ផ្តើមពី៖ .......... ទំព័រ ៨២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:១៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ដូចបានជម្រាបជូនកាលពីម្សិលមិញរួចហើយថា អង្គជំនុំជម្រះនៅថ្ងៃនេះ នឹងបន្តចាត់តាំងក្រឡាបញ្ជីសវនាការអាននូវបណ្តាកថាខណ្ឌ ដែលនៅសេសសល់នៅក្នុងសំណុំរឿង០០២/០១ ដែលអង្គជំនុំជម្រះកំណត់ថា ជាកិច្ចដំណើរការសវនាការវគ្គបី នៃសំណុំរឿង០០២/០១។

ហើយមុននឹងផ្តល់វេទិកាជូនទៅលោកស្រី សែ កុលវុឌ្ឍី ដើម្បីបន្តការអាននូវបណ្តាកថាខណ្ឌដែលបានផ្តល់ភារៈជូនកាលពីម្សិលមិញ សូមលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

[០៩:០៣:២៧]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ លើកលែងតែជនជាប់ចោទ អៀង សារី អវត្តមានដោយមូលហេតុសុខភាព។ ប៉ុន្តែជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងដំណើរការសវនាការ នៃការស្តាប់សក្ខីកម្មសាក្សី TCW-428។ ចំណែកឯសាក្សី TCW-428 រូបនេះនឹងត្រូវមកផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះ នៅក្នុងថ្ងៃនេះ។ ហើយសាក្សីរូបនេះ នឹងមានវត្តមាននៅម៉ោងដប់សាមសិបនាទីព្រឹក។ សាក្សីរូបនេះនឹងធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ហើយជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅលោកស្រី សែ កុលវុឌ្ឍី បន្តការអាននូវកថាខណ្ឌដែលនៅសេសសល់ ដែលយើងខ្ញុំបានចាត់តាំងលោកស្រី ឲ្យអាននូវបណ្តាកថាខណ្ឌនៅក្នុង

ដីកាដំណោះស្រាយ នៃ នៅក្នុងសំណុំរឿង០០២/០១ កាលពីម្សិលមិញ។ ហើយមុននឹងផ្តល់វេទិកាគឺយើងកែតម្រូវលើកថាខណ្ឌ ដែលផ្តល់ជូនកាលពីម្សិលមិញឡើងវិញ។

ទី១ គឺកថាខណ្ឌចាប់ពី ១១៣ ដល់ ១៤៩។ ទី២ គឺកថាខណ្ឌពី ១៥៦ ដល់ ១៦៥ និងកថាខណ្ឌ ២២១ ដល់ ២២៧។ សូមអញ្ជើញ!

[០៩:០៥:០៦]

**ក្រឡាបញ្ជី៖**

<u>កងទ័ពរបស់ភូមិភាគ</u>

កថាខណ្ឌ១៣៣៖ នៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា សាខាធំទីពីរគឺកងទ័ពរបស់ភូមិភាគ ដែលជាទូទៅត្រូវបានរៀបចំជាកងពល។ ទោះបីជាកងពលទាំងនោះត្រូវរាយការណ៍ជាចុងក្រោយទៅមជ្ឈិមក៏ដោយ ក៏កងពលទាំងនេះគឺជាផ្នែកមួយនៃរចនាសម្ព័ន្ធរដ្ឋបាលភូមិភាគដែរ។ ភារកិច្ចរបស់កងពលទាំងនេះមានការទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងសកម្មភាពរបស់ភូមិភាគដែលខ្លួនឈរជើង និងរួមមានជាអាទិ៍ការការពារទឹកដី និងសន្តិសុខផ្ទៃក្នុង។ កងទ័ពរបស់ភូមិភាគនៅតាមព្រំដែនថៃ និងវៀតណាម មានការជាប់ពាក់ព័ន្ធខ្លាំងនៅក្នុងប្រយុទ្ធនានា ដែលបានកើតឡើងនៅតាមបណ្តោយព្រំដែនទាំងនេះ។ នៅថ្នាក់ក្រោមកងពល ស្រុកនានាក៏មានកងកម្លាំងមូលដ្ឋានរបស់ខ្លួនដែរ ដែលចំណុះឲ្យថ្នាក់កងវរសេនាតូច។

<u>កងឈ្លប</u>

កថាខណ្ឌ១៣៤៖ កងកម្លាំងទី៣ គឺយោធានៅតាមមូលដ្ឋានដែលត្រូវបានគេនិយាយសំដៅថាកងឈ្លប។

កថាខណ្ឌ១៣៥៖ កងឈ្លបបានរស់នៅក្នុងចំណោមប្រជាពលរដ្ឋនៅតាមភូមិភាគ -- ភូមិនានាដោយបំពេញភារកិច្ចទាក់ទងទៅនឹងសន្តិសុខនៅតាមមូលដ្ឋាន។ ក្នុងចំណោមភារកិច្ចទាំងនេះ រួមមានការចាប់ខ្លួន ការសម្លាប់ ព្រមទាំងភារកិច្ចដែលទាក់ទងទៅនឹងការងារយោធាបន្ថែមទៀតផងដែរ ដូចជាការងារត្រៀមការពារភូមិ និងសហករណ៍។ កងឈ្លបរាយការណ៍ផ្ទាល់ទៅ ភូមិ គណៈឃុំ និងគណៈស្រុក។ ហើយត្រូវបានគេហៅឲ្យបំពេញការងារសន្តិសុខរដ្ឋបាលស៊ីវិល។

ឃ) ទំនាក់ទំនង/ការរាយការណ៍

កថាខណ្ឌ១៣៦៖ កងទ័ពបដិវត្តន៍កម្ពុជាមានរចនាសម្ព័ន្ធបញ្ជាតាមឋានានុក្រម ដែលត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញតាមរយៈរចនាសម្ព័ន្ធទំនាក់ទំនងការងាររបស់ខ្លួន។ ការរាយការណ៍ត្រូវបានប្រមូល

នៅក្នុងកងពល ហើយបន្ទាប់មកត្រូវបានបញ្ជូនទៅអង្គការបញ្ជាការថ្នាក់មជ្ឈិម គឺសេនាធិការ។ បញ្ជាត្រូវបានចេញតាមរយៈបណ្ដាញទំនាក់ទំនងបញ្ច្រាសមកវិញ។ បញ្ជាការថ្នាក់មជ្ឈិមបញ្ជូនបញ្ជារបស់ខ្លួន ទៅកាន់កងពលនានា ដែលបញ្ជាទាំងនោះត្រូវបានបញ្ជូនបន្តទៀត ទៅកាន់មេបញ្ជាការថ្នាក់ទាបជាង ដែលជាអ្នកអនុវត្តនូវបញ្ជាទាំងនោះ។

[០៩:០៧:៤១]

<u>ទំនាក់ទំនងរវាងកងពល និងមជ្ឈិម</u>

កថាខណ្ឌ១៣៧៖ ទំនាក់ទំនងការងាររវាងកងពល និងមជ្ឈិមត្រូវបានធ្វើជាប្រចាំ ដោយមានទំនាក់ទំនងច្រើនដងក្នុងមួយថ្ងៃ។ បញ្ជាការថ្នាក់មជ្ឈិមបានធ្វើទំនាក់ទំនងការងារជាទៀងទាត់ជាមួយនឹងកងពលនានា។ ហើយផ្អែកទៅលើកងពលទាំងនេះ ដើម្បីបញ្ជូនបន្តនូវបញ្ជារបស់ខ្លួនទៅកាន់អង្គភាពនានា ដែលមានថ្នាក់ទាបជាង។ សេចក្ដីសម្រេចសំខាន់នានារបស់ថ្នាក់កងពលត្រូវបានទុកឱ្យអង្គភាពបញ្ជាការមជ្ឈិមធ្វើការសម្រេច។ កងពលនានាធ្វើសេចក្ដីរាយការណ៍ទៅអង្គភាពបញ្ជាការមជ្ឈិមជាទៀងទាត់។

ជាទូទៅសេចក្ដីរាយការណ៍ទាំងនេះ ស្ដីអំពីការប្រយុទ្ធគ្នាពីការរកឃើញខ្មាំងផ្ទៃក្នុងរួមជាមួយនឹងបញ្ហាផ្សេងៗទៀតផង។

[០៩:០៨:៣៨]

កថាខណ្ឌ១៣៨៖ ទំនាក់ទំនងការងារត្រូវបានសម្របសម្រួលតាមមធ្យោបាយផ្សេងៗជាច្រើន។ បណ្ដាញទំនាក់ទំនងដែលប្រើប្រាស់ជាញឹកញាប់គឺ តាមរយៈវិទ្យុទាក់ទង និងតាមទូរលេខ។ ដើម្បីសម្រេចគោលបំណងនេះ សេនាធិការ ក៏ដូចជាកងពលនីមួយៗ មានអង្គភាពវិទ្យុទាក់ទង និងអង្គភាពទូរលេខ។ សារនានាត្រូវបានផ្ញើ និងទទួលដោយកងទ័ពបដិវត្តន៍កម្ពុជាជាលេខសម្ងាត់។

កថាខណ្ឌ១៣៩៖ នីរសារត្រូវបានប្រើប្រាស់ជាញឹកញាប់ផងដែរ ដើម្បីបញ្ជូនសារ។ កងពលនីមួយៗមានអង្គភាពនីរសារដើម្បីផ្ដល់នូវសេវាកម្មទាំងនេះ។

កថាខណ្ឌ១៤០៖ សាររវាងសេនាធិការ ឬគណៈកម្មាធិការយោធា និងសាររវាងកងពលផ្សេងៗត្រូវបានបញ្ជូនជាញឹកញាប់ទៅឱ្យសមាជិកនៃគណៈមជ្ឈិម។

[០៩:០៩:៣៤]

កថាខណ្ឌ១៤១៖ មធ្យោបាយផ្សេងទៀត ដែលត្រូវបានប្រើប្រាស់ជាញឹកញាប់ ដើម្បីទំនាក់ទំនង

ការងាររវាងអង្គភាពបញ្ជាការថ្នាក់មជ្ឈិម និងកងពលនានា គឺតាមរយៈកិច្ចប្រជុំផ្ទាល់។ ការប្រជុំទាំងនេះអាចមានការប្រជុំទ្រង់ទ្រាយតូច ឬអាចជាការប្រជុំទ្រង់ទ្រាយធំ។

ឧទាហរណ៍៖ ការប្រជុំធំសំខាន់ៗមានដូចជា ការប្រជុំដែលធ្វើឡើងនៅមុនពេលវាយប្រហារផ្តាច់ព្រ័ត្រយកភ្នំពេញ ឬមុនពេលបោសសម្អាតភូមិភាគបូព៌ា។ នៅក្នុងការប្រមូលផ្តុំប្រជុំទ្រង់ទ្រាយធំជាញឹកញាប់មានការធ្វើសុន្ទរកថាដោយមេដឹកនាំបក្ស។ សាក្សីខ្លះបានរាយការណ៍ថា មានការប្រជុំធំផ្នែកយោធាដែលធ្វើឡើងពហុកីឡាដ្ឋានជាតិអូឡាំពិកនៅភ្នំពេញ សម្រាប់មេបញ្ជាការអង្គភាពនានាពីថ្នាក់វរសេនាតូចឡើងទៅ ដែលដឹកនាំប្រជុំដោយ សុន សេន។

<u>ទំនាក់ទំនងនៅក្នុងកងពល</u>

កថាខណ្ឌ១៤២៖ នៅក្នុងកងពលនានា ទំនាក់ទំនងការងារធ្វើតាមរចនាសម្ព័ន្ធបញ្ជា ដោយមានមេបញ្ជាការដែលជាធម្មតាធ្វើការទំនាក់ទំនងជាមួយថ្នាក់លើ និងថ្នាក់ក្រោមបង្គាប់របស់ពួកគេផ្ទាល់។ ទំនាក់ទំនងការងារប្រចាំថ្ងៃ ជារឿយៗត្រូវបានធ្វើឡើងតាមវិទ្យុទាក់ទងចល័ត ប៉ុន្តែមធ្យោបាយនីរសារទូរលេខ និងការប្រជុំនានាត្រូវបានគេប្រើប្រាស់ផងដែរ។

[០៩:១១:១០]

ច) វិន័យ

កថាខណ្ឌ១៤៣៖ កងទ័ពបដិវត្តន៍កម្ពុជាបានដាក់របបវិន័យដ៏តឹងរ៉ឹងទៅលើមេបញ្ជាការ និងកងទ័ពរបស់ខ្លួន ដែលរបបវិន័យបានចែងពីមធ្យោបាយនានានៃការតាមដានត្រួតពិនិត្យ និងការដាក់ទណ្ឌកម្ម។

កថាខណ្ឌ១៤៤៖ ការប្រជុំទិតៀន និងស្វ័យទិតៀន ត្រូវបានធ្វើឡើងនៅក្នុងអង្គភាពយោធាដែលកងទ័ពត្រូវបានគេរំពឹងឲ្យធ្វើការទិតៀនពីកំហុសរបស់ពួកគេ និងទិតៀនពីកម្មាភិបាលរបស់ពួកគេ។

បច្ចេកទេសនៃការត្រួតពិនិត្យ និងការដាក់ពិន័យនេះត្រូវបានប្រើប្រាស់ផងដែរនៅក្នុងការប្រជុំដែលត្រូវបានរៀបចំដោយសេនាធិការ។

កថាខណ្ឌ១៤៥៖ មានទម្រង់ផ្សេងៗនៃទណ្ឌកម្ម ដើម្បីដាក់វិន័យទៅលើកងទ័ព។ នៅពេលណាដែលមានការប្រព្រឹត្តខុស។ មានការដាក់ទណ្ឌកម្មនៅក្នុងអង្គភាពនានា ដែលរួមមាន៖ ការបញ្ជូនទៅអប់រំកែប្រែ ឬទៅការដ្ឋានការងារ ឬត្រូវបានគេសម្លាប់។ មេបញ្ជាការដែលមិនគោរពបញ្ជា ឬត្រូវបានគេចាត់ទុកថា “ក្បត់” ត្រូវបានចាប់ខ្លួន និងក្រោយមកត្រូវបានគេសម្លាប់។

[០៩:១២:២៧]

ចំពោះការចាប់ខ្លួន និងការសួរចម្លើយជនក្បត់ ដែលគេសន្មត៖ អង្គភាពនានារបស់កងទ័ពបដិវត្តន៍កម្ពុជាបានប្រើប្រាស់នូវទីតាំងរបស់មន្ទីរផ្សេងៗដូចជារបស់មន្ទីរ ស-២១ ឬមន្ទីរសន្តិសុខផ្ទាល់ខ្លួនរបស់អង្គភាពនោះ។

ឆ) ការចូលរួមរបស់កងទ័ពបដិវត្តន៍កម្ពុជានៅក្នុងការបោសសម្អាត

កថាខណ្ឌ១៤៦៖ ក្នុងឋានៈជាអ្នកទទួលខុសត្រូវលើសន្តិសុខផ្ទៃក្នុងកងទ័ព កងទ័ពបដិវត្តន៍កម្ពុជាបានអនុវត្តការបោសសម្អាតតាមបញ្ជារបស់មជ្ឈិមបក្ស។

កថាខណ្ឌ១៤៧៖ នៅក្នុងការប្រជុំជាផ្លូវការរបស់កងទ័ពបដិវត្តន៍កម្ពុជានាខែកក្កដា ឆ្នាំ១៩៧៥ ប្រធាននៃគណៈកម្មាធិការយោធាជាន់ខ្ពស់របស់បក្សបានប្រកាសថា "កងទ័ពបដិវត្តន៍ត្រូវការពារប្រទេសប្រឆាំងនឹងខ្មាំងស៊ីរូងផ្ទៃក្នុង និងថាកាតព្វកិច្ចកងទ័ពបដិវត្តន៍គឺបន្តការកម្ទេច"។ នៅក្នុងពេលប្រជុំលេខា និងអនុលេខាកងពល និងវរសេនាធំឯករាជ្យ វិធានការនានាត្រូវបានលើកយកមកពិភាក្សាផងដែរ រួមទាំងការបោសសម្អាតសមាសភាពមិនល្អ។

កថាខណ្ឌ១៤៨៖ ឌុច បានពន្យល់ថា នៅក្នុងរយៈពេលក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភ្លាមក្នុងពេលដែលមិនទាន់មានអង្គភាពសន្តិសុខមជ្ឈិមណាមួយនោះ បទបញ្ជាទាក់ទងការសម្លាប់អ្នករដ្ឋការរបស់អតីតរបបសាធារណរដ្ឋខ្មែរនិងអ្នកផ្សេងទៀត ដែលត្រូវបានគេចាត់ទុកថាជា"សត្រូវ" ត្រូវបានសម្លាប់ដោយកម្មាភិបាលយោធាចំណុះឲ្យលេខាភូមិភាគ ដែលជាអ្នកទទួលបញ្ជាពីគណៈកម្មាធិការអចិន្ត្រៃយ៍។ អង្គភាពយោធាភូមិភាគដែលចូលភ្នំពេញព្រមទាំងអង្គភាពភូមិភាគ និងអង្គភាពក្រោមចំណុះដែលចូលដល់ទីក្រុងផ្សេងៗដូចជា៖ ខេត្តពោធិ៍សាត់ នៅក្នុងភូមិភាគពាយ័ព្យបានអនុវត្តការសម្លាប់មនុស្សតែម្តង។ កងកម្លាំងយោធាថ្នាក់ភូមិភាគ ថ្នាក់តំបន់ និងស្រុកបានបន្តចូលរួមក្នុងការសម្លាប់មនុស្សនានានៅតាមតំបន់ និងក្នុងផ្នែកមួយចំនួននៃប្រទេសក្នុងអំឡុងពេញមួយរបបនោះ។

[០៩:១៤:៥៥]

ឧទាហរណ៍៖ ករណីនៅភូមិភាគបស្ចិម តំបន់៣៧ និងនៅមន្ទីរសន្តិសុខកោះខ្សងក្នុងស្រុកព្រៃនប់នៅមន្ទីរសន្តិសុខភ្នំក្រោល ក្នុងស្រុកកោះញែក តំបន់ស្វយ័ត១០៥ និងនៅមន្ទីរសន្តិសុខព្រៃដំរីស្រុតក្នុងស្រុកកំពង់ត្រឡាចលើ តំបន់៣១ នៃភូមិភាគបស្ចិម។

កថាខណ្ឌ១៤៩៖ យោងតាមសាក្សីថា សេចក្តីសម្រេចឲ្យអនុវត្តការបោសសម្អាតនៅក្នុងជួរ

យោធាត្រូវបានធ្វើឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍ ដោយមាន សុន សេន ជាអ្នកធ្វើតាមបញ្ជានានារបស់ ប៉ុល ពត នួន ជា និងតាម៉ុក។ សាក្សីរូបនោះ ក៏បាននិយាយផងដែរ អំពីអត្ថិភាពនៃការបោសសម្អាត់ ការប្រជុំរៀបចំផែនការរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ដែលមាន ប៉ុល ពត, នួន ជា និង អៀង សារី។ សាក្សីដដែលនេះ រៀបរាប់ថា ការបញ្ជាឲ្យបោសសម្អាតត្រូវបានទទួលនៅក្នុងការប្រជុំនៃមេបញ្ជាការយោធានានា ដែលកោះប្រជុំដោយ ប៉ុល ពត, នួន ជា, តាម៉ុក និងសុន សេន។

[០៩:១៦:០៤]

ផ្នែកទី៧៖ ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម

កថាខណ្ឌ១៥៦៖ មេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាដែលមាន -- មានផែនការរួម ដើម្បីបង្កើតនៅក្នុងប្រទេសកម្ពុជា នូវបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សតាមរយៈគ្រប់មធ្យោបាយចាំបាច់តាមសន្ទុះមហាលោតផ្លោះ និងដើម្បីការពារបក្សប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ។

កថាខណ្ឌ១៥៧៖ ដើម្បីធ្វើឲ្យសម្រេចនូវផែនការរួម មេដឹកនាំរបស់កុម្មុយនីស្តកម្ពុជាបានឲ្យអត្ថន័យ និងបានអនុវត្តនូវគោលនយោបាយទាំងប្រាំ ដូចជា ការផ្លាស់ទីលំនៅ ដែលធ្វើឡើងជាច្រើនលើកច្រើនសា ទៅលើប្រជាជន ចេញពីទីប្រជុំជនទៅកាន់ទីជនបទ និងពីទីជនបទមួយ ទៅកាន់ទីជនបទមួយផ្សេងទៀត។

<u>ការបង្កើត និងការទាញយកផលប្រយោជន៍តាមរយៈសហករណ៍ និងតាមការដ្ឋាន</u>

ការអប់រំសមាសភាពមិនល្អ និងការកម្ទេចខ្មាំង ដែលត្រូវបានរកឃើញទាំងនៅក្នុង និងនៅក្រៅបក្ស។ ការចេញនូវវិធានការជាពិសេស ចំពោះក្រុមមនុស្សជាក់លាក់នានា ដូចជា ជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិកជន និងអតីតរដ្ឋការនានា នៃសាធារណរដ្ឋខ្មែរ រួមទាំងមន្ត្រីរាជការ អតីតបុគ្គលិកយោធា ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ។

<u>ការដាក់បទបញ្ញាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍</u>

កថាខណ្ឌ១៥៨៖ ផែនការរួមកើតមានតាំងតែពីមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបានបន្តយ៉ាងហោចណាស់ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ គោលនយោបាយទាំងប្រាំ ដែលត្រូវបានបង្កើតដើម្បីឲ្យសម្រេចផែនការរួមនេះ ត្រូវបានអនុវត្តន៍ក្នុងរវាង ឬមុនកាលបរិច្ឆេទទាំងនេះ។

[០៩:១៨:១១]

គោលនយោបាយទាំងនេះ បានប្រែប្រួលនៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យដែលមាន

លក្ខណៈកាន់តែធំ និងតឹងរ៉ឹង។ ផលវិបាកមួយ ក្នុងចំណោមផលវិបាកនានានៃគោលនយោបាយទាំងនេះ គឺការធ្វើសមូហភាវូបនីយកម្មសង្គមលើគ្រប់វិស័យទាំងអស់។ សមូហភាវូបនីយកម្មសង្គមនេះរួមមាន ការលុបបំបាត់ផ្សារ រូបិយវត្ថុ និងការកម្មសិទ្ធិឯកជន ការហាមឃាត់ការធ្វើដំណើរទៅមកដោយសេរីរបស់មនុស្ស និងជាចុងក្រោយ គឺការប្រមូលផ្តុំមនុស្សជាអង្គភាពដោយឡែកៗពីគ្នា ដោយធ្វើការបែងចែកជាប្រភេទ ដែលក្នុងមនុស្សត្រូវរស់នៅរួមគ្នាជាលក្ខណៈទូទៅ។

ការណ៍នេះ បានបង្កើតនូវប្រព័ន្ធមួយ ដែលក្រោយមក ប្រជាជនកម្ពុជាបានកំណត់ជាទូទៅថាប្រទេសទាំងមូលបានក្លាយទៅជាគុកឥតជញ្ជាំង។

កថាខណ្ឌ១៥៩៖ បុគ្គលដែលបានចូលរួមក្នុងផែនការរួមនេះ យ៉ាងហោចណាស់មានសមាជិកនៃគណៈកម្មការអចិន្ត្រៃយ៍ ដូចជា នួន ជា និង អៀង សារី អ្នកដែលស្ថិតនៅក្នុងគណៈកម្មាធិការមជ្ឈិម ដូចជា ខៀវ សំផន រដ្ឋមន្ត្រីនានា ដូចជា អៀង ធីរិទ្ធ លេខាភូមិភាគ និងតំបន់ស្វយ័ត និងមេដឹកនាំកងពលយោធាមជ្ឈិម។

[០៩:១៩:៣២]

ក) ការផ្លាស់ទីលំនៅរបស់ប្រជាជន

កថាខណ្ឌ១៦០៖ គោលនយោបាយមួយ ក្នុងចំណោមគោលនយោបាយទាំងប្រាំ ដែលត្រូវបានអនុវត្តដើម្បីសម្រេចបាន និងការពារបដិវត្តន៍សង្គមនិយម និងការផ្លាស់ទីលំនៅរបស់ប្រជាជន ពីទីប្រជុំជន ទៅកាន់តំបន់ជនបទ និងពីទីជនបទមួយ ទៅកាន់ទីជនបទមួយផ្សេងទៀត តាមមធ្យោបាយចាំបាច់ណាក៏ដោយ។ បក្សកុម្មុយនីស្តកម្ពុជា បានចាំផ្តើមផ្លាស់ទីលំនៅរបស់ប្រជាជនមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបានបន្តរហូតយ៉ាងហោចណាស់ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ សហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងអំពីការផ្លាស់ទីលំនៅប្រជាជនជាក់លាក់ទាំងបីដំណាក់កាល៖ ការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ (ដំណាក់កាលទី១) ពីភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ភូមិភាគនិរតី ភូមភាគបស្ចិម និងភូមិភាគបូព៌ា (ដំណាក់កាលទី២) និងពីភូមិភាគបូព៌ា (ដំណាក់កាលទី៣)។

កថាខណ្ឌ១៦១៖ គោលដៅមួយក្នុងចំណោមគោលដៅទាំងអស់នៃការផ្លាស់ទីលំនៅប្រជាជន គឺដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃកម្លាំងពលកម្មសម្រាប់សហករណ៍ និងការដ្ឋានទាំងឡាយ។ បក្សកុម្មុយនីស្តកម្ពុជាបានធ្វើការប្រកាសថែមទៀតថា គឺដើម្បីធានានូវស្បៀងអាហារ និងការពារសន្តិសុខរបស់ប្រជាជន។ ឯកសារមួយរបស់បក្សកុម្មុយនីស្តកម្ពុជា ចុះខែកញ្ញា ឆ្នាំ១៩៧៥ បានឆ្លុះបញ្ចាំងពី

គោលដៅសំខាន់មួយផ្សេងទៀតគឺ៖ ការដកហូតសិទ្ធិគោលនយោបាយ និងសេដ្ឋកិច្ចពីអ្នករស់នៅទីក្រុង និងពីអតីតអ្នករដ្ឋការ ដើម្បីប្រែក្លាយពួកគេឲ្យទៅជាកសិករ និងដើម្បី "រក្សាលទ្ធផលបដិវត្តន៍"។ ហេតុដូច្នេះ ការផ្លាស់កន្លែងប្រជាជន គឺត្រូវបានយកចិត្តទុកដាក់ជាពិសេសក្នុងកិច្ចប្រឹងប្រែងរបស់បក្សកុម្មុយនីស្តកម្ពុជាដែលថា "យើងខំធ្វើយ៉ាងម៉េច ឲ្យតែចំណេញដល់បដិវត្តន៍"។

[០៩:២២:០១]

<u>កាលបរិច្ឆេទ និងការចូលរួម</u>

កថាខណ្ឌ១៦២៖ ចាប់តាំងពីមុនឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តគោលនយោបាយជម្លៀសប្រជាជនពីទីក្រុងនានា ដែលស្ថិតនៅក្រោមការត្រួតត្រារបស់ពួកគេ៖ ប្រជាជនត្រូវបានផ្លាស់កន្លែងមួយផ្នែក ឬទាំងស្រុងទីរួមខេត្តស្ទឹងត្រែង ខេត្តក្រចេះ ស្រុកបាណន់ និង ឧដុង្គ។ រហូតដល់ភូមិភាគឧត្តរ បូព៌ា ពល្លសាន និងនៅតំបន់៥០៥។ ការបោះពុម្ពផ្សាយទស្សនាវដ្តីទង់បដិវត្តបានបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានផ្លាស់ទីលំនៅប្រជាជន ពីទីប្រជុំជនទៅជនបទដោយមានការគិតទុកជាមុន។

កថាខណ្ឌ១៦៣៖ គោលនយោបាយនេះ ត្រូវបានអនុវត្តដំបូងនៅថ្ងៃ ឬនៅអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ (ដំណាក់ទី១) បន្ទាប់មកចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៥ រហូតដល់ ឆ្នាំ១៩៧៧ (ដំណាក់កាលទី២) និងនៅចុងឆ្នាំ១៩៧៧ រហូតដល់ឆ្នាំ១៩៧៨ (ដំណាក់កាលទី៣)។

[០៩:២២:៥៧]

កថាខណ្ឌ១៦៤៖ ទាក់ទងនឹងដំណាក់កាលទី១ ប៉ុល ពត បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការធ្វើសេចក្តីសម្រេច ដើម្បីជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញ។ ផែនការរៀបចំទទួលអ្នកជម្លៀសពីទីក្រុងភ្នំពេញ ត្រូវបានផ្សព្វផ្សាយមុននឹងធ្វើការជម្លៀស។ សមាជិកមជ្ឈិមបក្សផ្សេងទៀតក៏មានការពាក់ព័ន្ធនៅក្នុងការរៀបចំផែនការនៃការជម្លៀសនេះដែរ ក្នុងអំឡុងពេលប្រជុំកាលពីចុងខែមីនា និងដើមខែមេសា ឆ្នាំ១៩៧៥។ កិច្ចប្រជុំផ្សេងៗទៀតត្រូវបានធ្វើឡើងដើម្បីផ្សព្វផ្សាយដល់កម្មាភិបាលថ្នាក់ក្រោមអំពីសេចក្តីសម្រេច។ ក៏ប៉ុន្តែកងទ័ពបដិវត្តន៍ -- ក៏ប៉ុន្តែកងទ័ពបក្សកុម្មុយនីស្តកម្ពុជាមួយចំនួនត្រូវបានជូនដំណឹងជាមុនអំពីការវាយប្រហារលើទីក្រុងភ្នំពេញ ជាទូទៅតាមរយៈថ្នាក់លើរបស់ពួកគេ និងយោងតាមឋានានុក្រម ឯកងទ័ពផ្សេងទៀតបានទទួលត្រឹមតែបទបញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្លាមៗបន្ទាប់ពួកគេមកដល់ទីក្រុងភ្នំពេញប៉ុណ្ណោះ។ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មិនមែនជាព្រឹត្តិការណ៍មួយដាច់ដោយឡែកតែឯងនោះទេ ប៉ុន្តែវាជាផ្នែកមួយនៃផែនការរួមក្នុងការផ្លាស់

ទីលំនៅរបស់ប្រជាជនចេញពីទីក្រុងបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

[០៩:២៤:២៤]

កថាខណ្ឌ១៦៥៖ ទាក់ទងនឹងដំណាក់កាលទី២ ផែនការបញ្ជូនប្រជាជនទៅភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ បានបង្ហាញឲ្យឃើញច្បាស់តាមរយៈដំណើរទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាទៅភូមិភាគទាំងនេះ មុន ឬ ប្រហែលជាខែសីហា ឆ្នាំ១៩៧៥។ ការធ្វើទស្សនកិច្ចនេះបានធ្វើឲ្យលេចចេញនូវបញ្ហាដែលថា "កម្លាំងមនុស្សមិនគ្រប់។ ត្រូវបន្ថែមកម្លាំងពលកម្ម។ ៣ ឬ ៤សែនទៀតក៏មិនគ្រប់។ កម្លាំង១លាននាក់បច្ចុប្បន្នធ្វើមិនបាន ៥០ភាគរយទេ។ ត្រូវថែម ៤ ឬ ៥សែនទៀត"។

ឯកសាររបស់បក្សចុះខែកញ្ញា ឆ្នាំ១៩៧៥ បានលើកឡើងថា ប្រជាជនថ្មី ត្រូវធ្វើបន្លាស់ទីចេញពីភូមិភាគ ដែលជាកន្លែងប្រមូលផ្តុំបណ្តោះអាសន្នរបស់ពួកគេ ដោយសារជួបបញ្ហាកង្វះស្បៀងអាហារ។ ឯកសារនោះបានគូសបញ្ជាក់ថា ដំណោះស្រាយទៅលើបញ្ហានេះ ដែលមានលក្ខណៈអចិន្ត្រៃយ៍ និងស្របទៅតាមតម្រូវការផលិតកម្ម គឺត្រូវតែអនុវត្តចាប់ពីខែវិច្ឆិកា ឆ្នាំ១៩៧៥។

សាក្សីផ្សេងៗ និងឯកសារទាំងឡាយ ផ្តល់នូវភស្តុតាងថែមទៀត ទាក់ទិននឹងមធ្យោបាយ ដែលមជ្ឈិមបក្សមានការពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅទាំងអស់នេះ។ សារទូរលេខលេខ ១៥ ចុះខែវិច្ឆិកា ឆ្នាំ១៩៧៥ ដែលបានផ្ញើទៅ ប៉ុល ពត ដោយរៀបរាប់អំពីសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជាទាក់ទងនឹងការផ្លាស់ទីលំនៅរបស់ប្រជាជននៅដំណាក់កាលទី២។

[០៩:២៦:០១]

យោងតាមអតីតប្រធានអង្គភាពផ្នែកសារទូរលេខនៅភូមិភាគកណ្តាល ភូមិភាគឧត្តរចាស់ ភូមិភាគបូព៌ា ត្រូវបញ្ជូនរបាយការណ៍ពីភូមិភាគទៅ ប៉ុល ពត ថ្នាក់មជ្ឈិមសិន។ រួចហើយរង់ចាំការណែនាំពី ប៉ុល ពត។ កែ ពក ទទួលសារទូរលេខរឿងនេះមកពីមជ្ឈិម គឺមិនមែនទទួលផ្ទាល់មកពីខាងបូព៌ានោះទេ។

ផ្នែកទី៨៖ ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃឧក្រិដ្ឋកម្ម

ក) ការផ្លាស់ទីលំនៅរបស់ប្រជាជន

<u>ការជម្លៀសប្រជានពីភ្នំពេញដំណាក់កាលទី១</u>

<u>*ស្ថានភាពមុនឆ្នាំ១៩៧៥*</u>

កថាខណ្ឌ២២១៖ ចន្លោះពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ប្រជាជននៅទីក្រុងភ្នំពេញ បានកើនឡើង

យ៉ាងខ្លាំងដល់ចំនួនច្រើនលាននាក់ ដោយសារតែប្រជាជនផ្លាស់ទីលំនៅពីទីជនបទ ចូលទីក្រុងដើម្បីគេចពីសង្គ្រាម។

កថាខណ្ឌ២២២៖ បុគ្គលិក និងគ្រឿងបរិធាន នៃសេវាកម្មសុខាភិបាល បានថយចុះនូវសមត្ថភាពនៅអំឡុងពេលនោះ ហើយសេវាកម្មនានានៅទីជនបទ មានកាន់តែតិចជាងនៅតាមទីក្រុង ដោយសារមូលហេតុសំខាន់បណ្តាលមកពីសង្គ្រាម ដែលចេះតែបន្តរវាងកម្លាំងបក្សកុម្មុយនីស្តកម្ពុជា និងកម្លាំងរបប លន់ នល់។ មន្ទីរពេទ្យនានានៅក្នុងរដ្ឋធានី កាន់តែមានភាពណែនតាន់តាប់ឡើង និងគុណភាពមានការប្រែប្រួល។ វិស័យសុខាភិបាលមានចំណែកអត្រាតិចជាង៣ភាគរយ នៃថវិកាជាតិ នៅចុងឆ្នាំ១៩៧៤ បើប្រៀបធៀបនឹងអត្រា ៥.៧ភាគរយ នៅឆ្នាំ១៩៦៨។

[០៩:២៨:០១]

កថាខណ្ឌ២២៣៖ ទោះបីជាភាពអត់ឃ្លាន និងកង្វះជីវជាតិជាបញ្ហាគួរឲ្យព្រួយបារម្ភនៅអំឡុងពេលសង្គ្រាមមុនឆ្នាំ១៩៧៥ ក៏ដោយ ក៏មិនមានរបាយការណ៍ណាមួយនិយាយអំពីការរាលដាលនៃគ្រោះទុរភិក្ស ឬហានិភ័យនៃជំងឺឆ្លងនៅក្នុងអំឡុងពេលនោះឡើយ។ បញ្ហានេះ ដោយសារតែមួយផ្នែកធំមានអង្គការបរទេសជួយឧបត្ថម្ភដល់ប្រជាជន ទោះបីជាសមត្ថភាពរបស់អង្គការបរទេសទាំងនោះ ដែលទទួលបន្ទុកជួយសហគមន៍ ដែលត្រូវបានទទួលរងផលប៉ះពាល់ថយចុះ ខណៈពេលដែលអសន្តិសុខកើនឡើងជាបន្តបន្ទាប់។

<u>ការចាកចេញ</u>

កថាខណ្ឌ២២៤៖ នៅពេលដែលកងទ័ពបដិវត្តន៍ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាចូលដល់រដ្ឋធានីប្រជាជនភ្នំពេញត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុងចាប់តាំងពីព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយការចាកចេញនេះ បានបន្តអស់ជាច្រើនសប្តាហ៍ទាំងយប់ទាំងថ្ងៃ។ ជាទូទៅប្រជាជនបានចាកចេញពីលំនៅដ្ឋានរបស់ខ្លួនទូទាំងរដ្ឋធានី។

<u>ប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅ</u>

កថាខណ្ឌ២២៥៖ ប្រជាជនដែលត្រូវបានបង្ខំឲ្យចាកចេញពីភ្នំពេញ ភាគច្រើនជាជនស៊ីវិលរួមមាន៖ បុរស ស្ត្រី មនុស្សចាស់ កុមារ ព្រះសង្ឃ។ល។ វេជ្ជបណ្ឌិត និងគិលានុបដ្ឋាកក៏ត្រូវបានប្រាប់ឲ្យចេញដែរ ព្រមទាំងអ្នកជំងឺនៅមន្ទីរពេទ្យ អ្នករបួស និងអ្នកជំងឺរួមទាំងស្ត្រីដែលទើបសម្រាលកូនផងដែរ។ គ្រប់គ្រួសារទាំងអស់ ត្រូវបានបង្ខំឲ្យចេញពីភ្នំពេញ។ ជារឿយៗ សមាជិកគ្រួសារត្រូវបានបំបែកពីគ្នា

ក៏ដោយ។

[០៩:២៩:៤៨]

កថាខណ្ឌ២២៦៖ ចំនួនប្រជាជនជាក់លាក់ ដែលត្រូវបានបង្ខំឲ្យចេញពីភ្នំពេញ មិនមានភាពច្បាស់លាស់ទេ ទោះបីជាប្រជាជនសរុបទាំងអស់ទំនងជាមានចំនួនពី ១.៥ ទៅ ២.៦លាននាក់ក៏ដោយ។ សាក្សី ជាច្រើនបាននិយាយថា “បានឃើញមនុស្សយ៉ាងច្រើនកកកុញ ធ្វើដំណើរនៅតាមផ្លូវនានា ហើយថា ទីក្រុងទាំងមូលមិនមានប្រជាជនទេ”។ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានអះអាងថា “ប្រជាជនក្រុងភ្នំពេញ និងតំបន់ផ្សេងទៀត ដែលគ្រប់គ្រងដោយខ្មាំងមានចំនួនប្រហែល ១លាននាក់”។ ក្រោយថ្ងៃទី១៧ ខែមេសា បក្សកុម្មុយនីស្តបានប៉ាន់ប្រមាណចំនួនអ្នកដែលត្រូវបានជម្លៀសសរុបជាផ្លូវការមានចំនួន ២លាននាក់។ បន្ទាប់មកបក្សកុម្មុយនីស្តកម្ពុជា បានកំណត់តួលេខអ្នកដែលត្រូវបានជម្លៀសពីភ្នំពេញ និងទីរួមខេត្តនានាថា មានប្រមាណ៣លាននាក់។ ទោះបីជាពេលខ្លះចំនួន៣លាននាក់នេះ សំដៅតែទីក្រុងភ្នំពេញតែមួយគត់ ជាពិសេសលើកឡើងដោយ អៀង សារី ក៏ដោយ។

[០៩:៣១:០០]

ក្នុងឆ្នាំ១៩៧៧ បក្សកុម្មុយនីស្តកម្ពុជាបានផ្លាស់ប្តូរការប៉ាន់ប្រមាណរបស់ខ្លួនចំពោះចំនួនប្រជាជនសរុបដែលត្រូវបានជម្លៀសថា មានចំនួនដល់៤លាននាក់។

<u>គោលដៅដំបូង</u>

កថាខណ្ឌ២២៧៖ ប្រជាជនស៊ីវិលដែលចាកចេញពីភ្នំពេញ បានចាកចេញតាមគ្រប់ទិសដៅតាមផ្លូវជាតិនៅគ្រប់ទិស ទៅទិសខាងជើង ខាងត្បូង ខាងកើត និងខាងលិច ទីក្រុង។ ជាទូទៅប្រជាជនមិនត្រូវបានប្រាប់ពីទិសដៅ ឬពីគោលដៅចុងក្រោយទេ លើកលែងតែថា ត្រូវទៅទីជនបទ ឬទីកន្លែងកំណើត ឬភូមិកំណើតរបស់ខ្លួន។ មានពេលខ្លះ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានឲ្យប្រជាជនផ្លាស់ប្តូរទិសដៅ។ សក្ខីកម្មបង្ហាញថា ប្រជាជនបានទៅកាន់តំបន់នានានៃប្រទេសកម្ពុជា។ ជារឿយៗ សហគមន៍មូលដ្ឋានត្រូវបានណែនាំឲ្យទទួលយកប្រជាជនដែលទើបមកដល់ថ្មី ហើយផ្តល់អាហារ និងជម្រក ទោះបីជាទូទៅ វាមិនគ្រប់គ្រាន់ទៅនឹងចំនួនអ្នកមកដល់ក៏ដោយ។

ក្នុងករណីខ្លះ ប្រជាជនស៊ីវិលមកពីភ្នំពេញត្រូវបានផ្តល់ជម្រកនៅក្នុងរោងធំៗ ឬត្រូវសង់ជម្រកដោយខ្លួនឯង។ ប្រជាជនមួយចំនួនបានធ្លាក់ខ្លួនឈឺ ដោយសារការធ្វើដំណើរពីភ្នំពេញ ឬដោយសារ

ស្ថានភាពរស់នៅផ្សេងៗនៅពេលមកដល់។ ប្រជាជនដែលមកពីភ្នំពេញត្រូវបានផ្តល់អត្តសញ្ញាណថាជា “ប្រជាជនថ្មី” ឬ “ប្រជាជន១៧ មេសា” ឬក៏ “ប្រជាជនបញ្ញើ” ហើយជារឿយៗត្រូវបានកំណត់ជាមុខសញ្ញានៅពេលមកដល់ដោយផ្អែកលើអត្តសញ្ញាណនេះ។

[០៩:៣៣:១២]

**ប្រធានអង្គជំនុំ៖**

លោក ដាវ អានសាន អានទូវកថាខណ្ឌ២២៨ ដល់២៧៣ និងកថាខណ្ឌ២៧៤ ដល់២៨១!

**ក្រឡាបញ្ជី៖**

បាទ ខ្ញុំសូមអានបន្ត។

<u>មធ្យោបាយ និងវិធីសាស្ត្រនៃការផ្លាស់ទីលំនៅ</u>

<u>មធ្យោបាយ</u>

កថាខណ្ឌ២២៨៖ អ្នកដែលរៀបចំការផ្លាស់ទីលំនៅប្រជាជនចេញពីភ្នំពេញ ត្រូវបានកំណត់អត្តសញ្ញាណដោយសាក្សីថា ជា “កងទ័ពខ្មែរក្រហម”។ កងទ័ពទាំងនោះត្រូវបានពណ៌នាថា មានសម្លៀកបំពាក់ពណ៌ខ្មៅ ឬពណ៌កាគី មួយចំនួនមានកន្សែង ឬក្រមាបង់ក។ ជារឿយៗ កងទ័ពខ្មែរក្រហម មានបំពាក់ដោយអាវុធ។

កថាខណ្ឌ២២៩៖ កងទ័ពធ្វើការប្រកាសនានា ជាទូទៅតាមឧឃោសនសព្ទ ឬប្រដាប់បំពងសំឡេងធំៗថា “ប្រជាជនមានពេលវេលាកំណត់ដើម្បីចាកចេញពីភ្នំពេញ”។ ក្នុងករណីខ្លះ មានសេចក្តីរាយការណ៍ថា កងទ័ពបក្សកុម្មុយនីស្តកម្ពុជាមានបញ្ជីឈ្មោះ ហើយពួកគេត្រូវបានបែងចែកទៅតាមទីតាំងជាក់លាក់នានាក្នុងរដ្ឋធានី ដើម្បីពិនិត្យមើលការផ្លាស់ទីលំនៅរបស់ប្រជាជន។

កថាខណ្ឌ២៣០៖ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាដែលមកពីអង្គភាពផ្សេងៗ ត្រូវបានឃើញថាបានចូលរួមដើម្បីអនុវត្តការផ្លាស់ទីលំនៅរបស់ប្រជាជនភ្នំពេញ។ ក្រុមកងទ័ពទាំងនោះមានដូចជាកងទ័ពភូមិភាគឧត្តរ រួមមាន៖ កងពលធំលេខ១ នៅក្រោមមេបញ្ជាការឈ្មោះ (លុប)។ កងទ័ពភូមិភាគនិរតី កងទ័ពភូមិភាគពិសេស និងកងទ័ពភូមិភាគបូព៌ា។ ហើយពេលខ្លះសាក្សីនានារៀបរាប់ថា “ក្រុមកងទ័ពទាំងនោះមានឥរិយាបថផ្សេងៗគ្នាចំពោះប្រជាជន”។

[០៩:៣៥:១១]

កថាខណ្ឌ២៣១៖ ប្រជាជនមិនបានរឹងទទឹងនឹងការប្រាប់ឲ្យចាកចេញពីភ្នំពេញឡើយ។ សាក្សី

មួយចំនួនបានបង្ហាញសក្ខីកម្មថា“មិនបានឃើញអំពើហិង្សាជាក់លាក់ណាមួយប្រព្រឹត្តដោយកងទ័ពបក្សកុម្មុយនីស្តកម្ពុជានោះទេ”។ ទោះបីយ៉ាងណាក៏ដោយសាក្សីភាគច្រើននិយាយថា “កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានជាប់ពាក់ព័ន្ធក្នុងការគំរាមកំហែង និងការប្រើប្រាស់កម្លាំង ដើម្បីធ្វើឲ្យប្រាកដថា ប្រជាជនចាកចេញពីផ្ទះរបស់ខ្លួន”។ សាក្សីនានាបានរាយការណ៍ថា “បានឮស្នូរកាំភ្លើង”។

កថាខណ្ឌ២៣២៖ សាក្សីដទៃទៀតនិយាយថា “កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានបាញ់សម្លាប់ប្រជាជន ប្រសិនបើពួកគេបដិសេធមិនចាកចេញពីផ្ទះ”។ ជនស៊ីវិលក៏ត្រូវបានសម្លាប់ផងដែរនៅក្នុងការបាញ់តបតគ្នា ដែលមានគោលដៅចំពោះទាហាន លន់ នល់។ សាក្សីមួយចំនួនបានប្រាប់ថា “បានឃើញសាក្សីនៅតាមផ្លូវនានានៅទីក្រុងភ្នំពេញ”។ សាក្សីដទៃទៀតនិយាយថា “កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានទទួលបញ្ជាឲ្យប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ ដើម្បីឲ្យប្រាកដថាប្រជាជនចាកចេញពីភ្នំពេញ”។

[០៩:៣៦:៣២]

កថាខណ្ឌ២៣៣៖ មានការលើកឡើងផងដែរ អំពីការធ្វើបាប និងអំពើហិង្សាផ្សេងៗប្រឆាំងនឹងប្រជាជនស៊ីវិលដូចជា វាយ និងបាញ់ឡើងលើ។ មានសេចក្តីរាយការណ៍ថា “ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ប្រជាជនទីក្រុងភ្នំពេញត្រូវបានរឹបអូសយកដោយកងទ័ពបក្សកុម្មុយនីស្តកម្ពុជា”។

កថាខណ្ឌ២៣៤៖ ទាក់ទងនឹងទាហានៗ លន់ នល់ ថា ពួកគេខ្លះត្រូវបានដកអាវុធដោយកងទ័ពបក្សកុម្មុយនីស្តកម្ពុជា ហើយត្រូវបានឲ្យចាកចេញពីទីក្រុងជាមួយនឹងប្រជាជនស៊ីវិល។ ទាហាន លន់ នល់ ខ្លះទៀតត្រូវបានកំណត់អត្តសញ្ញាណដោយការសួរចម្លើយ ហើយបំបែកចេញពីប្រជាជនដែលចាកចេញពីទីក្រុង។ មានការប្រកាសជាមុនថា “អង្គការអាចលើកលែងទោសដល់ប្រជាជនទាំងឡាយដែលមកពីរបបមុន លើកលែងតែមន្ត្រីថ្នាក់ខ្ពស់៧នាក់ប៉ុណ្ណោះ”។ ហើយថា នៅពេលជម្លៀស កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានស្នើអតីតទាហាន លន់ នល់ មន្ត្រីរាជការ និងមន្ត្រីប៉ូលិស ឲ្យណែនាំខ្លួនដើម្បីធ្វើការបម្រើបក្ស។

ហើយបន្ទាប់មក បុគ្គលទាំងនេះត្រូវបានយកទៅកន្លែងដែលគ្មាននរណាដឹង មុននឹងបាត់ខ្លួន។

[០៩:៣៧:៥៦]

កថាខណ្ឌ២៣៥៖ ទាហាន លន់ នល់ មួយចំនួនត្រូវបានបាញ់ ប្រសិនបើពួកគេបដិសេធមិនទម្លាក់អាវុធរបស់ខ្លួន ឬបានបង្ហាញពីការរឹងទទឹងណាមួយ។ ជាពិសេស មានបញ្ហាជាលាយលក្ខណ៍

អក្សរមួយដែលចុះហត្ថលេខាដោយសមមិត្ត (លុប) ដែលបានបញ្ជាឲ្យកម្ទេចអ្នករដ្ឋការលន់ នល់ ដែលមានឈ្មោះក្នុងបញ្ជីមួយ ហើយសាក្សីមួយរូបនិយាយថា “សុន សេន បានបញ្ជាឲ្យចាប់ខ្លួនមន្ត្រីរដ្ឋការស៊ីវិលថ្នាក់ខ្ពស់នៃរបប លន់ នល់ ព្រមទាំងអ្នកនៅក្នុងមន្ទីរពេទ្យផងដែរ”។ ក្រោយមកពួកគេត្រូវបានសម្លាប់ និងបោះចូលទៅក្នុងអណ្តូងមួយនៅតំបន់ទួលគោក។ សាក្សីខ្លះនិយាយថា បានឃើញ -- បានមើលឃើញការសម្លាប់ទាហាន លន់ នល់ ហើយនិងបានឃើញសាកសពទាហានលន់ នល់ នៅតាមផ្លូវ។

[០៩:៣៨:៥២]

<u>វិធីសាស្ត្រ</u>

កថាខណ្ឌ២៣៦៖ មិនមានសក្ខីកម្មណាបង្ហាញថា មានការផ្តល់នូវការដឹកជញ្ជូនណាមួយទេក្រៅពីការនិយាយខ្លះអំពីការប្រើប្រាស់ឡានយោធា។ ប្រជាជនភាគច្រើនបានធ្វើដំណើរដោយថ្មើរជើង អ្នកផ្សេងទៀតបានបើក ឬយានជំនិះផ្សេងទៀត ឬរុញយានជំនិះទាំងនោះរួមមាន៖ កង់ម៉ាស៊ីន ឬតូចទោចក្រយានយន្ត និងទោចក្រក្រយាន ឬស៊ីក្លូ នៅក្នុងករណីខ្លះទូកក៏ត្រូវបានប្រើប្រាស់ផងដែរ។

កថាខណ្ឌ២៣៧៖ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានប្រាប់ប្រជាជនកុំឲ្យយករបស់របរផ្ទាល់ខ្លួនច្រើនពេក។ ដោយនៅក្នុងករណីមួយចំនួនបានគូសបញ្ជាក់ថា មិនមានការចាំបាច់ ព្រោះថាពួកគេចាកចេញសម្រាប់រយៈពេលខ្លីតែប៉ុណ្ណោះ ហើយថាប្រជាជនមិនអាចយករបស់របរទៅជាមួយខ្លួនបានដោយសារពួកគេត្រូវចាកចេញជាប្រញាប់។ ដូច្នេះ ប្រជាជនភាគច្រើនបានទុករបស់របរផ្ទាល់ខ្លួននៅក្នុងផ្ទះ។

[០៩:៤០:០១]

ចំពោះប្រជាជនដែលយករបស់របរតាមខ្លួន មិនមានភស្តុតាងបង្ហាញអំពីការជួយដឹកជញ្ជូនរបស់របរឲ្យពួកគេទេ។ ប្រជាជនយកអីវ៉ាន់តាមខ្លួន ដោយទូលលើក្បាល ឬលីនៅនឹងស្មា ដឹកតាមរទេះ ឬតាមយានជំនិះរបស់ខ្លួន។ ប្រជាជនបានយកតាមខ្លួននូវរបស់របរដូចជា អង្ករ លុយ ថ្នាំសង្កូវ សៀវភៅ ឬសម្លៀកបំពាក់។ ប្រជាជនក៏បានជួយអាសាដល់អ្នកដែលឈឺ និងមនុស្សចាស់ផងដែរ។

កថាខណ្ឌ២៣៨៖ មានសក្ខីកម្មមួយចំនួនបង្ហាញថា ម្ហូបអាហារ ឬទម្រង់ដទៃទៀត នៃការឧបត្ថម្ភត្រូវបានផ្តល់ឲ្យប្រជាជនអំឡុងពេលធ្វើដំណើរចេញពីភ្នំពេញ។ ទោះបីជាសក្ខីកម្មខ្លះបង្ហាញថា កងទ័ពបក្សកុម្មុយនីស្តកម្ពុជាមួយចំនួនបានផ្តល់អង្ករដល់ប្រជាជនបរិភោគក៏ដោយ ក៏សាក្សីភាគច្រើន

រាយការណ៍ថា ពួកគេបានផឹកទឹកកខ្វក់ ពីស្រះទឹកនៅតាមផ្លូវ។ ហើយថាកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបានកត់ឈ្មោះអ្នកដែលបានទទួលអាហារ និងឈ្មោះអ្នកដែលមិនចង់បន្តដំណើរទៅមុខទៀត។ សាក្សីពីររូបនិយាយថា ពួកគេមិនបានឃើញប្រជាជនអត់ឃ្លាន អំឡុងពេលផ្លាស់ទីលំនៅចេញពីភ្នំពេញទេ។

កថាខណ្ឌ២៣៩៖ មិនមានភស្តុតាងដែលថា កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានផ្តល់សន្តិសុខ ឬការការពារដល់ប្រជាជននៅតាមផ្លូវឡើយ។ ប្រជាជនមិនមានជម្រកនៅតាមផ្លូវ ហើយបានដេកលើកន្ទេលនៅតាមផ្លូវ ដេកនៅក្នុងផ្ទះគ្មានមនុស្ស ឬដេកនៅក្រោមដើមឈើ។ ប្រជាជនមិនត្រូវបានផ្តល់អាហារ ឬទឹកទេ។ សាក្សីមួយរូបនិយាយថា កងទ័ពបក្សកុម្មុយនីស្តកម្ពុជាមិនអនុញ្ញាតឲ្យយកអាហារឡើយ ហើយអាហារដែលមានតែមួយមុខគត់នោះ គឺបាយ។ ប្រជាជនមួយចំនួនត្រូវធ្វើដំណើរទាំងពេលយប់ ដោយមិនសម្រាកអស់ជាច្រើនថ្ងៃ។ ប្រជាជនខ្លះ បានហើមជើង ដោយសារធ្វើដំណើរផ្លូវឆ្ងាយ ហើយមានសេចក្តីរាយការណ៍អំពីការស្លាប់ដោយស្ថានភាពដូចនេះ។

មិនមានភស្តុតាងបង្ហាញថា ប្រជាជនបានទទួលថ្នាំសង្កូវឡើយ។ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាមួយចំនួនបានយកទ្រព្យសម្បត្តិពីប្រជាជននៅអំឡុងពេលធ្វើដំណើរ។

[០៩:៤២:៣០]

កថាខណ្ឌ២៤០៖ សាក្សីជាច្រើនបាននិយាយថា បានឃើញសាកសពមនុស្សដែលត្រូវបានបាញ់សម្លាប់នៅតាមផ្លូវ។ ប្រជាជនត្រូវបានសម្លាប់នៅតាមផ្លូវ ដោយសារបញ្ហាតូចតាច ដូចជា មិនចង់បោះបង់ចោលកង់របស់ខ្លួន។ ទោះបីជាសាក្សីមួយចំនួនផ្តល់ចម្លើយថា ពួកគេមិនបានឃើញការធ្វើទុក្ខទោសណាមួយពីសំណាក់កងទ័ពបក្សកុម្មុយនីស្តកម្ពុជា ចំពោះជនស៊ីវិល ឬក៏ថាពួកគេថា មិនបានឃើញនរណាស្លាប់ម្នាក់ -- មិនបានឃើញនរណាម្នាក់ស្លាប់នៅតាមផ្លូវទេក៏ដោយ ក៏ អៀង សារី ខ្លួនឯងបាននិយាយថា ប្រជាជន២.០០០ ទៅ៣.០០០នាក់ បានស្លាប់ នៅអំឡុងការជម្លៀសចេញពីភ្នំពេញ។

[០៩:៤៣:២០]

<u>ការវិលត្រឡប់ទៅភ្នំពេញវិញ</u>

កថាខណ្ឌ២៤១៖ សាក្សីមួយរូបនិយាយថា កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានគំរាមកំហែងថានឹងបាញ់សម្លាប់ ប្រសិនបើនរណាវិលត្រឡប់ទៅទីក្រុងភ្នំពេញវិញ។ នួន ជា បាននិយាយអំពីចេតនានៃការអនុញ្ញាតឲ្យប្រជាជនវិលត្រឡប់ទៅភ្នំពេញ ហើយ អៀង សារី បាននិយាយនៅក្នុងខែឧសភា

ឆ្នាំ១៩៧៧ ថា "ទីក្រុងនានា ត្រូវបានបំពេញដោយប្រជាជនវិញ បន្ទាប់ពីការផ្លាស់ទីលំនៅប្រជាជនជាដំបូង ទៅជនបទ។ ហើយថា ប្រជាជនអាចមានជម្រើសត្រឡប់ទៅទីក្រុងវិញ ប្រសិនបើពួកគេចង់ ឬ អាចបន្តនៅជនបទ"។ ប៉ុន្តែទោះបីជាក្នុងកាលៈទេសៈកម្រខ្លះ ប្រជាជនមួយចំនួនទំនងជាត្រូវបានបញ្ជូនត្រឡប់មកភ្នំពេញវិញ ដើម្បីធ្វើការក៏ដោយ ក៏ជាទូទៅទីក្រុងមានសភាពស្ងប់ស្ងាត់ គ្មានប្រជាជន ហើយមានតែកងទ័ព និងកម្មាភិបាលមួយចំនួនតែប៉ុណ្ណោះ រហូតដល់ការដួលរលំនៃរបបកម្ពុជាប្រជាធិប-តេយ្យ។

យោងតាមសេចក្តីថ្លែងការណ៍មួយរបស់ ប៉ុល ពត ដោយ ប៉ុល ពត នៅឯការប្រជុំមួយ នាថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៧៦ ប្រជាជននៅភ្នំពេញ មានចំនួនជាងមួយសែន។ នាខែមេសា ឆ្នាំ១៩៧៧ តួលេខនេះ រួមបញ្ចូលទាំងរបបអាហារ ចំនួន៤៣.៨១០នាក់ ដែលត្រូវបានផ្តល់ដោយគណៈសេនាធិការដ្ឋាន។

[០៩:៤៥:០២]

<u>មូលហេតុដែលលើកឡើងដើម្បីផ្លាស់ទីលំនៅប្រជាជន</u>

កថាខណ្ឌ២៤២៖ នៅពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានប្រាប់ប្រជាជនឲ្យចេញពីផ្ទះរបស់ខ្លួនតែរយៈពេលខ្លះ គឺតែ ២ ឬ ៣ថ្ងៃ ឬ ១ ឬ ២ សប្តាហ៍ប៉ុណ្ណោះយ៉ាងយូរ។

កថាខណ្ឌ២៤៣៖ សាក្សីមួយចំនួននិយាយថា កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានប្រាប់ប្រជាជនថា ជាការចាំបាច់ក្នុងការចាកចេញពីភ្នំពេញ ដើម្បីសន្តិសុខផ្ទាល់ខ្លួន ហើយកងទ័ពទាំងនោះអាចកំណត់អត្តសញ្ញាណ ឬកម្ចាត់ទាហាន លន់ នល់ បើមិនដូច្នេះទេ គឺដើម្បីស្វែងរកខ្មាំង។ មានការលើកឡើងផងដែរអំពីការទម្លាក់គ្រាប់បែក ដែលបានគ្រោងទុកទីក្រុងដោយកងទ័ពសហរដ្ឋអាមេរិក ទោះបីជាមានសញ្ញាបង្ហាញឲ្យឃើញផងដែរថា ប្រជាជនមួយចំនួនមិនជឿលើការពន្យល់លើហេតុការណ៍នេះក៏ដោយ។ ក្នុងចំណោមយុត្តិកម្មនានាដែលបានលើកឡើង មានការលើកឡើងផងដែរអំពីការដាក់បណ្តាញគិញរបស់ភ្នាក់ងារ សេ.អ៊ី.អា ដើម្បីបើកការប្រយុទ្ធតបវិញ។

[០៩:៤៦:១៨]

កថាខណ្ឌ២៤៤៖ សាក្សីខ្លះបានបង្ហាញផងដែរថា មានការចាំបាច់នឹងបង្ខំឲ្យប្រជាជនចេញពីភ្នំពេញ ដើម្បីរៀបចំនិងបោសសម្អាតទីក្រុង ដូចជាការបោសសម្អាតអារុធយុទ្ធភណ្ឌជាដើម។

កថាខណ្ឌ២៤៥៖ មានការផ្តល់យុត្តិកម្មពាក់ព័ន្ធនឹងនយោបាយផងដែរ៖ សាក្សីមួយចំនួននិយាយថា ពួកគេត្រូវបានប្រាប់ថា អង្គការកំពុងរង់ចាំទទួលពួកគាត់ ហើយថាពួកគេត្រូវការពួកគាត់ដើម្បីកសាងសេដ្ឋកិច្ចជនបទ កសាងទំនប់ទឹក ព្រែកជីក និងការងារនៅតាមវាលស្រែ ហើយថាអ្នកដែលត្រូវបានអនុញ្ញាតឲ្យនៅទីក្រុងគឺមានតែសមាជិកងទ័ពប៉ុណ្ណោះ ដែលត្រូវធ្វើការរបស់ខ្លួន -- ដែលត្រូវធ្វើការងាររបស់ខ្លួន។ មានការលើកឡើងផងដែរអំពីកង្វះម្ហូបអាហារនៅភ្នំពេញ ដែលជាមូលហេតុនៃការផ្លាស់ទីលំនៅប្រជាជន ហើយថាដោយសារម្ហូបអាហារមិនមានបរិបូរណ៍នៅជនបទ។

កថាខណ្ឌ២៤៦៖ យុត្តិកម្មទាំងនេះបានបង្ហាញពីសក្ខីកម្មដែលត្រូវបានរកឃើញនៅក្នុងសេចក្តីថ្លែងការណ៍របស់ជនត្រូវចោទ។ នៅក្នុងកិច្ចសម្ភាសន៍មួយដែលបានធ្វើជាមួយអ្នកកាសែតមួយរូបក្នុងឆ្នាំ១៩៨០ អៀង សារី បាននិយាយយោងជាទូទៅដល់មូលដ្ឋានសេដ្ឋកិច្ច នយោបាយ និងយោធាដែលជាយុត្តិកម្មចំពោះការផ្លាស់ទីលំនៅប្រជាជនចេញ។

[០៩:៤៧:៥១]

កថាខណ្ឌ២៤៧៖ អៀង សារី បាននិយាយក្នុងកិច្ចសម្ភាសន៍ជាមួយអ្នកកាសែតមួយរូបក្នុងឆ្នាំ១៩៧៥ ដូចដែលបាននិយាយម្តងទៀតនៅឯសន្និសីទមួយក្នុងឆ្នាំ១៩៧៨ថា មូលហេតុចម្បងចំពោះការផ្លាស់ទីលំនៅប្រជាជន គឺម្ហូបអាហារ។ គាត់និយាយថា ពីដំបូងគេគិតថា ប្រជាជននៅទីក្រុងភ្នំពេញមាន២លាននាក់ ប៉ុន្តែក្រោយមករកឃើញថាមានចំនួន៣លាននាក់។ អៀង សារី បានគូសបញ្ជាក់ថា មុនរបបកម្ពុជាប្រជាធិបតេយ្យ ប្រទេសកម្ពុជាបានទទួលជំនួយជាអាហារចំនួនរវាងពី ៣ម៉ឺន ទៅ៤ ម៉ឺនតោនក្នុងមួយខែពីសហរដ្ឋអាមេរិក។ ហើយថា បក្សកុម្មុយនីស្តកម្ពុជាមិនមានបំណងស្នើសុំជំនួយពីសហគមន៍អន្តរជាតិឡើយ ហើយក៏មិនមានមធ្យោបាយគ្រប់គ្រាន់ក្នុងការដឹកជញ្ជូនម្ហូបអាហារពីជនបទចូលទីក្រុងដែរ។ ខៀវ សំផន បាននិយាយផងដែរនៅក្នុងការសម្ភាសតាមវិទ្យុមួយក្នុងឆ្នាំ២០០៧ថា ប្រជាជនមានការអត់ឃ្លាននៅពេលនោះ ប៉ុន្តែគាត់បានយល់ស្របថា នៅជនបទក៏មិនមានអាហារគ្រប់គ្រាន់ដែរ ដូច្នេះប្រជាជនបរិភោគផ្លែចេកជាមួយបាយ ឬដំឡូង ហើយជំនួយស្បៀងអាហារដ៏មានកំណត់ត្រូវបានបញ្ជូនមកតែពីប្រទេសសម្ព័ន្ធមិត្ត និងបក្សកុម្មុយនីស្តកម្ពុជាតែប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងចម្លើយពីមុនមួយ ខៀវ សំផន បាននិយាយថា រដ្ឋាភិបាលណាមួយដែលទើបងើបចេញពីសង្គ្រាមអាចប្រឈមនឹងបញ្ហាគ្រោះអត់ឃ្លាន ហើយគាត់បាននិយាយថា បន្ទាប់ពីផ្លាស់ទីលំនៅប្រជាជនចេញពីភ្នំពេញ ប្រជាជនមានអាហារគ្រប់គ្រាន់នៅតាមសហករណ៍។

[០៩:៤៩:៣៧]

កថាខណ្ឌ២៤៨៖ ជនត្រូវចោទនានាក៏បាននិយាយយោងទៅដល់មនោគមវិជ្ជានៃរបបនោះ ជាយុត្តិកម្មមួយចំពោះការផ្លាស់ទីលំនៅប្រជាជនផងដែរ។ នៅក្នុងការប្រឈម និងវិបត្តិម្ហូបអាហារនោះ នួន ជា បាននិយាយថា ទិសដៅនៃរបបនោះគឺត្រូវរក្សាឯករាជ្យភាព និងអធិបតេយ្យភាព។ ខៀវ សំផន ក៏បាននិយាយដែរថា ប៉ុល ពត មិនចង់រស់នៅក្រោមការគ្រប់គ្រងរបស់ជនបរទេស។

ការផ្លាស់កន្លែងប្រជាជនពីទីក្រុងទៅជនបទ ក៏ត្រូវបាននិយាយដោយជនត្រូវចោទ នួន ជា ថាជាសមាសធាតុមួយនៃបដិវត្តន៍សង្គម។ អៀង សារី បាននិយាយថា គោលបំណងគឺដើម្បីប្រែក្លាយទីកន្លែងនៅក្នុងក្រុង ដែលមិនមានមនុស្សរស់នៅ ឲ្យទៅជាទីតាំងឧស្សាហកម្ម។ អៀង សារី បាននិយាយដែរថា វាមានការចាំបាច់ ដើម្បីនឹងលត់ដំប្រជាជន ដែលមកពីទីក្រុងឲ្យស៊ូទ្រាំនឹងការលំបាក ទាំងផ្លូវកាយ និងផ្លូវចិត្ត តាមរយៈពលកម្មធ្ងន់ធ្ងរ។

តាមសាក្សីមួយរូបបាននិយាយ តាម៉ុក ប្រកាសថា មិនមានការចាំបាច់ឲ្យមានទីផ្សារ ឬទីក្រុង ហើយប្រជាជននៅទីក្រុងទាំងអស់ ត្រូវទៅទីជនបទ ដើម្បីកសាងសេដ្ឋកិច្ចជនបទ។

[០៩:៥១:០៣]

ឌុច បានពន្យល់ថា គោលបំណងរបស់បក្សកុម្មុយនីស្ត គឺត្រូវប្រែក្លាយប្រទេសទាំងមូលឲ្យទៅជាប្រទេសរបស់កសិករ លុបបំបាត់ឯកជនភាវូបនីយកម្ម និងដើម្បីបង្ខំអ្នកបច្ចេកទេស ឲ្យធ្វើស្រែចម្ការ ដើម្បីឲ្យពួកគេរស់នៅស្មើភាពគ្នា ហើយពឹងផ្អែកលើកសិករ។

ឯកសារកាលពីសម័យនោះឲ្យដឹងថា ការអប់រំកែប្រែមិនអាចធ្វើទៅបានក្នុងទ្រង់ទ្រាយធំឡើយ ហេតុដូច្នេះ ជាការចាំបាច់នឹងធ្វើការជម្លៀសប្រជាជនទៅតាមទីជនបទ ដើម្បីបញ្ឈប់ការចម្លងមនោគមន៍វិជ្ជា ដែលមិនអាចគ្រប់គ្រងបានក្នុងជួរបដិវត្តន៍ ហើយដើម្បីចូលរួមនៅក្នុងចលនាបង្កបង្កើនផល និងចូលរួមចំណែកការពារ និងកសាងប្រទេស។

កថាខណ្ឌ២៤៩៖ ជាចុងក្រោយ ទាក់ទងនឹងបញ្ហាសន្តិសុខ នួន ជា បាននិយាយថា ជាការចាំបាច់ក្នុងការផ្លាស់ទីលំនៅប្រជាជនចេញពីភ្នំពេញ ដើម្បីសម្រួលដល់ការការពារប្រទេសតាមបែបយោធា ដែលប្រឈមមុខនឹងប្រទេសវៀតណាម និងការពារប្រជាជនពីសង្គ្រាម។ អៀង សារី បានលើកឡើងពីឯកសារសម្ងាត់មួយរបស់ សេ.អ៊ី.អា ពាក់ព័ន្ធនឹងផែនការជ្រៀតចូលទីក្រុង។ ខៀវ សំផន បានលើកឡើងពីតម្រូវការក្នុងការធ្វើឲ្យប្រទេសខ្លាំង ដើម្បីវាយខ្នាំង។ តាមឯកសារបក្សកុម្មុយនីស្តកម្ពុជា បានឲ្យ

ដឹងថា ប្រសិនបើប្រជាជនមិនបានចាកចេញពីទីក្រុងនានាទេ ខ្មាំងអាចមានលទ្ធភាពបើកការវាយប្រហារដ៏ភ្ញាក់ផ្អើលពីក្រោយខ្នង។

[០៩:៥២:៤៥]

<u>ការរៀបចំផែនការ</u>

កថាខណ្ឌ២៥០៖ ចាប់តាំងពីមុនឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តគោលនយោបាយជម្លៀសប្រជាជនពីទីក្រុងនានា ដែលស្ថិតនៅក្រោមការត្រួតត្រារបស់ពួកគេ។ ប្រជាជនត្រូវបានផ្លាស់ទីលំនៅមួយផ្នែក ឬទាំងស្រុង ពីរួមខេត្តស្ទឹងត្រែង ខេត្តក្រចេះ ស្រុកបាណន់ និងឧដុង្គ។

កថាខណ្ឌ២៥១៖ មានសក្ខីកម្មខ្លះបង្ហាញថា ការសម្រេចចិត្តផ្លាស់ទីលំនៅប្រជាជនចេញពីភ្នំពេញ ប្រហែលជាធ្វើឡើងក្នុងខែកុម្ភៈ ឆ្នាំ១៩៧៥ ហើយគឺជាផែនការដែលបានគិតទុកជាមុនរបស់មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា។ អតីតកម្មាភិបាលភូមិភាគបូព៌ាមួយរូបបញ្ជាក់ថា ការសម្រេចនេះ បានបន្តធ្វើតាមបញ្ជារបស់ ប៉ុល ពត នៅខែកុម្ភៈ ឆ្នាំ១៩៧៥ ឲ្យគ្រប់ស្រុក និងគ្រប់តំបន់ត្រូវប្រុងប្រៀបរៀបចំសង់លំ -- សង់ទីលំនៅដើម្បីទទួលប្រជាជនពីភ្នំពេញ។

[០៩:៥៣:៥៥]

កថាខណ្ឌ២៥២៖ សាក្សីមួយរូបបានរៀបរាប់ថា នៅដើមខែមេសា ឆ្នាំ១៩៧៥ មានការប្រជុំមួយបានធ្វើឡើងនៅមន្ទីររបស់ ប៉ុល ពត នៅភូមិតាំងពោន ស្រុកកំពង់ត្រឡាចលើ ខេត្តកំពង់ឆ្នាំង ដែលផ្តោតជាសំខាន់ទៅលើផែនការជម្លៀសប្រជាជនចេញពីភ្នំពេញ។ សាក្សីរូបនេះបញ្ជាក់ថា ទោះបីជាមិនមានការកត់ត្រាជាផ្លូវការពីការប្រជុំនោះក៏ដោយ ទាំង នួន ជា និង ខៀវ សំផន បានចូលរួមនៅក្នុងការប្រជុំនោះ ហើយបានកត់ត្រារៀងៗខ្លួន។ យោងតាមសាក្សីនេះ មេបញ្ជាការនានាត្រូវបានប្រាប់ឲ្យរៀបចំការប្រជុំ នៅពេលដែលគេត្រឡប់ទៅតំបន់របស់គេវិញ ហើយធ្វើផែនការដើម្បីជម្លៀសប្រជាជននៅក្នុងទីក្រុង ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់គេ។ ក្រោយមកព័ត៌មាននេះត្រូវបានបោះផ្សាយនៅក្នុងទង់បដិវត្ត និងទង់រណសិរ្ស ហើយបានចែកទៅឲ្យគ្រប់សមាជិកបក្សទាំងអស់ ទោះបីជាគ្មានដាមស្នាម អំពីការបោះពុម្ពទាំងនេះក៏ដោយ។

[០៩:៥៥:០៣]

កថាខណ្ឌ២៥៣៖ សាក្សីម្នាក់ទៀតនិយាយអំពីការប្រជុំសម្របសម្រួលមួយនៅមុនថ្ងៃទី១៧ខែមេសា ឆ្នាំ១៩៧៥ ដែលនៅពេលនោះ មេបញ្ជាការកងទ័ពបក្សកុម្មុយនីស្តកម្ពុជាទាំងអស់នៃអង្គភាព

របស់គាត់ (កងពលធំលេខ១ នៃភូមិភាគឧត្តរនៅពេលនោះ ក្រោយមកជាកងពលធំលេខ៣១០របស់មជ្ឈិម) ត្រូវបាន១អញ្ជើញឲ្យចូលរួមប្រជុំ ដូចដែលបានរាយការណ៍ទៅឲ្យសាក្សីរូបនេះដោយឈ្មោះ (លុប) ដែលជាមេបញ្ជាការកងវរសេនាតូចរបស់គាត់។ សាក្សីម្នាក់ទៀត និយាយថាប្រមាណ១ខែមុនពេលចូលមកទីក្រុងភ្នំពេញ ការប្រជុំមួយត្រូវបានធ្វើឡើងនៅភ្នំសរ (បញ្ជាការដ្ឋានកងទ័ពបក្សកុម្មុយនីស្តកម្ពុជាតំបន់ខេត្តកំពត)។ ប្រធានសេនាធិការឈ្មោះ (លុប) តំបន់៣៥នៃភូមិភាគនិរតី បានធ្វើជាប្រធានអង្គប្រជុំដែលនៅក្នុងនោះលេខាភូមិភាគនិរតីឈ្មោះ តាម៉ុក បាននិយាយថា "មិនចាំបាច់នឹងមានផ្សារ ឬទីក្រុងឡើយ ហើយថា ប្រជាជនទាំងអស់ត្រូវតែជម្លៀសចេញពីទីក្រុងនានាទៅតំបន់ជនបទដើម្បីកសាងសេដ្ឋកិច្ចជនបទ ក្នុងរយៈពេល២ថ្ងៃ បន្ទាប់ពីកាន់កាប់ទីក្រុង"។

[០៩:៥៦:៣០]

កថាខណ្ឌ២៥៤៖ មានភស្តុតាងថា សំ ប៊ិត អតីតមេបញ្ជាការកងពលធំលេខ២ នៃភូមិភាគនិរតីបានចូលរួមការប្រជុំជាមួយនឹងសមាជិកបក្សកុម្មុយនីស្តកម្ពុជាជាន់ខ្ពស់ ដែលនៅក្នុងការប្រជុំនោះមាននិយាយថា "ប្រជាជនភ្នំពេញត្រូវតែជម្លៀសចេញ ដើម្បីស្វែងរកសមាសភាព លន់ នល់"។ បន្ទាប់មកព័ត៌មាននេះត្រូវបានផ្សព្វផ្សាយចេញពីការប្រជុំនេះទៅថ្នាក់កងវរសេនាធំ និងកងវរសេនាតូច។

កថាខណ្ឌ២៥៥៖ អតីតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាថ្នាក់ទាប ក៏និយាយដែរថា ពួកគេត្រូវបានប្រាប់ជាមុន អំពីផែនការផ្លាស់ទីលំនៅប្រជាជនចេញពីភ្នំពេញ។ កងទ័ពបក្សកុម្មុយនីសកម្ពុជាមួយរូបបានឮគេនិយាយថា អង្គការមានផែនការជម្លៀសប្រជាជនទៅកាន់ស្រុកកំណើតរបស់ពួកគេវិញ។ សាក្សីម្នាក់ទៀតនិយាយថា លេខាកងពលធំលេខ១ ភូមិភាគឧត្តរ ឈ្មោះ (លុប) បានដាក់បញ្ជាក់ដល់ក្រុមរបស់គាត់ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនប្រហែល៣ថ្ងៃ មុនរំដោះ។ រីឯអតីតកងទ័ពម្នាក់ទៀត ក៏បាននិយាយដែរថា គាត់បានទទួលព័ត៌មាននេះពីឈ្មោះ (លុប) ៣ថ្ងៃមុនការវាយចូលទីក្រុងភ្នំពេញ។

[០៩:៥៧:៥៦]

កថាខណ្ឌ២៥៦៖ ទោះបីជាយ៉ាងណាក៏ដោយ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាថ្នាក់ក្រោមផ្សេងទៀត បាននិយាយថា មិនមានការណែនាំមុនព្រឹត្តិការណ៍ទាំងនោះទេ។ លើសពីនេះទៀត កងទ័ពមួយចំនួនបានគូសបញ្ជាក់ថា ខ្លួនគ្រាន់តែបានទទួលបញ្ជាឲ្យផ្លាស់ទីលំនៅប្រជាជនតែប៉ុណ្ណោះ បន្ទាប់ពីបានចូលដល់ភ្នំពេញបានប៉ុន្មានថ្ងៃ។

កថាខណ្ឌ២៥៧៖ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាក៏បានទទួលការណែនាំពីថ្នាក់លើរបស់ខ្លួនឲ្យផ្លាស់ទីលំនៅប្រជាជនចេញពីភ្នំពេញស្របតាមខ្សែរយៈបញ្ជាផ្នែកយោធា។ កងវរសេនាធំលេខ២ (ក្រោយមកលេខ៧២៣) នៃកងពលធំលេខ៣១០ (កងពលធំលេខ១នៃភូមិភាគឧត្តរ) បានទទួលបញ្ជាឲ្យជម្លៀសប្រជាជនពីមេបញ្ជាការឈ្មោះ (លុប) និងមេបញ្ជាការឈ្មោះ (លុប)។ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាក៏បាននិយាយអំពីថ្នាក់លើ ឬអង្គការ ថាបានចេញបញ្ជាឲ្យប្រជាជនចាកចេញពីទីក្រុង។

កថាខណ្ឌ២៥៨៖ ពាក់ព័ន្ធនឹងការចូលរួមរបស់ជនត្រូវចោទនៅក្នុងដំណើរការធ្វើសេចក្តីសម្រេច នួន ជា បានចូលរួមក្នុងការរៀបចំផែនការកងទ័ពបក្សកុម្មុយនីស្តកម្ពុជាទាក់ទងនឹងការវាយប្រហារលើទីក្រុងភ្នំពេញ ដូចដែលបានបង្ហាញជាសក្ខីកម្មអំពីវត្តមានរបស់គាត់ នៅក្នុងការប្រជុំជាមួយមេដឹកនាំយោធា។ នៅក្នុងសេចក្តីថ្លែងការណ៍មួយទៅកាន់អ្នកសារព័ត៌មានមួយរូប នួន ជា បានថ្លែងថា ការសម្រេចជម្លៀសប្រជាជនពីទីក្រុងភ្នំពេញនានាត្រូវបានធ្វើឡើងដោយគណៈមជ្ឈិមបក្ស។ កាលហ្នឹងផ្តើមគំនិតម្នាក់បន្តិចៗ។ ផ្សំពីនេះពីនោះ។

[០៩:៥៩:៥៨]

នួន ជា បានថ្លែងទៀតថា “ដូច្នេះទៅ -- ដូច្នេះទៅវាយយកអាបន្ទាយខាងក្នុងៗយក។ ដល់អ៊ីចឹង ១៧ មេសា ១៩៧៥ រំដោះ។ កងទ័ពចូលរំដោះយកភ្នំពេញទាំងស្រុង”។ អៀង សារី បាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ មួយនៅក្នុងឆ្នាំ១៩៩៦ ថា “ការសម្រេចចិត្តត្រូវបានធ្វើឡើងដោយ ប៉ុល ពត ដោយគាត់មិនបានដឹង”។ ប៉ុន្តែគាត់បានគូសបញ្ជាក់ផងដែរថា គាត់បានព្យាយាមរារាំង ប៉ុល ពត ដោយបាននិយាយថា “ក្នុងឆ្នាំ១៩៧៤ ខ្ញុំបាននិយាយជាមួយ ប៉ុល ពត ថា យកមនុស្សចេញពីស្ទឹងត្រែង និងក្រចេះ គឺការងាយ ពីព្រោះមិនមានប្រជាជនច្រើន។ ប៉ុន្តែជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺមិនមែនជាការងាយទេ គ្រប់យ៉ាងត្រូវតែរៀបចំឲ្យបានសព្វគ្រប់ ពីព្រោះមានប្រជាជនរាប់លាននាក់”។ អៀង សារី ក៏បាននិយាយដែរថា “រាល់សេចក្តីសម្រេចទាំងអស់ត្រូវធ្វើឡើងដោយគណៈកម្មាធិការបួនរូបនោះឯង រួមទាំងរូបគាត់ និង នួន ជា”។ ការជម្លៀសប្រជាជនចេញពីទីក្រុងនានាមិនពាក់ព័ន្ធនឹងការចូលរួមធ្វើសេចក្តីសម្រេចរបស់ខ្ញុំទេ។ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានចុះពីយន្តហោះមកពីទីក្រុងប៉េកាំង។ ខ្ញុំបានឃើញទីក្រុងក្លាយជាទីរហោស្ថានរួចទៅហើយ។ យោងតាម អៀង សារី ការសម្រេចដាច់ណាត់ក្នុងការជម្លៀសភ្នំពេញត្រូវបានធ្វើឡើងចុងខែមីនា ឬដើមខែមេសា ឆ្នាំ១៩៧៥។

[១០:០១:៤០]

នៅក្នុងបទសម្ភាសន៍តាមវិទ្យុមួយ ខៀវ សំផន បាននិយាយថា "គាត់បានប្រឆាំងនឹងការជម្លៀស ប៉ុន្តែគាត់ថា ការជម្លៀសនោះត្រូវតែធ្វើដើម្បីជាប្រយោជន៍ដល់អ្នកទីក្រុង"។ ហើយនៅក្នុងការសម្ភាសមួយទៀតគាត់ថា "វិធានការនេះត្រូវបានគិតគូរ និងរៀបចំផែនការដោយគណៈកម្មាធិការអចិន្ត្រៃយ៍"។ ចំណែកឯ អៀង ធីរិទ្ធ បាននិយាយនៅក្នុងកិច្ចសម្ភាសជាមួយ(លុប) ក្នុងឆ្នាំ១៩៨០ ថា "គាត់មិនបានដឹងពេលណា ដែលការសម្រេចចិត្តជម្លៀសប្រជាជនភ្នំពេញត្រូវបានធ្វើទេ ពីព្រោះគាត់នៅកន្លែងផ្សេងនៅពេលនោះ"។

កថាខណ្ឌ២៥៩៖ ទាក់ទិននឹងវត្តមានរបស់ជនត្រូវចោទនៅភ្នំពេញ នួន ជា បានចាកចេញពីអតីតមូលដ្ឋានកងទ័ពបក្សកុម្មុយនីស្តកម្ពុជានៅថ្ងៃទី១៧ ខែមេសា ហើយបានមកដល់ភ្នំពេញនៅប្រហែលថ្ងៃទី២០ ខែមេសា។ អៀង សារី បាននិយាយថា "គាត់បានមកដល់ភ្នំពេញថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៥ ពីប៉េកាំង"។ អៀង ធីរិទ្ធ បាននិយាយថា "គាត់បានមកដល់ភ្នំពេញអំឡុងខែមិថុនា ប៉ុន្តែគាត់បានដឹងអំពីការជម្លៀសនៅមុនពេលគាត់មកដល់ភ្នំពេញ"។ ខៀវ សំផន បានថ្លែងថា "គាត់បានចូលភ្នំពេញពី៧ ទៅ ១០ថ្ងៃ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥"។

[១០:០៣:១១]

កថាខណ្ឌ២៦០៖ ផ្អែកលើភស្តុតាងខាងលើមកនេះ ការសម្រេចផ្លាស់ទីលំនៅប្រជាជនពីភ្នំពេញត្រូវបានធ្វើឡើងជាសំខាន់ដោយប៉ុល ពត ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៥ ជាមួយនឹងផែនការដែលត្រូវបានផ្សព្វផ្សាយរួចហើយ ដើម្បីរៀបចំទទួលប្រជាជនពីភ្នំពេញក្នុងខែជាមួយគ្នានោះដែរ។ ការចូលពាក់ព័ន្ធរបស់សមាជិកមជ្ឈិមបក្សទំនងត្រូវបានធ្វើឡើងក្រោមរូបភាពជាការប្រជុំមួយចំនួននៅចុងខែមីនា ឬដើមខែមេសា ឆ្នាំ១៩៧៥ ដោយមានការចូលរួមពី នួន ជា, ខៀវ សំផន និងអៀង សារី។ ទោះបីជា អៀង សារី នៅក្រៅប្រទេសនាពេលនោះ មានភស្តុតាងបង្ហាញថា អៀង សារី បានទទួលការទាក់ទងអំពីការសម្រេចនានា ហើយថា អៀង សារី បានពិភាក្សាគ្នារួចហើយ អំពីបញ្ហានេះជាមួយនឹង ប៉ុល ពត ក្នុងឆ្នាំ១៩៧៤។ ខណៈនោះក៏មានការប្រជុំជាមួយនឹងកម្មាភិបាលថ្នាក់ក្រោម ដើម្បីផ្សព្វផ្សាយការសម្រេចនេះ ហើយកងទ័ពបក្សកុម្មុយនីស្តកម្ពុជាមួយចំនួនបានទទួលបញ្ជាជាមុន មុនការវាយប្រហារលើទីក្រុងភ្នំពេញ។ ទោះបីជាអ្នកដទៃទៀតមិនត្រូវបានប្រាប់ឲ្យដឹង មុនពេលទទួលបញ្ជាឲ្យផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងក៏ដោយ។

[១០:០៥:៣៥]

<u>ការផ្លាស់ទីលំនៅប្រជាជនពីភូមិភាគឧត្តរចាស់ កណ្តាល និរតី បស្ចិម និងបូព៌ា</u>

<u>ពេលវេលា និងទីកន្លែង</u>

កថាខណ្ឌ២៦២៖ អំឡុងខែកញ្ញា ឆ្នាំ១៩៧៥ និងបន្តដល់ឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ ប្រជាជនមួយចំនួនធំត្រូវបានផ្លាស់ទីលំនៅពីផ្នែកកណ្តាល និងផ្នែកនិរតីនៃប្រទេស (បើយោងតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលនៃបក្សកុម្មុយនីស្តកម្ពុជា) រួមមាន ភូមិកណ្តាល និងភូមិភាគនិរតី និងផ្នែកខ្លះនៃភូមបស្ចិម និងភូមិភាគបូព៌ា ដែលគេស្គាល់ថា មានខេត្ត៖ កណ្តាល កំពង់ធំ តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង និងកំពង់ចាម។ ភាគច្រើនក្នុងចំណោមប្រជាជនទាំងនោះ ត្រូវបានបញ្ជូនទៅតំបន់ដែលបក្សកុម្មុយនីស្តកម្ពុជា ហៅថា តំបន់១០៦ (តំបន់សៀមរាប) តំបន់១០៣ (ព្រះវិហារ) និងភូមិភាគពាយ័ព្យ (ដែលរួមមានទីតាំង នៅតាមខេត្តបច្ចុប្បន្ននេះដូចជា៖ ខេត្តបាត់ដំបង, ពោធិ៍សាត់ និងបន្ទាយមានជ័យ) ឬត្រូវបានបញ្ជូនទៅភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) (ខេត្តកំពង់ធំ និងផ្នែកខ្លះនៃខេត្តកំពង់ចាមបច្ចុប្បន្ន)។

[១០:០៦:១១]

កថាខណ្ឌ២៦៣៖ លើសពីនេះទៀត សក្ខីកម្មខ្លះបង្ហាញអំពីការផ្លាស់ទីលំនៅ នៅក្នុងអំឡុងពេលជាមួយគ្នានេះដែរ ដូចជា ពីភូមិភាគបូព៌ា ឬនៅក្នុងភូមិភាគបូព៌ា (ខេត្តព្រៃវែង និងស្វាយរៀង) ទៅកាន់ខេត្តក្រចេះ (តំបន់៥០៥) នៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ឬនៅក្នុងខេត្តបាត់ដំបង។ សាក្សីភាគច្រើននិយាយថា ប្រជាជនត្រូវបានផ្លាស់ទីលំនៅជាច្រើនលើក មុននឹងទៅដល់គោលដៅចុងក្រោយរបស់ខ្លួន។ ប្រជាជនទាំងនោះ ជាពិសេសគឺប្រជាជនមួយចំនួនដែលត្រូវបានជម្លៀសពីដំបូងមកពីភ្នំពេញផងដែរ។

<u>ប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅ</u>

កថាខណ្ឌ២៦៤៖ មានការលំបាកនឹងធ្វើការប៉ាន់ស្មានអំពីចំនួនប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅពីផ្នែកនិរតី ឬផ្នែកកណ្តាលនៃប្រទេសកម្ពុជា ទៅកាន់ភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ រវាងចុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦។ កំណត់ហេតុមួយនៃគណៈអចិន្ត្រៃយ៍ នាខែសីហា ឆ្នាំ១៩៧៥ បានលើកឡើងអំពីតម្រូវការបន្ថែមប្រជាជន ៤០០.០០០ ឬ ៥០០.០០០នាក់ ទៅលើចំនួនប្រជាជនដែលមានស្រាប់នៅភូមិភាគពាយ័ព្យ។ រួមទាំងការបញ្ជូនផងដែរ នូវចំនួនប្រជាជនដែលមិនមានកំណត់ចំនួនច្បាស់លាស់

ទៅភូមិភាគឧត្តរនៅពេលនោះ។

យោងតាមឯកសារមួយរបស់បក្សកុម្មុយនីស្តកម្ពុជា នាខែកញ្ញា ឆ្នាំ១៩៧៥ ប្រជាជនចំនួន ៥០០.០០០នាក់ នឹងត្រូវបានផ្លាស់ទីលំនៅ ទៅភូមិភាគពាយ័ព្យ ហើយចំនួន ២០.០០០នាក់ ទៅខេត្តព្រះវិហារ និងអ្នកផ្សេងទៀត ទៅខេត្តកំពង់ធំ ក្នុងភូមិភាគឧត្តរ និងតំបន់មួយចំនួននៃភូមិភាគបូព៌ា។ ទូរលេខមួយនៅខែវិច្ឆិកា ឆ្នាំ១៩៧៥ "ទូរលេខ១៥" បង្ហាញថា ប្រជាជនចំនួន ៥០.០០០នាក់ នឹងត្រូវបានផ្លាស់ទីលំនៅពីភូមិភាគបូព៌ា និងប្រជាជនចាមចំនួន ១០០.០០០នាក់ នៅសល់ក្នុងភូមិភាគនេះ។

[១០:០៨:២៥]

យោងតាមសក្ខីកម្មរបស់អតីតកម្មករផ្លូវរថភ្លើងបញ្ជាក់ថា ប្រជាជនជាច្រើនពាន់នាក់ទំនងជាត្រូវបានបញ្ជូនតាមរថភ្លើងដោយកាត់តាមភ្នំពេញ ឆ្ពោះទៅគោលដៅនានា ក្នុងខេត្តពោធិ៍សាត់ និងបាត់ដំបង នៅក្នុងភូមិភាគពាយ័ព្យ។

កថាខណ្ឌ២៦៥៖ តាមសាក្សីភាគច្រើន (ដែលខ្លះជាអតីតអ្នកត្រូវបានផ្លាស់ទីលំនៅ) បានឲ្យដឹងថា អ្នកដែលត្រូវបានផ្លាស់ទីលំនៅរួមមាន កុមារ ស្ត្រី មនុស្សចាស់ គ្រួសារទាំងមូល។ ប្រជាជនមួយចំនួនមានជាប់ទាក់ទងទៅនឹងរបប លន់ នល់។ ប្រជាជនខ្លះទៀត ត្រូវបានចាត់ទុកថាជា "ប្រជាជនថ្មី" ដូចជា ប្រជាជនដែលត្រូវបានជម្លៀសពីដំបូងចេញពីភ្នំពេញជាដើម។ សាក្សីមួយចំនួននិយាយថា មានតែ "ប្រជាជនថ្មី" តែប៉ុណ្ណោះដែលត្រូវបានប្រាប់ឲ្យចាកចេញ។ សាក្សីម្នាក់ ក៏បាននិយាយអំពីការផ្លាស់ទីលំនៅរបស់ជនជាតិភាគតិចកម្ពុជាក្រោម និងប្រជាជនចិនផងដែរ។

[១០:០៩:៣៥]

កថាខណ្ឌ២៦៦៖ ជនជាតិចាមមួយចំនួន ក៏ស្ថិតក្នុងចំណោមមនុស្សដែលត្រូវបានផ្លាស់ទីលំនៅដែរ ដោយការផ្លាស់ទីលំនៅប្រជាជនចាមទាំងនេះ កើតឡើងនៅចុងឆ្នាំ១៩៧៥ បន្ទាប់ពីមានការបះបោររបស់ជនជាតិចាម នៃទីតាំងពីរកន្លែងក្នុងភូមិភាគបូព៌ា។ ជនជាតិចាមជាច្រើន ត្រូវបានផ្លាស់ទីលំនៅពីភូមិកំណើតរបស់ខ្លួន នៅក្នុងខេត្តកំពង់ចាម ហើយត្រូវបានបញ្ជូនទៅភូមិផ្សេងៗទៀត នៅក្នុងខេត្តដដែលនេះ។ អ្នកខ្លះទៀត ត្រូវបានបញ្ជូនទៅឆ្ងាយទៅភូមិនានាទូទាំងខេត្តក្រចេះ កំពង់ធំ និងបាត់ដំបង។ ទូរលេខ១៥ និងភស្តុតាងផ្សេងទៀតដែលបានបង្ហាញទុកបានឲ្យដឹងថា ការសម្រេចមួយត្រូវបានធ្វើឡើងដោយគណៈកម្មាធិការមជ្ឈិម ហើយក្រោយមកត្រូវបានអនុវត្តដើម្បីផ្លាស់ទីលំនៅប្រជាជនចាមរាប់ពាន់នាក់ទៅភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ។

<u>មធ្យោបាយ និងវិធីសាស្ត្រនៃការផ្លាស់ទីលំនៅប្រជាជន</u>

កថាខណ្ឌ២៦៧៖ ប្រជាជនត្រូវបានផ្លាស់កន្លែងតាមរថយន្តយោធា ឬរថយន្តស៊ីវិល រថភ្លើង ទូក រទេះគោ ត្រាក់ទ័រ និង/ឬដោយថ្មើរជើង។ នៅក្នុងករណីជាច្រើនការធ្វើដំណើរត្រូវធ្វើឡើងតាមមធ្យោបាយច្រើនរួមគ្នាអាស្រ័យតាមគោលដៅ។ សាក្សីភាគច្រើនមានអារម្មណ៍ទទួលរងការគំរាមកំហែង ឬត្រូវបានបង្ខំឲ្យចាកចេញ។ ប្រជាជនដែលបានគិតថា ពួកគេមានជម្រើសក៏នៅតែត្រូវចាកចេញដែរ ដោយភ័យខ្លាចថានឹងត្រូវចាប់ខ្លួន ឬសម្លាប់។ មានសក្ខីកម្មបង្ហាញថាប្រជាជនមួយចំនួនត្រូវបានចង ឬត្រូវបានភ្ជង់នឹងកាំភ្លើង ខណៈដែលអ្នកដទៃទៀតបាននិយាយថា ពួកគេមិនត្រូវបានចង ឬទទួលការធ្វើបាប ឬការវាយដំទេ។ សាក្សីមួយចំនួននិយាយថា ពួកគេត្រូវបានអនុញ្ញាតឲ្យវេចរបស់របរមួយចំនួន ឬចំណីអាហារបន្តិចបន្តួចមុននឹងចាកចេញ។

[១០:១១:៣៧]

កថាខណ្ឌ២៦៨៖ ប្រជាជនដែលត្រូវបានផ្លាស់កន្លែង រួមទាំងជនជាតិចាមត្រូវបានចាត់តាំងជាក្រុម។ ប្រជាជនមួយចំនួនត្រូវបានបំបែកពីគ្នានៅពេលចាកចេញ ឬអំឡុងពេលធ្វើដំណើរ ឬពេលមកដល់។ អតីតកម្មាភិបាលមូលដ្ឋានមួយរូបនិយាយថា "យើងមិនមានគោលការណ៍ហាមមិនឲ្យប្រជាជនថ្មីរស់នៅជាមួយសាច់ញាតិដែលជាអ្នកមូលដ្ឋាននោះទេ"។ សាក្សីមួយចំនួនបានរៀបរាប់ថា ប្រជាជនចាមត្រូវបានបំបែកទៅតាមភូមិខ្មែរ ដោយមានតែប្រជាជនចាមមួយចំនួនតូចប៉ុណ្ណោះត្រូវបានអនុញ្ញាតឲ្យរស់នៅតាមភូមិនីមួយៗ។ សក្ខីកម្មនានាបង្ហាញថា ជនជាតិចាមជា បុរស ស្ត្រី និងកុមារ ត្រូវបានបំបែកពីគ្នា ហើយផ្លាស់ទីលំនៅទៅទីផ្សេងពីគ្នា។ សាក្សីមួយចំនួននិយាយថា ពួកគេនៅជាមួយគ្រួសាររបស់ខ្លួនគ្រប់ពេលនៃការផ្លាស់ទីលំនៅ ឬក៏ថាពួកគេត្រូវបានអនុញ្ញាតឲ្យទៅជួបគ្រួសារវិញនាពេលក្រោយមក។ សាក្សីមួយចំនួននិយាយថា ខណៈពេលដែលប្រជាជនចាមភាគច្រើនត្រូវបានផ្លាស់ទីលំនៅប្រជាជនចាមមួយចំនួនតូចត្រូវបានតម្រូវឲ្យរស់នៅក្នុងភូមិរបស់ខ្លួនដដែល។ សាក្សីបីរូបនិយាយ -- បាននិយាយថា ពួកគេត្រូវបានតម្រូវឲ្យរស់នៅខាងក្រោមផ្ទះប្រជាជនខ្មែរ។ សាក្សីពីររូបនិយាយថា មនុស្សចាស់ជាជនជាតិចាម និងមេដឹកនាំសាសនានៅក្នុងភូមិរបស់ខ្លួន ត្រូវបានចាប់ខ្លួន និងសម្លាប់មុនពេលការផ្លាស់ទីលំនៅរបស់ប្រជាជនបានចាប់ផ្តើម។

[១០:១៣:១៦]

កថាខណ្ឌ២៦៩៖ ការធ្វើដំណើរអាចចំណាយពេល១ថ្ងៃ ឬច្រើនថ្ងៃ ដោយមានឈប់នៅតាម

ផ្លូវ។ ប្រជាជនអាចសម្រាក១ភ្លែត ១យប់ ឬ២-៣ថ្ងៃ ឬដល់ទៅ១សប្តាហ៍អាស្រ័យតាមចម្ងាយ និងការធ្វើដំណើរ។ ប្រជាជនធ្វើដំណើរទាំងពេលថ្ងៃ និង/ឬពេលយប់ ហើយប្រជាជនភាគច្រើនស្ថិតក្នុងសភាពលំបាកផ្នែករូបកាយយ៉ាងខ្លាំង។ សាក្សីជាច្រើនបង្ហាញថា ប្រជាជនត្រូវបានដាក់បញ្ជៀតចូលទៅក្នុងទូររថភ្លើង ឡាន ឬទូកដ៏ចង្អៀត។ ប្រជាជនបានទទួលរបស់តែបន្តិចបន្តួចសម្រាប់ហូប និងផឹកទឹកតែប៉ុណ្ណោះ អំឡុងពេលផ្លាស់ទីលំនៅ ឬពេលដល់គោលដៅ ខណៈដែលសាក្សីមួយរូបបាននិយាយថា កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានឲ្យនំប៉័ងមុនពេលប្រជាជនត្រូវឲ្យចុះទូក។ ថ្នាំពេទ្យក៏មានការខ្វះខាតដែរ។ ប្រជាជនបានស្លាប់មុនពេលធ្វើដំណើរ ឬនៅតាមផ្លូវ ឬបន្ទាប់ពីការធ្វើដំណើរដោយសារភាពអត់ឃ្លាន ដោយសារតែប្រជាជនទាំងនោះចាស់ពេក ឬខ្សោយខ្លាំងពេក ឬក៏ដោយសារជំងឺ។ សាក្សីនានាក៏បាននិយាយដែរថា ការចាប់ខ្លួនបានកើតឡើងផងដែរនៅអំឡុងពេលនៃការផ្លាស់ទីលំនៅទាំងនេះ។

[១០:១៤:៤២]

កថាខណ្ឌ២៧០៖ ប្រជាជនមួយចំនួនបានបាត់ខ្លួននៅអំឡុងនៃការផ្លាស់លំនៅនេះ។ សាក្សីម្នាក់ពន្យល់ថា គាត់ត្រូវបានគេប្រាប់នៅក្នុងអង្គប្រជុំមួយថា អ្នកដែលមិនព្រមចាកចេញនឹងត្រូវគេបញ្ជូនទៅអប់រំ ហើយទាំងនោះមិនដែលឃើញត្រឡប់មកវិញឡើយ។

កថាខណ្ឌ២៧១៖ មានសក្ខីកម្មស៊ីសង្វាក់គ្នាបង្ហាញថា កម្មាភិបាលដឹកនាំបក្សនៅតាមមូលដ្ឋានជាអ្នកទទួលបន្ទុកអនុវត្តការផ្លាស់ទីលំនៅ ទាំងនៅដំណាក់កាលចាកចេញ និងដំណាក់កាលមកដល់។ នៅពេលចាប់ផ្តើមចាកចេញ កម្មាភិបាលទាំងនោះបានទទួលការណែនាំពីថ្នាក់លើ ទោះបីជាយ៉ាងណាមានសាក្សីមួយរូបនិយាយថា ការសម្រេចជ្រើសរើសអ្នកភូមិ ដែលត្រូវផ្លាស់ទីលំនៅ ត្រូវបានធ្វើឡើងដោយសម្ងាត់ ដោយប្រធានកងអនុសេនាតូច។ ប្រជាជនដែលសួរនាំច្រើនអាចត្រូវបានគំរាម។ យោងតាមសាក្សីមួយចំនួន កម្មាភិបាលបក្សនៅតាមមូលដ្ឋាន បានទទួលនូវបញ្ជីឈ្មោះ ហើយបានរៀបចំកិច្ចប្រជុំដើម្បីហៅឈ្មោះទាំងនោះ ដោយសំឡេងខ្លាំងៗ និងដើម្បីកំណត់អំពីរបៀបដឹកជញ្ជូនប្រជាជនផងដែរ។

[១០:១៦:០២]

កថាខណ្ឌ២៧២៖ កងទ័ព កងឈ្លប ឬកងសន្តិសុខ បានឃ្លាំមើលការផ្លាស់ទីលំនៅទាំងនេះ។ សាក្សីភាគច្រើនបានលើកឡើងអំពីវត្តមានរបស់កងកម្លាំងទាំងនេះ នៅគ្រប់ដំណាក់កាលនៃការផ្លាស់ទីលំនៅ ដោយឃ្លាំមើលតាំងពីពេលចាប់ផ្តើមចេញដំណើរ អំឡុងពេលធ្វើដំណើរ ដើម្បីយាមប្រជាជននៅ

លើទូក នៅតាមរថភ្លើង -- នៅតាមរថយន្ត តាមរថភ្លើង ឬរទេះគោ និងរហូតដល់គោលដៅ។ ផ្ទុយទៅវិញ សាក្សីពីរបីនាក់បានប្រាប់ថា ពួកគេមិនត្រូវបានអមដំណើរជានិច្ចកាលដោយកម្លាំងប្រដាប់អាវុធឡើយ។

កថាខណ្ឌ២៧៣៖ នៅខេត្តបាត់ដំបង ឬពោធិ៍សាត់ អ្នកដែលត្រូវបានផ្លាស់ទីលំនៅភាគច្រើនបានមកដល់តាមរថភ្លើង។ មានអង្គភាពចាត់តាំងនៃបណ្តាញផ្លូវរថភ្លើងច្បាស់លាស់តាមឋានានុក្រមដោយមានអង្គភាពរថភ្លើងនៅភ្នំពេញជាអ្នកមើលការខុសត្រូវពីលើ។ អតីតកម្មករផ្លូវរថភ្លើងមួយរូបនៅខេត្តបាត់ដំបងប្រាប់ថា រថភ្លើងទាំងនោះត្រូវបានអមដោយកងទ័ពប្រដាប់អាវុធ ហើយថាកងឈ្លបជាអ្នកទទួលបន្ទុកបន្ទាប់ពីរថភ្លើងបានមកដល់។ តាមការយល់ឃើញរបស់គាត់គឺថា ការដឹកជញ្ជូនទាំងអស់ហ្នឹង រៀបចំដោយថ្នាក់លើ។ អតីតកម្មករផ្លូវរថភ្លើងពីររូបផ្សេងទៀតបានពន្យល់ថា កងទ័ពបីនាក់ជាអ្នកគ្រប់គ្រងបណ្តាញទំនាក់ទំនងរបស់ស្ថានីយរថភ្លើងខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង។

[១០:១៧:៤២]

យោងតាមសាក្សីនានា ដែលបានធ្វើការនៅស្ថានីយរថភ្លើងនៅខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលទទួលបន្ទុកតាមស្ថានីយរថភ្លើង រាយការណ៍ផ្ទាល់ទៅអង្គភាពរថភ្លើងនៅភ្នំពេញ។ លើសពីនេះទៀត សាក្សីមួយរូប ក្នុងចំណោមសាក្សីទាំងនោះពន្យល់ថា ក្នុងនាមជាសមាជិកបក្សកុម្មុយនីស្តមួយរូប កម្មាភិបាលទទួលបន្ទុកនៅស្ថានីយខេត្តពោធិ៍សាត់ បានចូលរួមវគ្គរៀនសូត្រនៅភ្នំពេញ ហើយសាក្សីរូបនេះអះអាងបញ្ជាក់ថា ដូច្នេះ មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាត្រូវបានជូនដំណឹងអំពីការផ្លាស់ទីលំនៅទាំងនេះជាប្រចាំ។

កថាខណ្ឌ២៧៤៖ កម្មាភិបាលដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅមូលដ្ឋាន បានទទួលប្រជាជនដែលផ្លាស់ទីលំនៅ ហើយរៀបចំអ្នកទាំងនោះឲ្យទៅតាមសហករណ៍។ សាក្សីមួយចំនួននិយាយថា កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបានសួរអំពីជីវប្រវត្តិរបស់ពួកគេ ពេលទៅដល់គោលដៅ។

ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបបាននិយាយថា មានពេលមួយ គាត់ត្រូវបានផ្តល់ឱកាសឲ្យជ្រើសរើសសហករណ៍ដែលគាត់ចង់ទៅ ដោយគូសបញ្ជាក់ផងដែរថា ក្រោយមកគាត់ត្រូវបានបញ្ជូនឲ្យទៅរៀនសូត្របន្ទាប់ពីការចាប់ខ្លួនប្តីរបស់គាត់។

[១០:១៩:០៣]

ចំពោះប្រជាជនដែលត្រូវបានបញ្ជូនទៅផ្នែកកណ្តាលនៃប្រទេស ឬទៅខេត្តក្រចេះ សាក្សីដែល

ពាក់ព័ន្ធបានផ្តល់សក្ខីកម្មប្រហាក់ប្រហែលគ្នា។

<u>ការវិលត្រឡប់មកវិញ</u>

កថាខណ្ឌ២៧៥៖ ប្រជាជនភាគច្រើនដែលត្រូវបានផ្លាស់ទីលំនៅ ហើយនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ បានត្រឡប់ទៅផ្ទះឬភូមិកំណើតរបស់ខ្លួនវិញភ្លាមៗតាមដែលពួកគេអាចធ្វើបាន។ សាក្សីមួយចំនួនបានឃើញភូមិពីមុនរបស់ខ្លួនស្ងាត់ជ្រងំ ផ្ទះបាក់បែក និងរណ្តៅសាកសពជាច្រើន។ សក្ខីកម្មទាំងនោះបង្ហាញថា នៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គ្មានករណីដែលគេអនុញ្ញាតឲ្យប្រជាជនត្រឡប់មកភូមិកំណើតរបស់ខ្លួនឡើយ។

[១០:១៩:៥៣]

<u>មូលហេតុដែលលើកឡើងដើម្បីផ្លាស់ទីលំនៅប្រជាជន</u>

កថាខណ្ឌ២៧៦៖ កំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍នាខែសីហា ឆ្នាំ១៩៧៥ បានលើកឡើងអំពីដំណើរទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍ទៅភូមិភាគពាយ័ព្យ។ កំណត់ហេតុនេះបញ្ជាក់អំពីតម្រូវការដើម្បីបង្កើនផលិតកម្មស្រូវនៅក្នុងភូមិភាគពាយ័ព្យទាំងមូលដោយ អង្គការ បានផ្តល់ការណែនាំ ហើយក្នុងនោះមានការណែនាំអំពីបញ្ហាសេដ្ឋកិច្ច និងការបង្កបង្កើនផលដោយឲ្យដឹងថា ភូមិភាគឧត្តរ និងពាយ័ព្យមានលក្ខណៈសម្បត្តិល្អច្រើនជាងគេ មានដូចជា ដីស្រែ និងស្រូវមានគុណភាពល្អ អាចចិញ្ចឹមប្រជាជនថ្មីបាន។

កំណត់ហេតុរបស់នៃអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍នាខែកក្កដា ឬខែសីហា ឆ្នាំ១៩៧៦ និងឯកសារផែនការ៤ឆ្នាំបក្សកុម្មុយនីស្តកម្ពុជា ជំរុញឲ្យមានការផ្តោតលើកិច្ចប្រឹងប្រែងស្តីពីផលិតកម្មស្រូវ។

[១០:២០:៥៦]

កថាខណ្ឌ២៧៧៖ សាក្សីមួយចំនួនដែលជាអតីតអ្នកផ្លាស់ទីលំនៅបាននិយាយថា “ពួកគេត្រូវបានប្រាប់ និងត្រូវបញ្ជូនទៅតំបន់មួយដែលមានអាហារសម្បូរជាង និងដីមានជីជាតិជាងសម្រាប់ការដាំដុំ ឬជាទីកន្លែងដែលខ្វះកម្លាំង”។ សាក្សីមួយរូបនិយាយថា “ប្រជាជនត្រូវបានប្រាប់ថា ពួកគេត្រូវតែធ្វើការឲ្យរបបសង្គមនិយម”។ នៅពេលមកដល់គោលដៅ ប្រជាជនត្រូវបានបញ្ជូនទៅធ្វើការក្នុងសហករណ៍ កសាងទំនប់ និងព្រែកជីក ឬធ្វើស្រែ។

កថាខណ្ឌ២៧៨៖ អតីតកម្មាភិបាលមូលដ្ឋានបក្សកុម្មុយនីស្តកម្ពុជាមួយរូបបានពន្យល់ថា “គោលការណ៍មជ្ឈិមត្រូវដកប្រជាជនថ្មីចេញពីបូព៌ានៅពេលដែលមានសង្គ្រាមជាមួយវៀតណាមនៅចុងឆ្នាំ១៩

៧៥ និងដើម១៩៧៦ ដោយសារមានសង្គ្រាមព្រំដែនទើបប្រជាជនថ្មីត្រូវជម្លៀសចេញ"។

<u>ការរៀបចំផែនការ</u>

កថាខណ្ឌ២៧៩៖ សក្ខីកម្មរបស់សាក្សី និងឯកសារ ចង្អុលបង្ហាញភស្តុតាងអំពីរបៀបដែលមជ្ឈិមជាប់ពាក់ព័ន្ធនៅក្នុងការផ្លាស់ទីលំនៅទាំងនេះ។ ការសម្រេចបញ្ជូនប្រជាជនទៅភូមិភាគឧត្តរ និងពាយ័ព្យនៃប្រទេស ទំនងជាត្រូវបានធ្វើឡើងបន្ទាប់ពីទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ទៅតំបន់នោះ ក្នុងអំឡុងខែសីហា ឆ្នាំ១៩៧៥។ ហើយឯកសារមួយរបស់បក្សកុម្មុយនីស្តកម្ពុជានាខែកញ្ញា ឆ្នាំ១៩៧៥ បានលើកឡើងអំពីការអនុវត្តសេចក្ដីសម្រេចនោះ។

[១០:២២:៣៨]

កថាណ្ឌ២៨០៖ ទូរលេខ១៥ នាខែវិច្ឆិកា ឆ្នាំ១៩៧៥ រៀបរាប់អំពីសេចក្ដីសម្រេចមួយដែលចេញដោយថ្នាក់លើរបស់បក្សកុម្មុយនីស្តកម្ពុជា ទាក់ទងនឹងការផ្លាស់ទីលនៅទាំងនេះ ហើយបើយើងតាមសក្ខីកម្មរបស់សាក្សីជាច្រើនដែលស៊ីសង្វាក់គ្នា សេចក្ដីសម្រេចនេះត្រូវបានអនុវត្តតាមនាពេលបន្ទាប់មក។ ទូរលេខនេះត្រូវបានបញ្ជូនដោយ ឆុន ទៅ ប៉ុល ពត ហើយចម្លងជូន នួន ជា, បងឌឿន (លេខាមន្ទីរនយោបាយ៨៧០) និងបង (លុប) (មន្ទីរ៨៧០)។

សាក្សីមួយរូបដែលធ្លាប់បានបកប្រែទូរលេខនានាឲ្យមន្ទីរ ក-១ ក្នុងអំឡុងក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិយាយថា "ប្រធានក្រុមទូរលេខបានសម្រេចចម្លងទូរលេខនេះជូន នួន ជា ដោយបញ្ជាក់ថាជាដំបូងសារទូរលេខនេះ គឺបញ្ជូនទៅតែ ប៉ុល ពត ម្នាក់គត់ ប៉ុន្តែដោយសារអ្នកគ្រប់គ្រងសារទូរលេខគាត់ដឹងថា បញ្ហានេះគឺត្រូវបញ្ជូនទៅអ្នកទទួលខុសត្រូវខាងប្រជាជន ដើម្បីដោះស្រាយ ដូចជា នួន ជាជាដើមនេះ។ សាក្សីរូបនេះ និយាយដែរថា គណៈអចិន្ត្រៃយ៍អាចមានជាប់ពាក់ព័ន្ធនឹងការដោះស្រាយបញ្ហានេះដែរ។ សាក្សីមួយរូបទៀត ដែលជាអតីតប្រធានក្រុមទូរលេខភូមិភាគកណ្ដាល (ភូមិភាគឧត្តរចាស់) បានពន្យល់ថា "ភូមិភាគបូព៌ាត្រូវបញ្ជូនរបាយការណ៍ពីភូមិភាគទៅ ប៉ុល ពត ថ្នាក់មជ្ឈិមសិន និងរង់ចាំ ប៉ុល ពត ណែនាំ។ កែ ពក លេខាភូមិភាគឧត្តរចាស់/កណ្ដាល ទទួលសារទូរលេខរឿងនេះមកពីមជ្ឈិម គឺមិនមែនទទួលផ្ទាល់មកពីខាងបូព៌ានោះទេ"។

[១០:២៤:២៦]

កថាខណ្ឌ២៨១៖ ទូរលេខ១៥ បង្ហាញជាសំខាន់អំពីបញ្ហាមួយដែលកើតឡើងពីការផ្លាស់ទីលំនៅប្រជាជនចាម ដោយឲ្យដឹងថា "ដូច្នេះប្រជាជនអ៊ីស្លាមនៅសល់ក្នុងភូមិភាគបូព៌ាជាង១សែននាក់ទៀត។

ដកនេះជាគោលការណ៍បំបែកដូចមតិបងបានពិភាក្សាជាមួយយើងខ្ញុំរួចស្រេចហើយ។ តែបើខត្តរមិនព្រមទទួល យើងខ្ញុំក៏ស៊ូទ្រាំក្តោបក្តាប់ប្រជាជនអ៊ីស្លាមតទៅទៀតដែរ គ្មានបញ្ហាអ្វីទេ”។ ហេតុការណ៍នេះកើតឡើងប៉ុន្មានសប្តាហ៍បន្ទាប់ពីការបះបោររបស់ប្រជាជនចាមនៅកោះផល និងស្វាយឃ្លាំង។

នៅក្នុងបរិបទដូច្នេះ ភស្តុតាងនេះអាចបង្ហាញថា មូលហេតុចម្បងនៃការផ្លាស់កន្លែង និងការបំបែកប្រជាជនចាមតាមការគ្រោងទុក គឺជាការដោះស្រាយបញ្ហាគំរាមកំហែងផ្នែកសន្តិសុខដែលមានជាមួយប្រជាជនចាម ព្រមទាំងជាការឆ្លុះបញ្ចាំងអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីបំបែកប្រជាជនចាម។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ដាវ អានសាន។ បាទ ឥឡូវដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់ប្រាំនាទី សូមអញ្ជើញចូលមកវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តី -- នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១០:២៥:៥៩]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី និងអង្គសវនាការទាំងមូល។ ខ្ញុំបានពិនិត្យមើលនៅក្នុងការអានរបស់ក្រឡាបញ្ជីដែលណែនាំដោយលោកប្រធាន ហើយឃើញថាការអានពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធនយោបាយ ការជម្លៀសទី១ និងជម្លៀសទី២ ជាពិសេស ក៏ប៉ុន្តែខ្ញុំពិនិត្យឃើញថា *ប៉ារ៉ាក្រាហ្វ* កថាខណ្ឌចំនួន២ ដែលពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណីគឺកថាខណ្ឌលេខ១៦១ និងកថាខណ្ឌ២៨២ មិនត្រូវបានណែនាំដោយប្រធានឲ្យក្រឡាបញ្ជីអាននោះទេ។ ហើយដោយមានការព្រួយបារម្ភអំពីផលវិបាកណាមួយដែលប៉ះពាល់ទៅដល់ឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំបាទសូមស្នើសុំ -- លើកជាសំណួរពីរដើម្បីសុំឲ្យអង្គជំនុំជម្រះជួយបញ្ជាក់ថា អំពីមូលហេតុ ហេតុអ្វីបានជាមិនមានការអានកថាខណ្ឌ១៦១ និងកថាខណ្ឌ២៨២ ដែលពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី ចំនួននៃដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងការពិនិត្យអង្គហេតុដោយការិយាល័យសហចៅក្រមស៊ើបអង្កេតនេះ ហើយចំណុចទី២ ថាតើការមិនអាននេះអាចមានផលវិបាកអ្វីពាក់ព័ន្ធទៅនឹងពាក្យសុំ ឬ/និងអង្គហេតុដែលលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពាក្យសុំរបស់គាត់។ សូមអរគុណលោកប្រធាន។

[១០:២៦:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២៦ នាទី ដល់ម៉ោង១០:៤៩ នាទី)*

[១០:៤៩:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីការសវនាការ ហើយនិងមុនផ្តល់នឹងវេទិកាជូនទៅលោក ឌុច ផារី ដើម្បីអាននូវកថាខណ្ឌជាបន្ត បញ្ចប់នោះ។ អង្គជំនុំជម្រះឆ្លើយតបទៅនឹងសំណួររបស់លោកមេធាវីជាតិ ក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានសួរអម្បាញ់មិញនេះ ថាមានកថាខណ្ឌចំនួនពីរ ដែលអង្គជំនុំជម្រះមិនបានចាត់តាំងក្រឡាបញ្ជីឲ្យអាន ហើយតើវាមានផលប៉ះពាល់អ្វីខ្លះ ចំពោះកិច្ចដំណើរសវនាការនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

អង្គជំនុំជម្រះសូមជម្រាបលោកថា ក្នុងចំណោមទាំងពីរនេះ គឺកថាខណ្ឌ១៦១ គឺជាកថាខណ្ឌដែលអង្គជំនុំជម្រះបានចាត់តាំងលោកស្រី សែ កុលវុឌ្ឍី អានរួចហើយ។ ហើយចំពោះកថាខណ្ឌ២៨២ និងកថាខណ្ឌផ្សេងទៀត អង្គជំនុំជម្រះបានអាននោះ គឺអង្គជំនុំជម្រះបានជម្រាបជូនរួចហើយ ថាឲ្យអាននូវកថាខណ្ឌទាំងឡាយ ដែលជាអង្គហេតុចោទប្រកាន់លើជនជាប់ចោទ។

[១០:៥១:១៦]

អង្គហេតុដែលមិនមែន -- កថាខណ្ឌដែលមិនចែងអំពីអង្គហេតុចោទប្រកាន់លើជនជាប់ចោទ អង្គជំនុំជម្រះមិនឲ្យអានទេ ទី១។ ហើយបញ្ហាទី២ គឺអង្គជំនុំជម្រះបានផ្អែកទៅលើឯកសារ E124/7.2 គឺការបំបែកកិច្ចដំណើរការនីតិវិធីមកធ្វើសវនាការនៅក្នុងដំណាក់ទី១ គឺបានរៀបរាប់សព្វគ្រប់ហើយ លោកអាចពិនិត្យមើលបាន។ បញ្ហាទី៣ គឺអង្គជំនុំជម្រះសូមជម្រាបថា ការដែលមិនអាននេះ មិនមាន

ផលប៉ះពាល់ផ្នែកខាងផ្លូវច្បាប់ -- ផលវិបាកផ្នែកខាងផ្លូវច្បាប់ ដល់ទៅដើមបណ្ដឹងរដ្ឋប្បវេណីទេ។

យ៉ាងណាមិញ គឺអង្គហេតុផ្សេងទៀត ដទៃទៀត ក៏អង្គជំនុំជម្រះសម្រេចមិនឲ្យអានដែរ ដូចជាបញ្ហាអង្គច្បាប់ជាដើម ឬក៏ទម្រង់នៃការទទួលខុសត្រូវជាដើម។ ពីព្រោះនោះ គឺមិនមែនជាអង្គហេតុចោទប្រកាន់លើជនជាប់ចោទទេ។ វាជាការ ជាបញ្ហាផ្លូវច្បាប់។

**លោក ពេជ អង្គ៖**

សូមអត់ទោសលោកប្រធាន ខ្ញុំចង់សូមកែសម្រួលបន្តិច។ អម្បាញ់មិញ ខ្ញុំបាននិយាយអំពីប៉ារ៉ាក្រាហ្វ១៦១ តាមការពិត គឺកថាខណ្ឌ២៦១ ដែលនិយាយអំពីដើមបណ្ដឹងរដ្ឋប្បវេណី។ សូមអរគុណលោកប្រធាន។

[១០:៥២:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្ត អង្គជំនុំជម្រះចាត់តាំងលោក ឌុច ផារី ឡើងអានទូវកថាខណ្ឌដូចខាងក្រោមនេះ គឺកថាខណ្ឌនៅក្នុងដីកាដំណោះស្រាយ ពីកថាខណ្ឌ៨៧៣ ដល់៨៧៩, ៨៩៣ ដល់៨០១, កថាខណ្ឌ១០១៦ ដល់១០២៤, កថាខណ្ឌ១១៤៦, កថាខណ្ឌ១១៥១ ដល់ កថាខណ្ឌ១១៦២, កថាខណ្ឌ១៥៨០ ដល់ កថាខណ្ឌ១៥៨៤, កថាខណ្ឌ១៥៨៩ ដល់ កថាខណ្ឌ១៥៩៧, និងកថាខណ្ឌ ពីកថាខណ្ឌ១៦០១ ដល់ កថាខណ្ឌ១៩០០ -- អ៎! ១៦០៤។ សូមអញ្ជើញ!

**ក្រឡាបញ្ជី៖**

<u>តួនាទីនៅក្នុងផ្នែកសន្តិសុខបក្សកុម្មុយនីស្ដកម្ពុជា</u>

<u>សមាជិកគណៈកម្មាធិការយោធានៃគណៈកម្មាធិការមជ្ឈិម</u>

កថាខណ្ឌ៨៧៣៖ នួន ជា ធ្លាប់ជាសមាជិកគណៈកម្មាធិកាយោធានៃគណៈកម្មាធិការមជ្ឈិម។ សមាជិកភាពរបស់គាត់នៅក្នុងគណៈកម្មាធិការនេះ ត្រូវបានបញ្ជាក់ដោយ អៀង សារី (លុប) និងសុន្ទរកថាដែលគាត់បានធ្វើឡើង នាឱកាសបុណ្យខួបលើកទី៩ នៃកងទ័ពបដិវត្តន៍កម្ពុជា។ ក្នុងនាមគណៈកម្មាធិការយោធារបស់បក្សកុម្មុយនីស្ដកម្ពុជា។

[១០:៥៤:៥២]

ឌុច បានប្រាប់ថា នួន ជា ជាសមាជិករបស់គណៈកម្មាធិការនេះ ប៉ុន្តែមិនច្បាស់លាស់ទេថា គាត់បានដឹងរឿងនេះ តាំងពីសម័យនោះមក ឬទើបតែដឹងនៅពេលដែលគាត់បានចូលមើលឯកសារនៅ

ក្នុងសំណុំរឿង។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏នៅពេលនោះ ឌុច ដឹងថា នួន ជា ទទួលបន្ទុកលើការងារសន្តិសុខ និងយោធា។ នួន ជា ទទួលស្គាល់ថា ពិតជាមានអង្គភាពបែបនេះមែននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងថាតួនាទីរបស់អង្គភាពនេះគឺការពារជាតិ និងបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុង ប៉ុន្តែបានបដិសេធនដាច់អហង្ការថា គាត់មិនធ្លាប់ជាសមាជិករបស់គណៈកម្មាធិការនោះឡើយ។

កថាខណ្ឌ៨៧៤៖ មានភស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿងបានបញ្ជាក់ថា នួន ជា ទទួលខុសត្រូវលើកិច្ចការសន្តិសុខ។ ឌុច បានអះអាងថា "ការងារសន្តិបាលត្រូវបានសម្រេចដោយ ប៉ុល ពត ប៉ុន្តែ នួន ជា ជាអ្នកតំណាងរបស់គាត់"។ អ្នកវាយសារទូរលេខ នៅក្នុងតំបន់ស្វយ័ត១០៥ បានពន្យល់ថា "ចំពោះការងារសន្តិសុខវិញ អង្គលីលេខរបស់ខ្ញុំផ្ញើទៅឈ្មោះ នួន ជា"។ គាត់បានបញ្ជាក់បន្ថែមថា "នួន ជា បានណែនាំមកជាប្រចាំអំពីការងារសន្តិសុខ"។ សាក្សីផ្សេងទៀតបានបន្ថែមថា នួន ជា ទទួលបន្ទុកលើការងារសន្តិសុខនេះ។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយអ្នកសារព័ត៌មាន នួន ជា បានបញ្ជាក់ថា សុន សេន ទទួលខុសត្រូវលើក្រសួងការពារជាតិ និងបញ្ជាក់ថា គាត់គ្មានសមត្ថភាពជ្រៀតជ្រែក ឬចេញបញ្ជាទាក់ទងនឹងសន្តិសុខផ្ទៃក្នុងនោះទេ វាជាផ្នែកទទួលខុសត្រូវរបស់គណៈកម្មាធិការយោធា។

[១០:៥៧:១៦]

កថាខណ្ឌ៨៧៥៖ ពាក់ព័ន្ធនឹងបញ្ហាយោធា អង្គភាពមជ្ឈិមរបស់កងទ័ពបដិវត្តន៍កម្ពុជា គឺជាអគ្គសេនាធិការដែលដឹកនាំដោយ សុន សេន ដោយមាន ប៉ុល ពត ទទួលខុសត្រូវទូទៅខាងផ្នែកយោធា។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងឋានៈជាអនុលេខាមជ្ឈិមបក្ស និងជាសមាជិកគណៈកម្មាធិការយោធាមជ្ឈិមបក្ស នួន ជា បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការយោធាជាមួយ ប៉ុល ពត និង សុន សេន។ នៅក្នុងអំឡុងពេលសួរយកចម្លើយ ឌុច បានបនិយាយថា "គ្រប់អ្វីៗទាំងអស់ត្រូវឆ្លង នួន ជា ទោះបីជាស្ថិតនៅក្នុងវិស័យយោធាក៏ដោយ។ នេះបង្ហាញឲ្យឃើញថា នួន ជា បានៗចូលរួមរៀបចំផែនការយោធាក្នុងការវាយប្រយុទ្ធដណ្តើមយកទីក្រុងភ្នំពេញនាខែមេសា ឆ្នាំ១៩៧៥។ លើសពីនេះទៀត សាក្សីជាច្រើនបានបញ្ជាក់ថា នួន ជា ប្រើប្រាស់អំណាចទទួលខុសត្រូវខ្លះក្នុងផ្នែកយោធាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចជាឧទ្ទេសនាមវគ្គរៀនសូត្រនយោបាយដល់សមាជិកកងទ័ពបដិវត្តន៍កម្ពុជា និងតែងតាំងកម្មាភិបាលយោធា។ អ្នកកាន់ទូរលេខឲ្យ សុន សេន ពន្យល់ថា គ្មានទំនាក់ទំនងសារទូរលេខធ្វើឡើងរវាង សុន សេន និង នួន ជា ទេ "ពីព្រោះពួកគេជួបធ្វើការងារជាមួយគ្នារាល់ថ្ងៃជាទូទៅ"។ សាក្សីដដែលនេះបានរៀបរាប់ថា "នួន ជា មិនដែលមកអគ្គសេនាធិការ ដែលជាកន្លែង សុន សេន ប្រជុំជាមួយ

កងទ័ពជាប្រចាំនោះទេ"។ ចំណុចនេះត្រូវបានបញ្ជាក់តាមហេតុដែលថា ពុំឃើញមានកំណត់ហេតុនៃការប្រជុំធ្វើឡើងរវាងអគ្គសេនាធិការ និងកងពលមជ្ឈិម និងកងវរសេនាធំឯករាជ្យនានា មានកត់ត្រាអំពីវត្តមានចូលរួមរបស់ នួន ជា នោះទេ។

[១០:៥៩:៤៥]

កថាខណ្ឌ៨៧៦៖ ទោះបីជាកិច្ចការនយោបាយការបរទេសមិនស្ថិតនៅក្នុងការទទួលខុសត្រូវចម្បងរបស់ នួន ជា ក៏ដោយ ក៏ នួន ជា បានបំពេញមុខងារមួយចំនួនទាក់ទងនឹងបញ្ហាសន្តិសុខអន្តរជាតិ។ ក្នុងឋានៈជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា នួន ជា បានចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងគោលនយោបាយ និងយុទ្ធសាស្ត្រអំពីបញ្ហាព្រំដែនកម្ពុជាព្រមទាំងស្ថានភាពជម្លោះព្រំដែនជាមួយប្រទេសវៀតណាម។ គាត់បានចូលរួមផ្តល់ជាយោបល់ និងការណែនាំច្បាស់លាស់អំពីបញ្ហាទាំងនេះ។ នួន ជា ធ្លាប់ចរចាជាមួយនឹងអាជ្ញាធរវៀតណាម និងបានចូលរួមនៅក្នុងការតាក់តែង "សៀវភៅខ្មៅ" ស្តីអំពីនយោបាយការបរទេសរបស់វៀតណាម។ នួន ជា ត្រូវបានចម្លងជូននូវសារទូរលេខជាច្រើន ដែលនៅសេសសល់ ដែលរាយការណ៍អំពីស្ថានភាពនៅលើសមរភូមិ និងនៅតាមព្រំដែនជាមួយវៀតណាម (ចលនារបស់ទ័ព ការវាយប្រយុទ្ធគ្នា និងអ្នករងរបួស)។ ទូរលេខខ្លះផ្ញើមកស្នើសុំការណែនាំ ឬសុំសម្ភារៈពីមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ឬដើម្បីបញ្ជាក់ថា បានអនុវត្តការណែនាំ ឬបានទទួលសម្ភារៈដែលបានស្នើសុំ។ មានភស្តុតាងបង្ហាញផងដែរថា នួន ជា មានអំណាចផ្ញើសេចក្តីណែនាំទាក់ទងនឹងបញ្ហាសន្តិសុខអន្តរជាតិ ទៅឲ្យថ្នាក់ក្រោម និងបង្ហាញថា នួន ជា បានផ្ញើសេចក្តីណែនាំនោះ តាមរយៈសារទូរលេខ ឬលិខិតនៅក្នុងឱកាសមួយចំនួន។

[១១:០១:៤៧]

<u>មន្ទីរសន្តិសុខ ស-២១ និងការដ្ឋាន ស-២៤ (ព្រៃស)</u>

ក្នុងកិច្ចសម្ភាសន៍ជាច្រើនក្រោយរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា បានពន្យល់ថា មុនឆ្នាំ ១៩៧៩ គាត់មិនបានដឹងពីមន្ទីរ ស-២១ នោះទេ។ ហើយប្រសិនបើមានឯកសារណាមួយដែលដាក់បន្ទុកលើរូបគាត់ ឯកសារទាំងនោះ គឺជាឯកសារដែលគេរៀបចំឡើងតែប៉ុណ្ណោះ។ នួន ជា បានបន្ថែមទៀតថា ឌុច ធ្លាប់ធ្វើការនៅក្រសួងការពារជាតិ និងសន្តិសុខផ្ទៃក្នុង ដែលមានសុន សេន ជាអ្នកទទួលខុសត្រូវ។ ទោះបីជាយ៉ាងណាក៏ដោយ មានភស្តុតាងយ៉ាងច្បាស់បានបង្ហាញថា នួន ជា ទទួលបន្ទុកគ្រប់គ្រងលើមន្ទីរសន្តិសុខស-២១ និងការដ្ឋាន ស-២៤ (ព្រៃស) របស់មន្ទីរ ស-២១ ចាប់តាំងពីការបង្កើត

មន្ទីរសន្តិសុខ ស-២១ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

កថាខណ្ឌ៨៧៨៖ នៅមន្ទីរស-២១ ចាប់តាំងពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ដំបូង អ៊ិន លន ហៅ ណាត ជាប្រធាន និងបន្ទាប់មក ឌុច មាន សុន សេន ជាថ្នាក់លើផ្ទាល់។ ឌុច យល់ឃើញថា អំណាចរបស់ សុន សេន កើតចេញពីតួនាទីរបស់គាត់ជាសមាជិកភាពរបស់គាត់នៅក្នុងគណៈយោធាមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ពីសមាជិកភាពនៅក្នុងគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា និងពីមុខតំណែងជានាយអគ្គសេនាធិការ។

[១១:០៣:០៣]

ទោះបីជានៅក្នុងដំណាក់កាលដំបូងនោះ ឌុច មិនមានទំនាក់ទំនងដោយផ្ទាល់ណាមួយជាមួយនឹង នួន ជា ក៏ដោយ ក៏ ឌុច អាចយល់បានតាមរយៈការសន្ទនារបស់គាត់ជាមួយនឹង សុន សេន ថា នួន ជា ក្នុងឋានៈជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ហើយជាបុគ្គលទី២ នៅក្នុងឋានានុក្រមបក្ស ទទួលខុសត្រូវលើមន្ទីរ ស-២១ ពីលើ សុន សេន។ ឌុច បានបញ្ជាក់ថា "សុន សេន មាន នួន ជា ជាថ្នាក់លើ ហើយនួន ជា នេះនៅក្រោម ប៉ុល ពត"។ មិនមានភាពច្បាស់លាស់ទេថា ថាតើការដឹងឮនិងការយល់ដឹងរបស់ ឌុច អំពីរចនាសម្ព័ន្ធឋានានុក្រម ដែលនៅពីលើគាត់បានកើនដល់កម្រិតណា បន្ទាប់ពីគាត់បានចូលមើលឯកសារនៅក្នុងសំណុំរឿង។ ប៉ុន្តែមានទឡ្ហីករណ៍យ៉ាងច្បាស់ដែលអាចបញ្ជាក់បានថា នៅពេលនោះ ឌុច បានដឹងថា នួន ជា ជាថ្នាក់លើរបស់ សុន សេន ពាក់ព័ន្ធនឹងមន្ទីរ ស-២១។

កថាខណ្ឌ៨៧៩៖ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ សុន សេន បានចាកចេញពីភ្នំពេញទៅកាន់សមរភូមិមុខ នៅក្នុងជម្លោះជាមួយប្រទេសវៀតណាម។ ហើយ នួន ជា បានហៅ ឌុច ឲ្យមកការិយាល័យរបស់គាត់ នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត។ ចាប់ពីពេលនោះមក ឌុច យល់បានថា គាត់ត្រូវរាយការណ៍ផ្ទាល់ទៅ នួន ជា តែក្លាយជាថ្នាក់លើរបស់គាត់។ ឌុច បញ្ជាក់ថា នួន ជា បានប្រាប់គាត់ថា ប្រធាននៃស-២១ មិនមែនខ្ញុំ ឌុច ទេ គឺគាត់ នួន ជា ប្រធាន។ ទោះបីជាត្រូវរាយការណ៍ផ្ទាល់ទៅ នួន ជា។ ឌុច នៅតែរក្សាទំនាក់ទំនងជាមួយនឹង សុន សេន តាមរយៈទូរស័ព្ទជារៀងរាល់២សប្តាហ៍ម្តង ឬ១ខែម្តង។ ថ្វីបើ ឌុច ឈប់ផ្ញើចម្លើយសារភាពទៅ សុន សេន ទៀតហើយក៏ដោយ សុន សេន នៅតែចូលរួមតាមដានសកម្មភាពការងាររបស់មន្ទីរស-២១ ដដែល។ ឌុច យល់ថា សុន សេន នៅតែចាត់ទុកខ្លួនគាត់ជាថ្នាក់លើរបស់ ឌុច។

[១១:០៦:៥១]

<u>ការចូលរួមជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ផ្សេងទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា</u>

កថាខណ្ឌ៨៩៣៖ នួន ជា មានទំនាក់ទំនងផ្ទាល់ខ្លួន និងនយោបាយជាមួយនឹងសមាជិកសំខាន់ៗរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងរយៈពេលជាច្រើនឆ្នាំ។ បន្ថែមពីលើមន្ទីរចំនួនពីររបស់គាត់ ដែលមានទីតាំងស្ថិតនៅបុរីកីឡា និងវិទ្យាល័យព្រះសុរាម្រិត (វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត) នោះ នួន ជា បានរស់នៅ និងធ្វើកិច្ចការប្រចាំថ្ងៃជាមួយ ប៉ុល ពត ខៀវ សំផន អៀង សារី និង សុន សេន នៅមន្ទីរក-១ និងមន្ទីរក-៣ ស្ទើរតែពេញមួយរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

កថាខណ្ឌ៨៩៤៖ នួន ជា បានចុះត្រួតពិនិត្យនៅឃ្លាំងមួយជាមួយនឹង ខៀវ សំផន និង វ៉ាន់ រិទ្ធ ហើយគាត់បានចុះទៅក្រសួង ហើយគាត់បានចុះទៅក្រសួងការបរទេសជាមួយនឹង ប៉ុល ពត និង ខៀវ សំផន។ នួន ជា ក៏បានធ្វើដំណើរទស្សនកិច្ចនៅមូលដ្ឋានជនបទជាមួយនឹងសមាជិកផ្សេងទៀតនៃគណៈមជ្ឈិម ដែលមានរួម ប៉ុល ពត ខៀវ សំផន និង អៀង សារី។ គាត់បានចូលរួមក្នុងការប្រជុំធំៗរបស់បក្ស រួមជាមួយនឹងថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងៗទៀត រួមមាន ប៉ុល ពត, អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ ផងដែរ។ នួន ជា បានទទួលគណៈប្រតិភូបរទេសនៅភ្នំពេញ ជាមួយនឹងសមាជិកថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងៗទៀត រួមមាន សុន សេន, ខៀវ សំផន, អៀង សារី និង ប៉ុល ពត។ ជាចុងក្រោយជាមួយថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀត បានធ្វើទំនាក់ទំនងជាប្រចាំពីភ្នំពេញទៅកាន់រដ្ឋាភិបាលបរទេសនានា។

[១១:០៩:០៣]

<u>ការចូលរួមក្នុងផែនការរួម</u>

<u>ការផ្លាស់ទីលំនៅប្រជាជន</u>

កថាខណ្ឌ៨៩៥៖ តាមរយៈតួនាទីរបស់គាត់ជាច្រើននៅក្នុងបក្សកុម្មុយនីស្តកម្ពុជា នួន ជា បានចូលរួមនៅក្នុងការជម្លៀសប្រជាជនពីទីក្រុង និងទីប្រជុំជននានាទៅជនបទ ព្រមទាំងពីជនបទមួយទៅកាន់ជនបទមួយទៀត។

កថាខណ្ឌ៨៩៦៖ បក្សកុម្មុយនីស្តកម្ពុជាបានជម្លៀសប្រជាជនពីទីប្រជុំជននានា មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែល នួន ជា សមាជិកគណៈអចិន្ត្រៃយ៍។ តាមការឲ្យដឹងរបស់ ខៀវ សំផន នៅឆ្នាំ១៩៦០ ក្នុងសន្និបាតបក្សលើកទី១ ដោយមានវត្តមានរបស់ នួន ជា មានការកំណត់ថា ទីក្រុងគឺជាកន្លែងដែលសត្រូវរបស់បដិវត្តន៍ប្រមូលផ្តុំកម្លាំង។ នៅក្នុងសុន្ទរកថានាខែកក្កដា ឆ្នាំ១៩៧៨ នួន ជា បាន

គាំទ្រគោលជំហរនេះដោយនិយាយថា មុនឆ្នាំ១៩៧៥ មានសត្រូវតិចតួចនៅតាមជនបទ ប៉ុន្តែមានសត្រូវច្រើននៅក្នុងទីក្រុង។ លើសពីនេះទៀត នៅក្នុងសុន្ទរកថាដែលគាត់បានថ្លែងក្នុងខួបអនុស្សាវរីយ៍លើកទី៩ របស់កងទ័ពបដិវត្តន៍កម្ពុជា នៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៧ នួន ជា បានលើកឡើងពីការជម្លៀសប្រជាជនចេញពីបាណាម ដែលស្ថិតនៅក្នុងភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៣ និងការជម្លៀសប្រជាជនចេញពីឧដុង្គដែលស្ថិតនៅក្នុងភូមិភាគពិសេសក្នុងឆ្នាំ១៩៧៤។

កថាខណ្ឌ៨៩៧៖ ជាច្រើនដង នៅក្នុងអំឡុងនិងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា បានគាំទ្រ និងការពារគោលនយោបាយនេះ។ ជាបឋមគាត់បានពន្យល់ថា ភ្លាមៗបន្ទាប់ពីការរំដោះទីក្រុងនានា ត្រូវបានជម្លៀសចេញដោយសារមូលហេតុសន្តិសុខដើម្បីកម្ទេចផែនការដែលជាសកម្មភាពរួមគ្នារបស់សហរដ្ឋអាមេរិក, កា.ហ្សេ.បេ និងវៀតណាម ដើម្បីដណ្តើមអំណាចពីបក្សកុម្មុយនីស្តកម្ពុជា។

[១១:១១:៥៣]

ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យ គាត់បានបន្ថែមថា ការជម្លៀសមានសារៈសំខាន់ក្នុងការការពារប្រជាជនពីសង្គ្រាម ហើយនោះគឺជាវិធានការបណ្តោះអាសន្នសមស្របមួយ ដោយសារតែការខ្វះខាតម្ហូបអាហារ និងប្រេងឥន្ធនៈនៅតាមបណ្តាក្រុងនានា។ និយាយពីប្រជាជនដែលត្រូវបានជម្លៀសវិញ គាត់បានលើកឡើងថា មិនមានប្រជាជនច្រើនស្លាប់ទេក្នុងអំឡុងពេលជម្លៀស ក្រោយមកទេមានព្រោះប្រជាជននៅមានកម្លាំង។ នួន ជា បានដឹងផងដែរ ពីការជម្លៀសប្រជាជននាសម័យកម្ពុជាប្រជាធិបតេយ្យ តាមរយៈការទទួលទូរលេខដូចជា ទូរលេខមួយចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៧ ដែលបានរាយ-ការណ៍អំពីការបែងចែកប្រជាជនថ្មីពីសៀមរាប ទៅកាន់ស្រុកផ្សេងៗ។

ដំណាក់កាលទី១

កថាខណ្ឌ៨៩៨៖ នួន ជា បានចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចដែលបណ្តាលឲ្យមានការជម្លៀសប្រជាជនចេញពីបណ្តាទីក្រុងមួយចំនួន ជាពិសេសទីក្រុងភ្នំពេញទៅកាន់ទីជនបទ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ នៅក្នុងបទសម្ភាសន៍មួយដែលធ្វើឡើងក្រោយរបបនេះ នួន ជា បាននិយាយថាសេចក្តីសម្រេចនេះ ត្រូវបានធ្វើឡើងដោយគណៈមជ្ឈិមបក្ស។ ទោះបីជាយ៉ាងណាក៏ដោយ នួន ជា នៅតែលើកឡើងពីការវិភាគ ដែលបណ្តាលឲ្យមានការសម្រេចជម្លៀសប្រជាជនចេញពីបណ្តាទីក្រុងដែលធ្វើឡើងដោយគណៈយោធាបក្សកុម្មុយនីស្តកម្ពុជា ជាគណៈកម្មាធិការមួយដែល នួន ជា បានបដិសេធថា គាត់មិនមែនជាសមាជិក។

[១១:១៣:៥៤]

កថាខណ្ឌ៨៩៩៖ នួន ជា បានជាប់ពាក់ព័ន្ធនៅក្នុងបន្តធ្វើផែនការស្តីពីគោលនយោបាយនេះ តាមរយៈការចូលរួមចំណែករបស់គាត់នៅក្នុងអង្គប្រជុំនានា ដែលប្រព្រឹត្តនៅចុងខែមីនា និងដើមខែមេសា ឆ្នាំ១៩៧៥។ នៅដើមខែមេសា មានអង្គប្រជុំមួយបានប្រព្រឹត្តទៅនៅឯមន្ទីររបស់ ប៉ុល ពត ស្ថិតក្នុងភូមិតាំងពន ស្រុកកំពង់ត្រឡាចលើ ក្នុងខេត្តកំពង់ឆ្នាំង។ គោលបំណងរបស់អង្គប្រជុំ គឺពិភាក្សាទៅលើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងរបៀបនៃការអនុវត្តគោលនយោបាយនេះ។ នួន ជា បានចូលរួមនៅក្នុងអង្គប្រជុំ និងបានកត់ត្រាខ្លឹមសារប្រជុំផ្ទាល់ខ្លួន។ សាក្សីបានឲ្យដឹងទៀតថា នួន ជា ក៏មានចំណាប់អារម្មណ៍ ហើយនិងយល់ព្រមលើផែនការដូចគ្នានេះដែរ។

[១១:១៥:០៣]

កថាខណ្ឌ៩០០៖ នួន ជា មានជាប់ពាក់ព័ន្ធនៅក្នុងការធ្វើផែនការ និងការសម្របសម្រួលផ្នែកយោធា ទាក់ទងនឹងការវាយប្រហារលើទីក្រុងភ្នំពេញក្នុងខែមេសា ឆ្នាំ១៩៧៥ ដែលបានធ្វើឡើងមុនការជម្លៀសប្រជាជនចេញពីទីក្រុង។ តាមរយៈអង្គប្រជុំដែលគាត់ធ្វើឡើងជាមួយ សុន សេន និងមេបញ្ជាការយោធាមកពីបណ្តាភូមិភាគទាំងអស់។ នៅក្នុងបទសម្ភាសន៍មួយនៅក្រោយរបបនេះ នួន ជា បាននិយាយថា "ដូច្នេះទៅវាយយកអាបន្ទាយខាងក្នុង ខាងក្នុងយក។ ដល់អីចឹង១៧ មេសា ឆ្នាំ១៩៧៥ រំដោះ កងទ័ពចូលរំដោះយកភ្នំពេញទាំងស្រុង"។ នួន ជា រួមជាមួយថ្នាក់ដឹកនាំបក្សដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងៗទៀតបានចាកចេញពីអតីតទីបញ្ជាការបក្សកុម្មុយនីស្តកម្ពុជា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ហើយបានចូលមកទីក្រុងភ្នំពេញនៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥។ កាលបរិច្ឆេទនេះមានភាពស៊ីសង្វាក់ជាមួយនឹងអង្គប្រជុំលើកដំបូងរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានធ្វើឡើងនៅក្នុងទីក្រុងភ្នំពេញ។ គឺនៅពេលក្រោយរំដោះមិនដល់មួយអាទិត្យនៅឯស្ថានីយរថភ្លើង ហើយដែលនៅទីនោះ នួន ជាត្រូវបានកត់ត្រាថា មានវត្តមាន។

[១១:១៦:៤៦]

<u>ដំណាក់កាលទី២</u>

កថាខណ្ឌ៩០១៖ សេចក្តីសម្រេចក្នុងការផ្លាស់ទីលំនៅប្រជាជនចេញពីភូមិភាគកណ្តាល ឧត្តរចាស់ ភូមិភាគបស្ចិម និងភូមិភាគបូព៌ាទៅកាន់ភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យត្រូវបានធ្វើឡើងដោយសមាជិកគណៈអចិន្ត្រៃយ៍ បន្ទាប់ពីពួកគេបានធ្វើដំណើរទស្សនកិច្ចនៅភូមិភាគពាយ័ព្យនៅចន្លោះថ្ងៃទី

២០ ដល់ ថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៧៥។ នួន ជា ប្រហែលជាបានចូលរួមធ្វើដំណើរទស្សនកិច្ចនេះ និងបានចូលរួមប្រជុំគណៈអចិន្ត្រៃយ៍ជាបន្តបន្ទាប់។ យ៉ាងហោចណាស់ គាត់ក៏បានដឹងឮផងដែរពីអត្ថិភាពរបស់ឯកសារបក្សចុះខែកញ្ញា ឆ្នាំ១៩៧៥ ដែលបានបញ្ជាក់ពីភាពចំបាច់ក្នុងការផ្លាស់ទីលំនៅប្រជាជនថ្មីទៅកាន់ភូមិភាគពាយ័ព្យ និងភូមិភាគឧត្តរ។ ឯកសារនេះស្របជាមួយនឹងអង្គប្រជុំគណៈអចិន្ត្រៃយ៍បើកទូលាយមួយក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ដើម្បីពិភាក្សាការពង្រីកវិស័យកសិកម្ម និងឧស្សាហកម្មដែល នួន ជា បានចូលរួម។

[១១:១៨:០៨]

មានទូរលេខចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ស្តីអំពីបញ្ហាកើតឡើងក្នុងការអនុវត្តសេចក្តីសម្រេចបញ្ជូនជនជាតិចាម និងប្រជាជនដទៃទៀតចេញពីភូមិភាគបូព៌ាជាលក្ខណៈទ្រង់ទ្រាយធំ ទៅភូមិភាគឧត្តរដែលបានផ្ញើដោយ ឈុន ទៅ ប៉ុល ពត និងចម្លងជូន នួន ជា។ សាក្សីមួយរូបដែលធ្លាប់ទទួលបន្ទុកបកប្រែទូរលេខនានាសម្រាប់មន្ទីរមជ្ឈិម ក-១ និយាយថា "ប្រធានមន្ទីរអង្គភាពទូរលេខជាអ្នកសម្រេចឲ្យចម្លងទូរលេខនេះទៅឲ្យ នួន ជា ដោយសារទូរលេខនេះទាក់ទងជាមួយប្រជាជនទើបគេបញ្ជូនមក នួន ជា ដើម្បីដោះស្រាយ"។

<u>ទំនាក់ទំនងជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា</u>

កថាខណ្ឌ១០១៦៖ អៀង សារី មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាលក្ខណៈបុគ្គល និងលក្ខណៈនយោបាយជាមួយសមាជិកសំខាន់ៗផ្សេងទៀតរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងរយៈពេលជាច្រើនឆ្នាំ។ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ អៀង សារី បានរស់នៅ និងធ្វើការជាមួយ សុន សេន, ខៀវ សំផន, នួន ជា និង ប៉ុល ពត នៅក-១ និងក-៣។

កថាខណ្ឌ១០១៧៖ អៀង សារី ក៏មានទំនាក់ទំនងផងដែរជាមួយមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជារួមមាន៖ ប៉ុល ពត, អៀង ធីរិទ្ធ, ខៀវ សំផន និង នួន ជា ក្នុងទិដ្ឋភាពផ្សេងៗជាច្រើនដូចជាការជួបជុំសំខាន់ៗរបស់បក្ស មុនពេលរៀបចំចេញដំណើរទៅតាមភូមិភាគ។ ដោយជួយសរសេរសុន្ទរកថាដល់ពួកគេ ឬនៅពេលទទួលពួកគេនៅប-១។ អៀង សារី និង ខៀវ សំផន ទទួលគណៈប្រតិភូបរទេសជាមួយគ្នា និងធ្វើដំណើរទៅបរទេសរួមគ្នា។ អៀង សារី និង ខៀវ សំផន ក៏ធ្លាប់បានធ្វើដំណើរទៅតាមទីជនបទ និងពិនិត្យតាមសហករណ៍ និងការដ្ឋានជាមួយគ្នាដែរ។

[១១:២០:៣៧]

<u>ការចូលរួមក្នុងផែនការរួម</u>

<u>ការផ្លាស់ទីលំនៅប្រជាជន</u>

កថាខណ្ឌ១០១៨៖ តាមរយៈតួនាទីនានារបស់គាត់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា អៀង សារី បានចូលរួមក្នុងការផ្លាស់ទីលំនៅប្រជាជន ពីតាមទីក្រុង និងទីប្រជុំជននានា ទៅជនបទ រួមទាំងការផ្លាស់ទីលំនៅពីតំបន់ជនបទមួយទៅជនបទមួយទៀត។

[១១:២១:១០]

កថាខណ្ឌ១០១៩៖ បក្សកុម្មុយនីស្តកម្ពុជាបានជម្លៀសប្រជាជនពីតាមទីក្រុងមួយចំនួន នៅមុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ខណៈដែល អៀង សារី ជាសមាជិកគណៈអចិន្ត្រៃយ៍ ជាហេតុការណ៍ដែលគាត់ទទួលស្គាល់ថា បានពិភាក្សាជាមួយ ប៉ុល ពត នាទីកន្លែងជិតទីក្រុងភ្នំពេញ នៅក្នុងឆ្នាំ១៩៧៤។ វាទំនងជាថា បញ្ហានេះ ត្រូវបានពិភាក្សាក្នុងអំឡុងពេលប្រជុំរបស់គណៈមជ្ឈិមបក្ស ខែមិថុនា ឆ្នាំ១៩៧៤។

កថាខណ្ឌ១០២០៖ ទាំងក្នុងអំឡុងពេល និងក្រោយរបបកម្ពុជាប្រជាធិតេបយ្យ អៀង សារី បានគាំទ្រ និងការពារជាសាធារណៈនូវគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលជម្លៀសមនុស្សចេញពីទីក្រុង និងបញ្ជូនប្រជាជនទៅទីជនបទ។ នៅខែកក្កដា ឆ្នាំ១៩៧៨ អៀង សារី បានផ្តល់មូលហេតុបី សម្រាប់បណ្តេញមនុស្សចេញពីទីក្រុងនៅកម្ពុជា គឺកង្វះស្បៀងអាហារ វត្តមាននៃបណ្តាញខ្មាំង និងបទពិសោធន៍ធ្វើស្រែចម្ការរបស់ប្រជាជន។ ក្នុងខែដដែល គាត់បានពន្យល់ថា នៅពេលផ្នែកឧស្សាហកម្មបានរីកចម្រើន ប្រជាជនអាចវិលត្រឡប់មកទីក្រុងវិញ។ នៅពេលមានការប្រជុំជាមួយគណៈប្រតិភូបរទេស អៀង សារី បាននិយាយថា “ការជម្លៀសប្រជាជនត្រូវបានរៀបចំផែនការជាមុន និងចាំបាច់ ដោយសារតែអាចនឹងមានការទម្លាក់គ្រាប់បែក មានគិញបង្កប់ គ្រោះអត់ឃ្លាន និងការចាំបាច់បញ្ជូនមនុស្សទៅទីជនបទ ដើម្បីបង្កបង្កើនផលកសិកម្ម”។

[១១:២៣:១៧]

អៀង សារី ក៏បានគាំទ្រដល់គោលនយោបាយនៅឯកិច្ចប្រជុំជាមួយបុគ្គលិកនៅប-១។ ដោយនិយាយថា “គេធ្វើឡើង ដើម្បីសម្រិតសម្រាំងមនុស្សដែលមានទម្លាប់នៅទីក្រុង”។ អៀង សារី បានដឹងពីការផ្លាស់ទីលំនៅដោយបង្ខំ ក្នុងសម័យគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជាតាមរយៈទទួលទូរលេខដូចជា ទូរលេខមួយ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៧ ដែលបង្ហាញពីការបញ្ជូនប្រជាជនថ្មីពីខេត្តសៀមរាបទៅស្រុកផ្សេងៗទៀត។

កថាខណ្ឌ១០២១៖ ក្រោយថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ អៀង សារី នៅបន្តគាំទ្រ និងការពារសម្រេចបណ្ដេញមនុស្សចេញពីក្រុង និងទីប្រជុំជនដដែល។ ឧទាហរណ៍នៅឆ្នាំ១៩៨០ គាត់បានអះអាងថា "ការសម្រេចចិត្តបណ្ដេញមនុស្សចេញពីទីក្រុង ត្រូវបានធ្វើឡើងដោយសារបក្សកុម្មុយនីស្តកម្ពុជាខ្លាចវៀតណាមជ្រាបចូលសម្លាប់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា"។ នៅឆ្នាំដដែលនោះ អៀង សារី អះអាងថា "នៅពេលដែលគាត់ទៅដល់ទីក្រុងភ្នំពេញ ទីក្រុងនោះ គ្មានរស់នៅរួចហើយ ហើយថាប្រសិនបើមនុស្សភាគច្រើន ក្នុងបក្សកុម្មុយនីស្តកម្ពុជាគិតដូចគាត់ ប្រាកដជាគេមិនអនុវត្តតាមការសម្រេចនោះទេ"។

[១១:២៥:០០]

នៅឆ្នាំ១៩៨៦ ចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យដែលបង្កើតឡើងដោយដោយ អៀង សារី បានប្រកាសថា ការជម្លៀសប្រជាជនចាត់ទុកជាការចាំបាច់ ដើម្បីបង្រៀនអ្នកក្រុងឲ្យចេះអត់ធន់នឹងការរងទុក្ខលំបាកទាំងផ្លូវចិត្ត និងផ្លូវកាយតាមរយៈការងារធ្ងន់។

<u>ដំណាក់ទី១</u>

កថាខណ្ឌ១០២២៖ អៀង សារី បានចូលរួមក្នុងការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ។ ទោះបីគាត់មិនបាននៅទីក្រុងភ្នំពេញ នៅពេលមានការប្រជុំសម្រេចលើផែនការជម្លៀសប្រជាជនក៏ដោយ (គាត់វិលត្រឡប់មកទីក្រុងភ្នំពេញវិញ ពីទីក្រុងប៉េកាំង ចន្លោះថ្ងៃទី២២ ដល់ថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៥ ហើយគាត់បានប្រាប់ថា នៅពេលនោះទីក្រុងគ្មានមនុស្សរស់នៅ)។ អៀង សារី ទទួលស្គាល់ថា គាត់បានពិភាក្សាផែនការជម្លៀសប្រជាជនជាមួយ ប៉ុល ពត នៅឆ្នាំ១៩៧៤ ហើយបានផ្ដល់ព័ត៌មានប្រាប់ ប៉ុល ពត ថាពួកចិនចាប់អារម្មណ៍ចង់ដឹងពីផែនការរបស់បក្សកុម្មុយនីស្តកម្ពុជា ក្រោយព្រឹត្តិការណ៍ជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជា។

[១១:២៦:២៤]

ប៉ុល ពត បានឆ្លើយតបថា ផែនការនោះគឺជាការជម្លៀសចេញពីទីក្រុង ហើយថាពួកចិនមិនចាំបាច់ព្រួយបារម្ភទេ ព្រោះធ្លាប់មានបទពិសោធន៍នេះពីខេត្តស្ទឹងត្រែង និងខេត្តក្រចេះរួចមកហើយ។ នៅដំណាក់នោះ អៀង សារី បាននិយាយថា គេមិនដឹងច្បាស់ទេថាតើទីក្រុងភ្នំពេញនឹងត្រូវជម្លៀសមនុស្សចេញទាំងស្រុងដែរឬទេ។ អៀង សារី និយាយថា ផែនការគឺត្រូវជម្លៀស ហើយបន្ទាប់មក "យើង" នឹងចាំមើលថាតើប្រជាជនកម្ពុជាទាំងនោះ រួមទាំងសហរដ្ឋអាមេរិកនឹងមានប្រតិកម្មយ៉ាងណា។ នៅខែ

កញ្ញា ឆ្នាំ១៩៨៦ អៀង សារី បានទទួលស្គាល់ថែមទៀតថា នៅឆ្នាំ១៩៧៤ គាត់បានព្រមាន ប៉ុល ពត ថា ការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញនឹងមិនងាយស្រួលដូចការជម្លៀសប្រជាជនពីទីប្រជុំជនតូចៗ ទៅខេត្តស្ទឹងត្រែង និងក្រចេះនោះទេ។ អៀង សារី បានដាស់តឿនថា គ្រប់យ៉ាងត្រូវតែ "រៀបចំឲ្យបានសព្វគ្រប់ ពីព្រោះមានប្រជាជនរាប់លាននាក់"។ គាត់និយាយថា នៅពេលគាត់មកដល់ទីក្រុង អ្វីៗទាំងអស់ត្រូវបានសម្រេចរួចជាស្រេចហើយ វាគ្មានប្រយោជន៍នឹងនិយាយពីបញ្ហានេះទៀតទេ។

[១១:២៧:៥៧]

កថាខណ្ឌ១០២៣៖ ការពន្យល់ជាបន្តបន្ទាប់ដែល អៀង សារី បានផ្តល់ឲ្យចំពោះហេតុផលដែលនាំឲ្យមានការជម្លៀសប្រជាជនចេញពីភ្នំពេញ មានខុសៗគ្នាទៅតាមឆ្នាំ។ នៅខែកញ្ញា ឆ្នាំ១៩៧៥ អៀង សារី បានអះអាងថា មានហេតុផលពីរដែលសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ទី១ ដោយសារមានការខ្វះខាតស្បៀងអាហារ និងបក្សកុម្មុយនីស្តកម្ពុជាមិនមានមធ្យោបាយដឹកជញ្ជូនគ្រប់គ្រាន់ ដើម្បីដឹកជញ្ជូនស្បៀងមកទីក្រុងភ្នំពេញ។ ដូច្នេះ ពួកគេសម្រេចជម្លៀសប្រជាជនទៅទីជនបទដែលមានស្បៀងអាហារ។ ការធ្វើបែបនេះ ដើម្បីបញ្ចៀសការសុំជំនួយពីប្រទេសដទៃ។ ទី២ ពួកគេបានរកឃើញឯកសារមួយដែលពណ៌នាលម្អិតអំពីផែនការសម្ងាត់របស់ សេ.អ៊ី.អា និងរបប លន់ នល់ ដែលដួលរលំ ដើម្បីរំលំនិងតស៊ូប្រឆាំងនឹងជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជានៅទីក្រុងភ្នំពេញ។ អៀង សារី បាននិយាយថាផងដែរថា ប្រជាជនអាចត្រឡប់មកទីក្រុងភ្នំពេញវិញ ប្រសិនបើពួកគេចង់ ហើយជាក់ស្តែងមានប្រជាជនចំនួន ១សែននាក់ បានត្រឡប់មកវិញ។

[១១:២៩:២៧]

ក្នុងខែតុលា ឆ្នាំ១៩៧៥ អៀង សារី បានអះអាងថា ការជម្លៀសចេញពីទីក្រុងភ្នំពេញ ជាការចាំបាច់ដើម្បីបង្អាក់ផែនការអាមេរិក ក្នុងការធ្វើឲ្យរដ្ឋាភិបាលគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជាដួលរលំ។ នៅខែឧសភា ឆ្នាំ១៩៧៧ អៀង សារី បានអះអាងថា បន្ទាប់ពី "ក្រោយពីការជម្លៀសប្រជាជនលើកដំបូងចេញពីទីក្រុង ឥឡូវទីក្រុងកំពុងមានកំណើនប្រជាជនឡើងវិញ" ហើយថា តំបន់ដែលពុំមានប្រជាជនត្រូវបានប្រើប្រាស់សម្រាប់បង្កបង្កើនផល។ អៀង សារី ក៏បានទទួលស្គាល់ផងដែរថា ប្រជាជនពី ២.០០០ នាក់ ទៅ ៣.០០០ បានស្លាប់ក្នុងអំឡុងពេលជម្លៀសចេញពីទីក្រុងភ្នំពេញ។ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៨ អៀង សារី បានពន្យល់យ៉ាងលម្អិតដល់ឯកអគ្គរដ្ឋទូតដាណឺម៉ាក ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ អៀង សារី បាននិយាយថា ការជម្លៀសនោះគឺដោយសារកង្វះ

ស្បៀងអាហារ បញ្ហាសន្តិសុខ និងភាពចាំបាច់ក្នុងការបង្កើតផលិតផលកសិកម្ម។

[១១:៣០:៥០]

ដំណាក់កាលទី ២

កថាខណ្ឌ១០២៤៖ ការសម្រេចផ្លាស់ទីលំនៅប្រជាជនចេញពីភូមិភាគកណ្តាល ខេត្តឧត្តរ -- ភូមិភាគកណ្តាលឧត្តរចាស់ ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា ទៅកាន់ភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យបានធ្វើឡើងដោយគណៈអចិន្ត្រៃយ៍ ក្រោយពេលពួកគេបានទៅទស្សនកិច្ចនៅភូមិភាគពាយ័ព្យចន្លោះថ្ងៃទី២០ ដល់ថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៧៥។ ទោះបី អៀង សារី ប្រហែលជាមិននៅក្នុងប្រទេសក្នុងពេលនោះក៏ដោយ ប៉ុន្តែគាត់បានទទួលស្គាល់ថា គាត់បានចូលរួមក្នុងអង្គប្រជុំបើកទូលាយមួយរបស់គណៈអចិន្ត្រៃយ៍នៅខែកញ្ញា ឆ្នាំ១៩៧៥ ដើម្បីពិភាក្សាអំពីបញ្ហានៃការបង្កើតរបបផ្តាច់ការ និងការពង្រីកវិស័យកសិកម្ម និងឧស្សាហកម្ម។ ម្យ៉ាងទៀត មានឯកសារមួយរបស់បក្ស មានចុះកាលបរិច្ឆេទដូចគ្នានឹងការប្រជុំនេះបញ្ជាក់ពីភាពចាំបាច់ក្នុងការបញ្ជូនប្រជាជនថ្មីទៅក្នុងភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ។

[១១:៣២:១១]

តួនាទីផ្សេងៗទៀត

ផ្នែកយោធា

កថាខណ្ឌ១១៤៦៖ ទាំងមុន និងក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខៀវ សំផន មានតួនាទីជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គមេបញ្ជាការកងទ័ពរំដោះជាតិ និងប្រជាជនកម្ពុជា។ ឌុច អះអាងថា ខៀវ សំផន គ្រាន់តែជាប្រធានកិត្តិយសគណៈកម្មាធិការយោធា ជារូបភាពបង្ហាញសកលលោកទេ។ រីឯ ប៉ុល ពត មានអំណាចពិតប្រាកដក្នុងវិស័យយោធា។

ការចូលរួមជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងៗ នៃបក្សកុម្មុយនីស្តកម្ពុជា

កថាខណ្ឌ១១៥១៖ ខៀវ សំផន មានទំនាក់ទំនងស្និទ្ធស្នាលជាលក្ខណៈបុគ្គល និងជាលក្ខណៈនយោបាយជាមួយសមាជិកសំខាន់ៗផ្សេងទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា អស់រយៈពេលជាច្រើនឆ្នាំ។ ក្នុងរបបបក្សកុម្មុយនីស្តកម្ពុជា គាត់បានចូលរួមជាទៀងទាត់មួយមេដឹកនាំជាន់ខ្ពស់ដទៃទៀតនៃបក្សកុម្មុយនីស្តកម្ពុជា។ គាត់បានរស់នៅ និងធ្វើការជាមួយ សុន សេន, អៀង សារី, នួន ជា, ប៉ុល ពត និង វន វ៉េត (រហូតពេល វន វ៉េត ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១) នៅមន្ទីរក-១ និងមន្ទីរ ក-៣

អស់រយៈពេលមួយភាគធំនៃរបបនេះ។ សាក្សីតែងតែបានឃើញ ខៀវ សំផន ចូលរួមប្រជុំ និងធ្វើការជាមួយថ្នាក់ដឹកនាំទាំងនោះ និងមេដឹកនាំជាន់ខ្ពស់ដទៃទៀត និងបានឮការប្រកាសតាមវិទ្យុអំពីការធ្វើការរួមគ្នារបស់ពួកគេ។ ឌុច បានផ្តល់សក្ខីកម្មថា ខៀវ សំផន ជាមនុស្សដែល ប៉ុល ពត ទុកចិត្ត ហើយបានទទួលនូវព័ត៌មានអធិភាពទាំងឡាយ។

[១១:៣៤:២៧]

កថាខណ្ឌ១១៥២៖ ខៀវ សំផន បានធ្វើជាគណៈអធិបតីនៅក្នុងកិច្ចប្រជុំ និងវគ្គរៀនសូត្រសំខាន់ៗរបស់បក្ស ដោយមានវត្តមាន ប៉ុល ពត, នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ហើយគាត់បានធ្វើបទបង្ហាញផងដែរ។ ខៀវ សំផន និង អៀង សារី បានទទួលគណៈប្រតិភូបរទេសរួមគ្នា និងបានធ្វើដំណើរទៅក្រៅប្រទេសរួមគ្នា។ ខៀវ សំផន និង អៀង សារី ក៏បានធ្វើដំណើរទៅតាមទីជនបទ និងបានចុះត្រួតពិនិត្យមើលតាមសហករណ៍ និងការដ្ឋាននានារួមគ្នា។ អៀង សារី តែងបានប្រាស្រ័យទាក់ទងជាទៀងទាត់ជាមួយខៀវ សំផន នៅពេលគាត់រៀបចំទទួលភ្ញៀវ និងនៅពេលធ្វើដំណើរទៅតាមបណ្តាភូមិភាគ។

<u>ការចូលរួមក្នុងផែនការរួម</u>

<u>ការផ្លាស់ទីលំនៅប្រជាជន</u>

កថាខណ្ឌ១១៥៣៖ តាមរយៈតួនាទីផ្សេងៗរបស់គាត់ក្នុងបក្សកុម្មុយនីស្តកម្ពុជា ខៀវ សំផន បានចូលរួមក្នុងការផ្លាស់ទីលំនៅប្រជាជនពីទីក្រុងទៅកាន់តំបន់ជនបទនានា ហើយព្រមទាំងពីតំបន់ជនបទមួយ ទៅកាន់តំបន់ជនបទមួយទៀត។

[១១:៣៥:៥០]

<u>ដំណាក់កាលទី១</u>

កថាខណ្ឌ១១៥៤៖ (លុប) បានបញ្ជាក់ថា ខៀវ សំផន បានចូលរួមប្រជុំសម្រេចអំពីផែនការផ្លាស់ទីលំនៅប្រជាជនទីក្រុងភ្នំពេញ នៅដើមខែមេសា ឆ្នាំ១៩៧៥។ ការប្រជុំនេះគឺនៅមន្ទីរប-៥ ដែលជាមន្ទីររបស់ ប៉ុល ពត ស្ថិតនៅភូមិតាំងពន ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ (លុប) បានគូសបញ្ជាក់ថា ខៀវ សំផន ជាអ្នកកត់ត្រា និងឡើងមានយោបល់ និងចំណាប់អារម្មណ៍ ហើយឯកភាពតាមផែនការដែលត្រូវជម្លៀសប្រជាជន។

កថាខណ្ឌ១១៥៥៖ សាក្សីម្នាក់ទៀតបានផ្តល់សក្ខីកម្មបញ្ជាក់ថា ខៀវ សំផន បានចូលមកទីក្រុងភ្នំពេញ នៅថ្ងៃទី២០ ឬរង្វង់ថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សី

ម្នាក់នេះ បានធ្វើដំណើរទៅកាន់ភ្នំអង្គរស្ស ដើម្បីសម្រាក និងរៀបចំខ្លួនចូលទីក្រុងភ្នំពេញជាមួយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាមួយក្រុម។ សាក្សីនេះបានបញ្ជាក់ថា ខៀវ សំផន, ហ៊ូ នឹម និង សុន សេន បានធ្វើដំណើរទៅជួបគ្នានៅឯភ្នំអង្គរស្ស និងបានត្រៀមចូលទៅកាន់ -- និងបានត្រៀមចូលទៅកាន់កាប់ក្រុងភ្នំពេញ។ គាត់បានបញ្ជាក់ថា ខៀវ សំផន, ហ៊ូ នឹម និង សុន សេន បានស្នាក់នៅភ្នំអង្គរស្សចំនួនបីយប់ មុនពេលធ្វើដំណើរចូលភ្នំពេញ។

កថាខណ្ឌ១១៥៦៖ ខៀវ សំផន បានបញ្ជាក់ថា គាត់បានចូលទីក្រុងភ្នំពេញពីថ្ងៃទី០៧ ដល់ថ្ងៃទី១០ -- ពី ៧ ទៅ១០ថ្ងៃ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ គាត់បាននិយាយថា គាត់ពុំបានដឹងអំពីផែនការជម្លៀសប្រជាជនចេញពីភ្នំពេញឡើយ ទើបតែពេលគាត់បានចូលមកភ្នំពេញ និងបានស្តាប់ឮទាហានមួយក្រុមជជែកគ្នាអំពីរឿងនេះប៉ុណ្ណោះ។ គាត់បានបញ្ជាក់ជាសាធារណៈថា គាត់គិតថាប្រជាជនពុំគួរត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញឡើយ។

[១១:៣៨:៤១]

កថាខណ្ឌ១១៥៧៖ ខៀវ សំផន បានចេញសេចក្តីថ្លែងការណ៍មួយចំនួនតាមវិទ្យុ នៅប៉ុន្មានខែមុនការជម្លៀសប្រជាជន ដែលនិយាយពាក់ព័ន្ធនឹងសភាពការណ៍នៅភ្នំពេញ។ នៅចន្លោះខែមករា និងខែមេសា ឆ្នាំ១៩៧៥ ខៀវ សំផន បានលើកឡើងជាច្រើនដង អំពីអ្វីដែលបានកំពុងកើតឡើងនៅភ្នំពេញ។ គាត់បានអះអាងថា បនក្បត់ លន់ នល់ ជិតដួលរលំហើយ បានបញ្ជា និងអំពាវនាវឲ្យប្រជាជនភ្នំពេញវាយប្រយុទ្ធពួក លន់ នល់ ដើម្បីរំដោះជាតិ។ គាត់ក៏បានអំពាវនាវឲ្យស្ថានទូតបរទេស និងអង្គការបរទេសទាំងអស់នៅភ្នំពេញជម្លៀសបុគ្គលិករបស់ខ្លួន ដើម្បីចៀសវាងការបាត់បង់អាយុជីវិតបុគ្គលទាំងនោះ។ ផ្អែកតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ខៀវ សំផន បានជំរុញឲ្យអ្នកទីក្រុងភ្នំពេញ ទៅរស់នៅជនបទ ដោយអំពាវនាវថា ឲ្យប្រជាជនធ្វើដំណើរទៅកាន់តំបន់រំដោះ ដោយប្រកាសថា ពុំមានអង្គការទេនៅក្នុងទីក្រុងភ្នំពេញ -- ដោយពុំមានអង្ករទេនៅក្នុងទីក្រុងភ្នំពេញ។ ហើយសន្យាប្រាប់ប្រជាជនថា កម្មាភិបាល និងអ្នកតស៊ូដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជាបានត្រៀមខ្លួនរួចជាស្រេច ដើម្បីជួយពួកគេឲ្យមានជីវិតថ្មីនៅជនបទ។ ហើយជាពិសេស ពួកគេអាចទទួលបានការផ្គត់ផ្គង់ និងមធ្យោបាយគ្រប់គ្រាន់សម្រាប់ផលិតកម្មកសិកម្ម។

[១១:៤០:២៩]

កថាខណ្ឌ១១៥៨៖ ខៀវ សំផន បានអំពាវនាវឲ្យកម្មាភិបាលបក្ស និងអ្នកតស៊ូ ដើម្បីបោស

សម្អាតសត្រូវឲ្យមានសកម្មភាពខ្លាំងក្លានៅទូទាំងតំបន់រំដោះ។ ហើយជាទូទៅ ដើម្បីលើកកម្ពស់ការប្រុងប្រយ័ត្ន បដិវត្តន៍ប្រឆាំងនឹងផែនការរបស់សត្រូវ។ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥ ខៀវ សំផន បានចេញសេចក្ដីប្រកាសព័ត៌មានមួយតាងនាមឲ្យរណសិរ្សរួបរួមជាតិកម្ពុជា ដោយបានប្រកាសថា ពួកក្បត់ទាំងប្រាំពីរ នៅទីក្រុងភ្នំពេញ លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត និង Sosthene Fernandez (សូស្តែន ហ្វែណង់ដេស) ត្រូវសម្លាប់ចោល និងបានអំពាវនាវឲ្យប្រជាជននៅភ្នំពេញរួមចំណែកដល់ការរំដោះជាតិតាមរយៈ បង្វែរចុងកាណុងដាក់ពួកវា។

[១១:៤១:៤០]

គាត់បានបញ្ជាក់ថា បនក្បត់ជាតិទីក្រុងភ្នំពេញបច្ចុប្បន្ននេះកំពុងភ័ន្តភាំង ភ័យស្លន់ស្លោ និងជិតដួលរលំទាំងស្រុង និងបានបញ្ជាឲ្យប្រជាជនវាយប្រហារខ្លាំងឲ្យបានខ្លាំងក្លា និងច្រើនឡើងថែមទៀតទាំងនៅខ្សែត្រៀមខាងមុខ និងខ្សែត្រៀមខាងក្រោយ ដើម្បីសម្រេចបាននូវភារកិច្ចរំដោះប្រជាជាតិ និងប្រជាជនយើងទាំងស្រុង និងជាអចិន្ត្រៃយ៍។

នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៥ គាត់បានថ្លែងសុន្ទរកថាតាមវិទ្យុថា ទោះបីជា លន់ នល់ និងពួកក្បត់ផ្សេងទៀត ដែលបានរៀបរាប់ឈ្មោះក្នុងខែកុម្ភៈ បានគេចចេញពីប្រទេសក៏ដោយ ក៏មានការប្រឹងប្រែងបន្តនូវអំពើក្បត់របស់ក្រុមក្បត់ចុងក្រោយផងដែរ។ ហើយបានអំពាវនាវឲ្យប្ដួលរំលំពួកក្បត់ទាំងនោះជាស្ថាពរ។

កថាខណ្ឌ១១៥៩៖ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៥ ខៀវ សំផន បានពន្យល់តាមវិទ្យុថា ភ្លាមៗក្រោយរំដោះ រណសិរ្សរួបរួមកម្ពុជាបានប្រឈមនឹងការរកវិធីដោះស្រាយបញ្ហាប្រជាជនឥតឃ្លាននៅភ្នំពេញ។ ហើយពួកគេបានដោះស្រាយបញ្ហានេះតាមរយៈការកេណ្ឌកម្លាំងប្រជាជន ដើម្បីបង្កើនផលិតកម្មនៅទូទាំងផ្ទៃប្រទេស។ ខៀវ សំផន បានលើកឡើងម្ដងទៀតនូវអំណះអំណាងទាំងនេះក្នុងសុន្ទរកថារបស់គាត់នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៦ ក្នុងឱកាសសន្និសីទកំពូលលើកទី៥នៃប្រទេសមិនចូលបក្សសម្ព័ន្ធនៅកូឡុំប៊ី ដោយបានបញ្ជាក់ថា យើងបានដោះស្រាយជាមូលដ្ឋានរួចហើយនូវបញ្ហាជីវភាពប្រជាជនកម្ពុជាយើង ចាប់តាំងពីថ្ងៃរំដោះ ពិសេសពាក់ព័ន្ធបញ្ហាស្បៀងអាហារ។ ខៀវ សំផន បានចេញសេចក្ដីថ្លែងការណ៍មួយចំនួនជាបន្តបន្ទាប់ដោយយល់ស្រប និងការពារផែនការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញដោយសំអាងថា ប្រជាជនកំពុងអត់ឃ្លាន។

[១១:៤៤:០៦]

កថាខណ្ឌ១១៦០៖ (លុប) បានបញ្ជាក់ថា ខៀវ សំផន បានប្រាប់ព្រះអង្គនៅក្នុងលិខិតមួយថា កុំឲ្យយាងត្រឡប់ទៅភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ ដោយហេតុថា បក្សកុម្មុយនីស្តកម្ពុជាត្រូវការជម្លៀសប្រជាជនដើម្បីទប់ស្កាត់ការរាលដាលនៃជំងឺឆ្លងដែលអាចបណ្តាលឲ្យស្លាប់។ ក្នុងពេលសួរចម្លើយ ខៀវ សំផន បាននិយាយប្រាប់សហចៅក្រមស៊ើបអង្កេតថា គាត់អាចភ្លេច ប៉ុន្តែសារនោះ អាចជាសារមួយដែលអានឲ្យកត់ត្រាដោយ ប៉ុល ពត។

[១១:៤៤:៥១]

កថាខណ្ឌ១១៦១៖ អត្ថបទសារព័ត៌មានមួយ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៥ អះអាងថា ខៀវ សំផន បានចូលទីក្រុងភ្នំពេញនៅសប្តាហ៍មុនក្នុងសម្លៀកបំពាក់ខ្មៅ និងក្រមាមួយ និងដោយបានប្រកាសអំពី ជ័យជម្នះនៃរបបឆ្វេងនិយមថ្មីរបស់គាត់។ លើសពីនេះរបាយការណ៍សារព័ត៌មានញូវយ៉កថាមស៍ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៨២ បានសរសេរលម្អិតអំពីកិច្ចសម្ភាសន៍មួយជាមួយ ខៀវ សំផន នៅឯទីក្រុង កូឡាំប៊ួរ ដែលគេជឿថាគាត់បានទទួលស្គាល់ថា បានចូលរួមក្នុងការសម្រេចរួមគ្នាអំពីការជម្លៀសប្រជាជនចេញពីភ្នំពេញដោយបង្ខំ។

<u>ដំណាក់កាលទី២</u>

កថាខណ្ឌ១១៦២៖ ការសម្រេចផ្លាស់ទីលំនៅប្រជាជនពីភូមិភាគកណ្តាល ឧត្តរចាស់ និរតី បស្ចិម និងបូព៌ា ត្រូវបានធ្វើដោយគណៈអចិន្ត្រៃយ៍បន្ទាប់ពីសមាជិកគណៈអចិន្ត្រៃយ៍បានទៅទស្សនកិច្ចនៅភូមិភាគពាយ័ព្យរវាងថ្ងៃទី២០ ដល់ ២៤ ខែសីហា ឆ្នាំ១៩៧៥។ ទោះបីជាមិនមាន កំណត់ត្រាអំពីអ្នកដែលបានទៅទស្សកិច្ចក៏ដោយ ហើយទោះបីជាគាត់ពុំមែនជាសមាជិកនៃបេសកកម្មនេះក្តី ក៏ អៀង សារី បានបញ្ជាក់ថា ខៀវ សំផន បានចូលរួមប្រជុំគណៈអចិន្ត្រៃយ៍បើកទូលាយនៅខែ កញ្ញា ឆ្នាំ១៩៧៥ ដើម្បីពិភាក្សាអំពីថា អនុវត្តលទ្ធិផ្តាច់ការ និងការពង្រីកវិស័យកសិកម្មនិងឧស្សាហកម្ម។

[១១:៤៦:៥៥]

ឯកសារមួយរបស់បក្សដែលមានកាលបរិច្ឆេទស្របគ្នានឹងថ្ងៃប្រជុំបានបញ្ជាក់ថា គេត្រូវការផ្លាស់ទីលំនៅប្រជាជនថ្មីទៅភូមិភាគឧត្តរ និងពាយ័ព្យ។

ជំពូកទី៤៖ បុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ

<u>ផ្នែកទីមួយ៖ នួន ជា</u>

កថាខណ្ឌ១៥៨០៖ សកម្មភាពនយោបាយរបស់ នួន ជា រហូតដល់ឆ្នាំ១៩៧៩ នឹងត្រូវរៀបរាប់

នៅក្នុងផ្នែកទាក់ទងនឹងជនត្រូវចោទនៃដីកាដំណោះស្រាយនេះ។

កថាខណ្ឌ១៥៨១៖ នៅពេលកងទ័ពវៀតណាមមកដល់នៅខែមករា ឆ្នាំ១៩៧៩ នួន ជា និង ប៉ុល ពត បានជួបជុំជាមួយ អៀង សារី និង ខៀវ សំផន នៅក្នុងខេត្តពោធិ៍សាត់។ នៅពេលប្រជុំគណៈមជ្ឈិមនាខែកុម្ភៈ ឬខែមីនា ឆ្នាំ១៩៧៩ នួន ជា បានជំរុញឲ្យ ប៉ុល ពត បន្តនៅជាលេខាបក្ស។ បន្ទាប់មកទៀត នួន ជា បានធ្វើដំណើរនៅក្នុងប្រទេសកម្ពុជាដើម្បីបែងចែកសម្ភារៈសឹកឲ្យកម្មាភិបាល និងកងទ័ព។ នៅខែធ្នូ ឆ្នាំ១៩៧៩ គណៈអចិន្ត្រៃយ៍របស់សភាតំណាងប្រជាជនបានសម្រេចជាឯកច្ឆ័ន្ទរក្សាតួនាទីរបស់គាត់ជាប្រធានសភាដដែល។ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៨១ នួន ជា បានរៀបចំសន្និសីទ ជាមួយ ខៀវ សំផន ដែលនៅក្នុងសន្និសីទនោះគាត់បានសម្រេចបង្កើតរណសិរ្សរួបរួមមួយ ជាមួយនឹងរណសិរ្សរំដោះជាតិប្រជាជនខ្មែរ និងអ្នករាជានិយម ដើម្បីប្រឆាំងនឹងវៀតណាម។ ក្រោយមក ក្នុងនាមសភាតំណាងប្រជាជននៃកម្ពុជាប្រជាធិបតេយ្យ នួន ជា និង ខៀវ សំផន បានផ្សព្វផ្សាយសារាចរណែនាំផ្សេងៗដែលអំពាវនាវឲ្យកងទ័ពប្រជាជន និងជនរួមជាតិទាំងអស់ដែលនៅក្រៅប្រទេសឲ្យបន្តការតស៊ូដើម្បីមាតុភូមិប្រឆាំងនឹងវៀតណាម។

[១១:៤៩:៣៤]

នៅខែតុលា ឆ្នាំ១៩៨១ នួន ជា ជាប្រធានគណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យចូលរួមសន្និសីទអាស៊ី សភាអាស៊ី ធ្វើនៅទីក្រុងបេកាំង។ បន្ទាប់ពីការរំលាយបក្សកុម្មុយនីស្តកម្ពុជាជាផ្លូវការនៅចុងឆ្នាំ១៩៨៣ ឬនាដើមឆ្នាំ១៩៨៤ នួន ជា បានចូលរួមវគ្គអប់រំនយោបាយនៅតំបន់សំឡូត ដែលនៅក្នុងវគ្គសិក្សានយោបាយនោះ គាត់បានប្រកាសថា "របបសង្គមនិយមកុម្មុយនីស្តមិនមែនជាគោលដៅរបស់យើងនោះទេ។ វាគ្រាន់តែជាមធ្យោបាយសម្រាប់ស្នេហាជាតិនិយមតែប៉ុណ្ណោះ"។

[១១:៥០:២០]

កថាខណ្ឌ១៥៨២៖ នួន ជា ជាមួយនឹង ខៀវ សំផន បានចុះចូលជាមួយរដ្ឋាភិបាលទីក្រុងភ្នំពេញនៅខែធ្នូ ឆ្នាំ១៩៩៨ ជាង៦ខែ ក្រោយពីការស្លាប់របស់ ប៉ុល ពត។ នៅពេលចាប់ខ្លួនគាត់នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ នួន ជា រស់នៅជាមួយប្រពន្ធគាត់នៅភូមិផ្សារព្រំ ស្រុកប៉ៃលិន។

កថាខណ្ឌ១៥៨៣៖ បន្ទាប់ពីបានប្រកាសបដិសេធអង្គហេតុ ដែលបានចោទប្រកាន់ទាំងអស់ និងថាចង់បំភ្លឺឲ្យពិភពលោកដឹងការពិត នៅពេលចូលខ្លួនដំបូង និងនៅពេលសួរដេញដោលបឋម ដើម្បីធ្វើការឃុំខ្លួនរបស់គាត់ នួន ជា មិនបានធ្វើសេចក្តីប្រកាសជាខ្លឹមសារណាមួយទេ។ ដោយគ្រាន់តែលើក

ឡើងជាបឋមអំពីសុខភាពរបស់គាត់ប៉ុណ្ណោះ។ នួន ជា ក៏បានជ្រើសរើសអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបផងដែរ។

កថាខណ្ឌ១៥៨៤៖ នួន ជា បានបដិសេធការជួបជាមួយអ្នកជំនាញផ្នែកចិត្តសាស្ត្រ ដែលទទួលបន្ទុកពិនិត្យ និងផ្តល់យោបល់អំពីលទ្ធភាពរបស់គាត់ក្នុងការទទួលយកការជំនុំជម្រះ។ ដូច្នេះ អ្នកជំនាញធ្វើការសង្កេតថា សំណុំឯកសារពេទ្យរបស់ នួន ជា មិនបង្ហាញអំពីប្រវត្តិនៃបញ្ហាផ្លូវចិត្តពីអតីតកាលឡើយ។

[១១:៥២:១១]

<u>ផ្នែកទី២៖ អៀង សារី ហៅ វ៉ាន់</u>

កថាខណ្ឌ១៥៨៩៖ សកម្មភាពនយោបាយរបស់ អៀង សារី រហូតដល់ឆ្នាំ១៩៧៩ ត្រូវបានវិភាគនៅក្នុងផ្នែក ទាក់ទងនឹងជនត្រូវចោទនៃដីកាដំណោះស្រាយនេះ។

កថាខណ្ឌ១៥៩០៖ នៅដើមឆ្នាំ១៩៧៩ នៅពេលដែលកងទ័ពវៀតណាមចូលមកប្រទេសកម្ពុជា អៀង សារី បានភៀសខ្លួនទៅប្រទេសថៃ ហើយបានជួបជាមួយ ប៉ុល ពត និង នួន ជា នៅជិតខេត្តពោធិ៍សាត់។ បន្ទាប់មកមានការសម្រេចបញ្ជូន អៀង សារី ទៅប្រទេសចិន ដើម្បីចរចាសុំជំនួយ។

កថាខណ្ឌ១៥៩១៖ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៩ អៀង សារី ត្រូវបានតុលាការបដិវត្តន៍ប្រជាជនភ្នំពេញជំនុំជម្រះកំបាំងមុខ រួមជាមួយ ប៉ុល ពត ពីបទប្រល័យពូជសាសន៍ ហើយផ្តន្ទាទោសប្រហារជីវិត និងដកហូតទ្រព្យសម្បត្តិ។

[១១:៥៣:២០]

កថាខណ្ឌ១៥៩២៖ អៀង សារី បានបន្តតួនាទីជាផ្លូវការក្នុងរដ្ឋាភិបាលនិរទេស ដោយតំណាងរដ្ឋាភិបាលនេះ នៅក្រៅប្រទេស ជាពិសេសនៅអង្គការសហប្រជាជាតិ និងត្រូវបានស្គាល់តាមរយៈសារព័ត៌មានបរទេស ថាជាប្រមុខដឹកនាំម្នាក់នៃរបបខ្មែរក្រហម។ ក្នុងឆ្នាំ១៩៨២ នៅពេលបង្កើតរដ្ឋាភិបាលចម្រុះ ដែលក្រៅពីសមាសភាពខ្មែរក្រហម មានការចូលរួមពីក្រុមអ្នកនិយមសម្តេច សីហនុ និង សុន សេន, អៀង សារី បានផ្ទេរក្រសួងការបរទេសទៅឲ្យ ខៀវ សំផន។

កថាខណ្ឌ១៥៩៣៖ ក្នុងតួនាទីជាអ្នកទទួលខុសត្រូវលើគណៈកម្មាធិការសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃរដ្ឋាភិបាលចម្រុះ អៀង សារី បានដើរតួនាទីដាច់មុខ ជាអ្នកទាក់ទងតែមួយគត់ជាមួយអាជ្ញាធរចិនពាក់ព័ន្ធនឹងបញ្ហាជំនួយយោធា និងហិរញ្ញវត្ថុ ដែលផ្តល់ដោយរដ្ឋាភិបាលក្រុងប៉េកាំងដល់ខ្មែរក្រហម។

កថាខណ្ឌ១៥៩៤៖ ក្រោយមកឥទ្ធិពលរបស់ អៀង សារី នៅក្នុងចលនានេះ បានថយចុះបន្តបន្ទាប់ ដោយគាត់ត្រូវបានដកហូតការទទួលខុសត្រូវជាច្រើន។ ក្នុងខែសីហា ឆ្នាំ១៩៩៦ ការបែកបាក់បានកើតឡើង ហើយ អៀង សារី បានចុះចូលជាមួយរដ្ឋាភិបាល ព្រមជាមួយនឹងក្រុមអ្នកគាំទ្រគាត់ជាច្រើនពាន់នាក់។

[១១:៥៥:០៦]

តាមរយៈព្រះរាជក្រិត្យ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦ អៀង សារី ត្រូវបានលើកលែងទោសពីការផ្តន្ទាទោសក្នុងឆ្នាំ១៩៧៩ និងទទួលបានផងដែរនូវការលើកលែងចេញពីច្បាប់ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤ (ច្បាប់ស្តីពីការដាក់ក្រុម កម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់)។

កថាខណ្ឌ១៥៩៥៖ ក្នុងឆ្នាំ១៩៩៧ អៀង សារី បានបង្កើតគណបក្សមួយដែលមានឈ្មោះថា ចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យ ដើម្បីចូលរួមក្នុងការបោះឆ្នោតក្នុងឆ្នាំ១៩៩៨ ក៏ប៉ុន្តែបានបញ្ចប់ទៅវិញ។

កថាខណ្ឌ១៥៩៦៖ រហូតដល់ពេលបានចាប់ខ្លួន អៀង សារី បានរស់នៅទីក្រុងភ្នំពេញ និងប៉ៃលិនជាមួយភរិយារបស់គាត់។

[១១:៥៦:២៦]

កថាខណ្ឌ១៥៩៧៖ ក្នុងបរិបទនៃការធ្វើកោសល្យវិច័យចិត្តសាស្ត្រ ដែលបង្គាប់ដោយសហចៅក្រមស៊ើបអង្កេត អ្នកជំនាញបានប្រាស្រ័យទាក់ទងជាមួយ អៀង សារី។ អ្នកជំនាញបានសន្និដ្ឋានថា អៀង សារី គ្មានបញ្ហាផ្លូវចិត្តនោះទេ ដោយបានលើកឡើងថា៖ "លោក អៀង សារី គឺជាមនុស្សចាស់វ័យ៨៥ឆ្នាំ ដែលដំណើរការសតិបញ្ញារបស់គាត់បង្ហាញនូវភាពស៊ីសង្វាក់គ្នា ជាមួយនឹងវ័យរបស់គាត់។ រីឯការចងចាំបានយូរជាងរបស់គាត់ បង្ហាញថា ល្អគួរឲ្យកត់សម្គាល់។ គាត់មិនបានបង្ហាញអំពីរោគសញ្ញានៃជំងឺផ្លូវចិត្តនាពេលបច្ចុប្បន្ននោះទេ។ ទោះបីជាវាបង្ហាញយ៉ាងច្បាស់ថាគាត់បានធ្វើទុក្ខដោយសារជំងឺ ដោយសារការប៉ះទង្គិចផ្លូវចិត្ត តាមរយៈបទពិសោធន៍ជីវិតជាច្រើនឆ្នាំរបស់គាត់ក៏ដោយ។ ទោះបីជាយ៉ាងណាក៏ដោយ គាត់មិនបង្ហាញអំពីរោគវិនិច្ឆ័យនៃជំងឺផ្លូវចិត្តណាមួយឡើយ ហើយតាមការយល់ឃើញរបស់យើងខ្ញុំ សម្រាប់មនុស្សដែលមានវ័យដូចគាត់នេះ គាត់មានសុខភាពផ្លូវចិត្តមាំមួនហើយ។ យើងខ្ញុំបានកំណត់បង្ហាញអំពីភាពចុះខ្សោយផ្នែកសតិបញ្ញាជាមធ្យម ជាពិសេសនៅត្រង់ចំណុចនៃការចងចាំថ្មីៗនេះ ដែលយើងខ្ញុំជឿជាក់ថា មានលក្ខណៈស្របទៅនឹងវ័យរបស់ជនត្រូវចោទ។ តាមការពិនិត្យ

យើងខ្ញុំមិនជឿថា បញ្ហានេះនឹងធ្វើឲ្យលោក អៀង សារី មានសភាពចុះខ្សោយរហូតមិនអាចមានលទ្ធភាពប្រឈមមុខនឹងការជំនុំជម្រះក្តីបាននោះឡើយ។

[១១:៥៨:២០]

<u>ផ្នែកទី៣៖ ខៀវ សំផន</u>

កថាខណ្ឌ១៦០១៖ សកម្មភាពនយោបាយរបស់ ខៀវ សំផន រហូតដល់ឆ្នាំ១៩៧៩ ត្រូវបានវិភាគនៅក្នុងផ្នែកពាក់ព័ន្ធនឹងបុគ្គល ដែលដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យនៅក្នុងដីកាដំណោះស្រាយនេះ។

កថាខណ្ឌ១៦០២៖ បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ការភៀសខ្លួនរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា និងការរុលទៅមុខរបស់កងទ័ពវៀតណាម ខៀវ សំផន បានបន្តគាំទ្រសកម្មភាពនានារបស់បក្សកុម្មុយនីស្តកម្ពុជា ដោយគាត់រស់នៅប្រទេសកម្ពុជាជាមួយ ប៉ុល ពត ហើយបានជួយដឹកនាំការងារជម្លោះជាមួយវៀតណាម។ ការចូលរួមរបស់ ខៀវ សំផន ស្តែងឡើងតាមសកម្មភាពនានា ដូចជា ការចុះពិនិត្យ និងការបែងចែកផ្គត់ផ្គង់ដល់កងទ័ព និងតំណាងកម្ពុជាប្រជាធិបតេយ្យក្នុងឋានៈជាប្រធានគណៈប្រធានរដ្ឋ។ ក្នុងនាមជាប្រធានគណៈប្រធានរដ្ឋ នាយករដ្ឋមន្ត្រីកម្ពុជាប្រជាធិបតេយ្យ និងជាប្រធានបណ្តោះអាសន្ននៃរណសិរ្សស្នេហាជាតិប្រជាធិបតេយ្យ ខៀវ សំផន បានចូលរួមក្នុងការបង្កើតសម្ព័ន្ធភាពជាមួយនឹងក្រុមចលនាតស៊ូផ្សេងៗ ដូចជារណសិរ្សរំដោះប្រជាជនខ្មែរ និងក្រុមរាជានិយម។

[១២:០០:០៥]

ជាមួយនឹងការបង្កើតរដ្ឋាភិបាលចម្រុះរបស់កម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៨២ ខៀវ សំផន បានក្លាយជាអនុប្រធានទទួលបន្ទុកកិច្ចការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ។ រវាងឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៦ ខៀវ សំផន បានបំពេញបេសកកម្មការទូតនានា និងបានតំណាងកម្ពុជានៅអង្គការសហប្រជាជាតិ។ នៅខែសីហា ឆ្នាំ១៩៨៥ នៅពេលដែលមានការសម្រេចបង្កើតគណបក្សកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន ត្រូវបានតែងតាំងជាប្រធាន។

នៅក្នុងឆ្នាំ១៩៨៩ ក្នុងឋានៈជាតំណាងកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានចូលរួមក្នុងសន្និសីទអន្តរជាតិទីក្រុងប៉ារីស ហើយនៅឆ្នាំ១៩៩១ គាត់បានមានវត្តមាននៅក្នុងពិធីចុះហត្ថលេខាកិច្ចព្រមព្រៀងទីក្រុងប៉ារីស រួមជាមួយនឹង សុន សេន។ ដូច្នេះ ខៀវ សំផន បានធ្វើដំណើរទស្សនកិច្ចផ្លូវការមួយមកទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៩១ ដែលនៅពេលនោះ គាត់ត្រូវបានវាយប្រហារដោយបាតុករមួយ

ក្រុម។ ខៀវ សំផន នៅតែបានរក្សាសម្ព័ន្ធភាពនយោបាយជាមួយ ប៉ុល ពត រហូតដល់មានការចាប់ ប៉ុល ពត ក្នុងឆ្នាំ១៩៩៧ ដោយពួកខ្មែរក្រហម។ ទោះបីជា ខៀវ សំផន បានបដិសេធទូទៅចំពោះរាល់ការពាក់ព័ន្ធជាមួយនឹងឧក្រិដ្ឋកម្មនានា ដែលប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ ខៀវ សំផន បានទទួលស្គាល់នៅក្នុងខែមេសា ឆ្នាំ១៩៨៦ ថា ខ្មែរក្រហមបានធ្វើខុស។

កថាខណ្ឌ១៦០៣៖ ខៀវ សំផន បានរស់នៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ រហូតដល់គាត់បានចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹង នួន ជា នៅខែធ្នូ ឆ្នាំ១៩៩៨។ ខៀវ សំផន បានរស់នៅទីក្រុងប៉ៃលិន។

[១២:០២:៣៧]

កថាខណ្ឌ១៦០៤៖ ខៀវ សំផន មិនចង់ជួបអ្នកជំនាញផ្នែកចិត្តសាស្ត្រ ដែលទទួលបន្ទុកពិនិត្យ និងផ្តល់យោបល់លើសម្បទារបស់គាត់ក្នុងការទទួលយកការជំនុំជម្រះ ដោយបញ្ជាក់ថា គាត់មិនមានបញ្ហាផ្លូវចិត្តនោះទេ ហើយគាត់មិនព្រមទទួលយកការពិនិត្យឡើយ។ ដូច្នេះអ្នកជំនាញបានធ្វើការបញ្ជាក់ថា សំណុំឯកសារពេទ្យរបស់ ខៀវ សំផន មិនបង្ហាញអំពីប្រវត្តិនៃបញ្ហាផ្លូវចិត្តពីអតីតកាលឡើយ។

បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ លោក ផារី។

ឥឡូវនេះ ដល់ពេលសម្រាកពិសាអាហារថ្ងៃត្រង់ហើយ ហើយមុននឹងប្រកាសសម្រាកអង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនថា នៅរសៀលនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីសាក្សីដែលមានរហស្សនាម TCW-428។ ហើយដើម្បីដោះស្រាយបញ្ហាមួយចំនួនដែលមានការជំទាស់ របស់ភាគីទៅលើបញ្ហានៃកិច្ចដំណើរការស្ដាប់សក្ខីកម្មសាក្សីរូបនេះ នៅរសៀលនេះ អង្គជំនុំជម្រះសម្រេចផ្ទាល់មាត់លើសំណើសុំរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន៨៧(៤) ក្នុងការដាក់បទសម្ភាសន៍របស់ ស៊ី.ឌី.ខេម ទាក់ទងនឹងសាក្សីដែលមានរហស្សនាម TCW-428 គឺឯកសារ 233/1 ដូចខាងក្រោមនេះ៖

[១២:០៤:១៤]

អង្គជំនុំជម្រះសាលាដំបូងទទួលសំណើមួយពីសហព្រះរាជអាជ្ញា ដើម្បីដាក់ទៅក្នុងសំណុំរឿងក្នុងប្រភេទជាឯកសារថ្មីនូវបទសម្ភាសន៍ជាមួយនឹងសាក្សីដែលមានរហស្សនាម TCW-428 ដែលបាន

ធ្វើសម្អាសកាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១១ កន្លងទៅ។ អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភស្តុតាងថ្មី លុះត្រាតែភស្តុតាងនោះ អាចត្រូវបានចាត់ទុកថា មានប្រយោជន៍ក្នុងការស្វែងរកការពិត ប្រសិនបើមានការបង្ហាញជាបឋមឲ្យឃើញនូវភាពពាក់ព័ន្ធ ភាព អាចជឿជាក់បាន និងយថាភាពនៃភស្តុតាង ដូចដែលតម្រូវដោយវិធាន៨៧ អនុវិធាន៣ នៃវិធានផ្ទៃក្នុង។

អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង និងដោយឆ្លុះបញ្ចាំងពីយុត្តិសាស្ត្រ ដែលត្រូវបាន បង្កើតឡើង នៅកម្រិតអន្តរជាតិផងនោះ អង្គជំនុំជម្រះបានតម្រូវជាទូទៅដល់ភាគី ដែលស្នើសុំឲ្យ បង្ហាញដល់អង្គជំនុំជម្រះ ជាភស្តុតាង ដែលបានស្នើនោះមិនអាចរកបានទេ នៅមុនពេលចាប់ផ្តើមការ ជំនុំជម្រះ និង/ឬ បន្ទាប់ពីបានបំពេញការងារយ៉ាងយកចិត្តទុកដាក់ហើយ ក៏នៅតែមិនអាចរកបានទៀត ឯកសារ E190។ ទោះបីជាកិច្ចសម្ភាសន៍នេះ ត្រូវបានធ្វើឡើងក្រោយពេលបើកការជំនុំជម្រះក៏ដោយ ក៏ ប៉ុន្តែកិច្ចសម្ភាសន៍នេះមានអត្ថិភាព អាចរកបាននៅពេលអង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងទៅ ភាគីកាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ ថាសាក្សី TCW-428 អាចត្រូវបានកោះហៅ មកផ្តល់សក្ខីកម្ម នៅក្នុងវគ្គដំបូងនៃសវនាការ ក្នុងសំណុំរឿង០០២ ឯកសារ E131/1.1។

[១២:០៦:៣០]

សំណើរបស់សហព្រះរាជអាជ្ញាខាងលើនេះ ត្រូវបានធ្វើឡើងជិតមួយឆ្នាំ ក្រោយពីសហព្រះរាជ អាជ្ញា បានទទួលការជូនដំណឹងថា សាក្សីរូបនេះ អាចនឹងមកផ្តល់សក្ខីកម្ម ពោលគឺមុនពេលបន្តិច ប៉ុណ្ណោះ នៃការត្រៀមមកដល់ មកផ្តល់សក្ខីកម្មរបស់សាក្សីរូបនេះ នៅចំពោះមុខអង្គជំនុំជម្រះ។ ជាង នេះទៅទៀត រហូតដល់មកទល់នឹងថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២ ឯកសារនៃកិច្ចសម្ភាសន៍នេះ នៅតែជា ភាសាខ្មែរប៉ុណ្ណោះ មុនពេលចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សី។ ការណ៍នេះធ្វើឲ្យភាគី និងអង្គជំនុំជម្រះជួប នូវការលំបាកក្នុងការពិនិត្យឲ្យបានដិតដល់ទៅលើខ្លឹមសារ នៃឯកសារ ដែលមានកម្រាស់រហូតដល់ទៅ ៤០ទំព័រ។

ដោយយោងទៅលើហេតុផលទាំងនេះ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា សំណើរបស់សហ ព្រះរាជអាជ្ញាមិនត្រូវបានធ្វើឡើងស្របតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងឡើយ។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីចៅក្រម។ ខ្ញុំមានសំណើពីរព្រឹកនេះ។ ទី១ ទាក់ទងទៅនឹងអ្វីដែលបានកើតឡើងនៅក្នុងការអាន ដីកាដំណោះស្រាយកូនក្ដីរបស់ខ្ញុំ លោក នួន ជា ចង់ធ្វើយោបល់ជាសាធារណៈទៅលើខ្លឹមសារទាំងនោះ ហើយគាត់ចង់ធ្វើសេចក្ដីថ្លែងការណ៍នេះ នៅក្នុងសវនាការសាធារណៈ។ ហើយខ្ញុំបានទទួលដំណឹងថា គាត់ឈឺក្បាល ហើយឈឺខ្នង ហើយនិងគាត់មិនអាចផ្ចង់អារម្មណ៍បានទេ ហើយខ្ញុំសូមស្នើដូចខាងក្រោមនេះថា ដើម្បីសុំពេល១៥មីនុត ក្រោយពីពិសាបាយថ្ងៃត្រង់ហើយ គាត់ត្រឡប់មកវិញ បន្ទាប់ពីពេលនោះ ហើយខ្ញុំនឹងជូនដំណឹងតុលាការថា គាត់នឹងប្រើពេលតែ១៥នាទី ឬលើសបន្តិច ហើយសូមអនុញ្ញាតឲ្យគាត់ត្រឡប់ទៅបន្ទប់ខាងក្រោមវិញ ដើម្បីតាមដានសវនាការ ដើម្បីអាចទទួលយកបាន ហើយនេះជាសំណើរបស់យើងខ្ញុំសម្រាប់ពេលល្ងាចនេះបាទ។

[១២:០៨:៥៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:១៥:១០]

**ប្រធានអង្គជំនុំ៖**

ឆ្លើយតបទៅនឹងសំណើសុំរបស់លោក នួន ជា ដែលធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់គាត់ លើសំណើទី១ សុំធ្វើការកត់សម្គាល់តបទៅនឹងបណ្ដាកថាខណ្ឌទាំងឡាយ ដែលក្រឡាបញ្ជីបានអាននូវអង្គហេតុដែលបានចោទប្រកាន់ទៅលើជនជាប់ចោទ ដែលខ្លួនថា អះអាងថា ចំណាយរយៈពេល១៥នាទីនោះ អង្គជំនុំជម្រះនឹងពិចារណាសម្រេចនៅពេលសមស្របខាងមុខនេះ។ ហើយកិច្ចការនេះ អង្គជំនុំជម្រះនឹងកំណត់ពេលវេលានៅពេលព្រឹកណាមួយ បន្ទាប់ពីអង្គជំនុំជម្រះស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-428 ចប់។ នេះជាសំណើសុំទី១។

សំណើសុំទី២ គឺអង្គជំនុំជម្រះបានស្ដាប់នូវសំណើសុំរបស់លោក នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលនៅរសៀលនេះ ដោយមូលហេតុបញ្ហាសុខភាពនោះ គឺអង្គជំនុំជម្រះសម្រេចយល់ព្រម អនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀល

នេះ ដោយ នួន ជា បានលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះឲ្យក្រុមមេធាវីការពារក្តី នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិមិនចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬស្នាមផ្តិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់ ពីជនជាប់ចោទ នួន ជា។

[១២:១៦:៤៧]

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចតាមដាន អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួន ស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈនៃកិច្ចដំណើរការសវនាការនៅពេលរសៀលនេះ។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និង លោក ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះ ទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលបានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែក លោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី។

មានបញ្ហាអីទៀត?

[១២:១៧:៣៦]

**លោក អេនគ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ មានបញ្ហាចំណុចមួយទៀត ខ្ញុំចង់លើកឡើង គឺថាមិនទាក់ទងនូវបញ្ហានេះទេ គឺទាក់ទងទៅនឹងសាក្សីបន្ទាប់ ដែលនឹងត្រូវកោះមក ដោយសារថាពេលម៉ោង គឺថាសមស្រប គឺថាខ្ញុំសុំឲ្យការអនុវត្តនោះ បន្ទាប់ពីអាហារបាយថ្ងៃត្រង់។ ហើយបើសិនជាសំណើនោះ ត្រូវបានអនុញ្ញាតឲ្យធ្វើក្រោយពីសាក្សីនេះ គឺថា -- ហើយខ្ញុំសូមពេលតែ៥នាទី ដើម្បីធ្វើសំណើល្ងាចនេះតែប៉ុណ្ណោះ លោកប្រធាន។

[១២:១៨:១០]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:១៩:១០]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអាចសង្ខេបនូវសំណើសុំរបស់លោកបានដែរទេ ព្រោះយើងបានជម្រាបលោកច្រើន

លើកច្រើនសាហើយ ថាសំណើរបស់លោកត្រូវតែប្រាប់អំពីសង្ខេបនូវខ្លឹមសារ និងគោលបំណងនៃការធ្វើសំណើនោះ ដើម្បីឲ្យអង្គជំនុំជម្រះពិចារណាសម្រេចបញ្ហានេះជាមុន។ ទាំងការអនុញ្ញាត ទាំងកំណត់ពេលវេលា។

**លោក អេនគ្រូ អ៊ីនូហ្វ៊ី៖**

លោកចៅក្រម ខ្ញុំអាចធ្វើសំណើនៅពេលនេះបាន ដូចដែលខ្ញុំនឹងប្រើពេលតែ៥នាទីតែប៉ុណ្ណោះ។ ខ្ញុំឃើញថា ពេលក្រោយម៉ោងដប់ពីរហើយ ប៉ុន្តែខ្ញុំចង់ធ្វើឥឡូវនេះ។

**ប្រធានអង្គជំនុំ៖**

មិនអីទេ យើងអនុញ្ញាត ប៉ុន្តែសូមឲ្យលោកកំណត់អំពីកម្មវត្ថុនៃបញ្ហាដែលលោកលើកហ្នឹងឲ្យច្បាស់លាស់ជាមុនសិន ដោយសង្ខេបជាមុនសិន ដើម្បីឲ្យអង្គជំនុំជម្រះពិចារណាថាអនុញ្ញាត ឬមិនអនុញ្ញាត។ នេះជាបញ្ហាជាមុន។ អ៊ីចឹងពីរដំណាក់កាល លោកនិយាយសង្ខេបអំពីប្រធានបទហ្នឹងជាមុនសិន ចំណងជើងនៃបញ្ហាសំណើជាមុនសិន បន្ទាប់មកយើងនឹងសម្រេចថាអនុញ្ញាត ឬមិនអនុញ្ញាត ហើយឲ្យលោកចំណាយពេលវេលាប៉ុន្មានដែលសមស្រប។

[១២:២០:៤៦]

**លោក អេនគ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ នេះជាសេចក្ដីសង្ខេបទេ អ្វីដែលយើងហៅថានៅ -- ហៅថាសំណើទាក់ទងទៅនឹងបញ្ហានេះ គឺជាៗសំណើផ្ទាល់មាត់ដែលធ្វើឡើងមុនដែលសក្ខីកម្មសាក្សីត្រូវបានផ្ដល់ដើម្បីដកចេញនូវខ្លឹមសារនៃសក្ខីកម្មខ្លះ ជានីតិវិធីដែលច្បាប់អនុញ្ញាត គឺទាក់ទងទៅនឹងចម្លើយរបស់សាក្សី។ ជាសមស្របយើងអាចធ្វើពេលនេះ គឺថាឯកសារ E3/80 នោះគឺជាចម្លើយសាក្សីរបស់ការិយាល័យសហចៅក្រមស៊ើប -- សហព្រះរាជអាជ្ញា គឺឯកសារ TCW-428 គឺទាក់ទងទៅនឹងផ្នែកមួយតូចនៅក្នុងឯកសារនេះ កត់ត្រាក្នុងតុលាការនេះ ERN នៅក្នុងឯកសារនេះ គឺទំព័រទី៥ នៃអត្ថបទជាភាសាអង់គ្លេសគឺ 440049167 (ស៊ីក), ខ្មែរ ERN 00486472, បារាំង ERN 00509787 ដល់ 788។ ខ្ញុំគិតថា ខ្ញុំអានបន្ទាត់មួយគឺថាអាចនឹងឃើញច្បាស់ហើយ គឺថាសំណើរបស់ខ្ញុំទាក់ទងនឹងបញ្ហាហ្នឹង ខ្ញុំសូមអាន។ នេះជាសំណើរបស់អ្នកស៊ើបអង្កេតម្នាក់។ ខ្ញុំមិនៗមានចេតនាថានឹងដាក់ឈ្មោះគាត់ទេ ខ្ញុំគ្រាន់តែអានចេញពីចម្លើយនេះ ចម្លើយសារភាពរបស់ ឌួ ដេត ហៅ ស៊ី បញ្ជាក់ថា ដកស្រង់ខ្លឹមសារនៃចម្លើយសារភាពនោះ គឺជាខ្លឹមសារគឺត្រូវបានយកទៅដាក់ឲ្យសាក្សី ដោយភ្នាក់ងាររបស់

ការិយាល័យចៅក្រមស៊ើបអង្កេត ហើយនេះជាចំណុចសំខាន់ដែលខ្ញុំលើកឡើងថាជាស្ថាប័នតុលាការដែលផ្អែកលើខ្លឹមសារនៃចម្លើយសារភាពដែលមានបញ្ហា ច្បាប់មិនអនុញ្ញាតឲ្យប្រើ។

[១២:២៣:០៣]

ដូច្នេះហើយ ខ្ញុំសូមបញ្ជាក់ឲ្យតុលាការជ្រាបច្បាស់ក្នុងឯកសារតុលាការថា ទោះបីថាមានការហាមខានថា មិនឲ្យប្រើនូវចម្លើយសារភាពដោយអំពើទារុណកម្មនេះដោយអនុសញ្ញាអន្តរជាតិក៏ដោយ ក៏មន្ត្រីនោះបានយកមកប្រើដែរ ហើយខ្ញុំសូមរំឭកតុលាការជ្រាបថា ខ្ញុំសូមជម្រាបដល់សាធារណជនឲ្យជ្រាបថា នេះជាការអនុវត្តបែបនេះ ការពឹកផ្អែកទៅលើភស្តុតាងដែលបានដោយអំពើទារុណកម្មនេះ គឺៗត្រូវបានតុលាការហាមឃាត់ទៅតាមផ្លូវច្បាប់នោះហើយ នៅក្នុងករណីជាច្រើនផងដែរ។

នៅក្នុងឯកសារនេះ យើងពិនិត្យឃើញថា ការិយាល័យសហចៅក្រមស៊ើបអង្កេត គឺថាបានដកដាកចេញអំពីវិធានដែលបានសម្រេច គឺសេចក្ដីសម្រេចរបស់តុលាការ។ ជាពិសេសគឺខ្ញុំមិនៗតវ៉ាអំពីវិការៈនៃការស៊ើបអង្កេតទេ ប៉ុន្តែនេះជាការហាមប្រាមរបស់អនុសញ្ញាអន្តរជាតិដែលទាក់ទងទៅនឹងខ្លឹម-សារជាសារធាតុនៃចម្លើយនេះ។ ដូច្នេះខ្ញុំស្នើថា នេះជាបញ្ហាសារធាតុ ទាក់ទងទៅនឹងរបៀបដែលអ្នកស៊ើបអង្កេត ឬក៏ស្ថាប័នស៊ើបអង្កេតដែលបានអនុវត្តនោះ។

[១២:២៤:២២]

ទាក់ទងទៅនឹងសំណើរបស់ខ្ញុំដើម្បីឲ្យច្បាស់មិនមែនជាសំណើសុំមោឃភាពទេ ដូចដែលខ្ញុំលើកឡើងគឺថាជាសំណើសុំក្នុងករណីពិសេស គឺសំណើសុំដើម្បីដកចេញនូវផ្នែកខ្លះនៃចម្លើយសារភាពនេះ នៃចម្លើយនេះដើម្បីទាក់ទងនឹងខ្លឹមសារដែលយកមកពីចម្លើយសារភាពដែលបានដោយអំពើទារុណកម្ម។ នេះហើយជាបញ្ហាដែលខ្ញុំស្នើ អ្វីដែលចង់បានដំណោះស្រាយនោះ គឺយើងខ្ញុំស្នើថាផ្នែកដែលខ្ញុំបានអានជូននេះ នៅក្នុងខាងដើមនៃទំព័រ៥ នេះ គឺ -- ហើយសំណួរមួយចំនួន ដែលបន្ទាប់ពីខ្លឹមសារនោះមកនោះគប្បីតែលុបចេញពី -- យកមកប្រើ គឺតុលាការ ចៅក្រម និងភាគីមិនត្រូវមកសំណួរទាំងអស់នេះមកដេញដោលនោះទេ។ ហើយយើងខ្ញុំស្នើថា ផ្នែកនេះចាប់ពីសំណួរនិងចម្លើយ១៦ នៅលើទំព័រនេះរហូតទៅដល់សំណួរ-ចម្លើយ២០ គប្បីតែដកចេញអំពីឯកសារនេះ។ ហើយខ្ញុំសង្ឃឹមថា នេះហើយជាមូលហេតុគឺ-- មូលហេតុគឺមានលក្ខណៈច្បាស់ គឺដោយយោងទៅរកយុត្តាធិការអ្វីដែលយើងហៅថាជាភស្តុតាងប្រតិឃាដ គឺថាយើងមាន គឺជាការបំពានច្បាប់ ដោយសារមានឯកសារច្បាប់ហើយគឺច្បាប់ហាម គឺថាដូចយើងយកភស្តុតាងដែលមានប្រលាក់ប្រឡូក គឺថាដូចជាយើងយកផ្លែឈើដែល

ពុលមកហូបដូច្នោះដែរ--

[១២:២៦:០៤]

**ប្រធានអង្គជំនុំ៖**

លោកនៅត្រូវការចំណាយពេលវេលាប៉ុន្មានទៀត ពីព្រោះបញ្ហាពាក់ព័ន្ធជាមួយនឹងពេលវេលា ដែលលោកសុំ ហើយនិង ឌី.វី.ឌី ដែលអស់ហើយ ត្រូវផ្លាស់ ឌី.វី.ឌី ថ្មី។ លោកនិយាយបញ្ហាឲ្យច្បាស់ ពីព្រោះហាក់ដូចកាន់តែវែងលើសពីអ្វីដែលសុំ៥មីនុតហ្នឹងទៅទៀត។ តើលោកត្រូវការចំណាយពេលវេលាប៉ុន្មានទៀត ដើម្បីយើងសម្រេចអំពីការផ្អាក ឲ្យប្តូរ ឌី.វី.ឌី ជាមុនសិន។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ដោយសង្ខេប គឺថាសំណើរបស់ខ្ញុំ ខ្ញុំគ្រាន់តែអាចនេះគឺថា គឺមានតន្ត្រីពីរ គឺថាមួយអាក្រក់ មួយមិនល្អ នេះហើយជាការប្រៀបធៀបនេះ។ នេះជាភស្តុតាងមិនល្អ ហើយតុលាការមិនគប្បីយកមកប្រើទេ។ នេះគឺជាសំណើរបស់ខ្ញុំ គឺសុំដកហូតផ្នែកមួយចំនួននោះ--

[១២:២៧:០១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់ ហើយយើងស្តាប់បានហើយបញ្ហានេះ ហើយទោះបីលោកលើកឡើងថាមិនមែនជាការមោឃៈនូវកិច្ចដំណើរការនីតិវិធីក៏ដោយ ប៉ុន្តែកិច្ចការនេះគួរតែត្រូវបានប្រើប្រាស់នៅក្នុងអំឡុងពេលនៃ ឲ្យបានមុនដីកាដំណោះស្រាយដែលចេញ។ នោះជារឿងមួយ។ ប៉ុន្តែលោកក៏បានលើកឡើងហើយ ហើយបញ្ហានេះក៏អង្គជំនុំជម្រះជួបប្រទះ ហើយមានបទពិសោធន៍ក្នុងការជួបប្រទះតាំងពីសំណុំរឿង០០១ រហូតដល់សំណុំរឿង០០២។ អ៊ីចឹងឱកាសក្នុងការដេញដោលនេះ លោកទំនងជាអាចមានទាំងសិទ្ធិក្នុងការជំទាស់ទៅលើកិច្ចនីតិវិធីនៃកិច្ចដំណើរការសវនាការសំណុំរឿងរបៀបនេះផង។

អង្គជំនុំជម្រះប្រកាសសម្រាក!

*(សវនាការសម្រាកពីម៉ោង ១២:២៧ នាទី ដល់ម៉ោង ១៣:៤៦ នាទី)*

[១៣:៤៦:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងកោះអញ្ជើញសាក្សីដែលមានរហស្សនាម TCW-428 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីឆ្លើយតបទៅនឹងសំណើសុំរបស់លោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ដែលបានធ្វើចុងម៉ោងកាលពីព្រឹកមិញ ហើយនិងធ្វើការបញ្ជាក់កត់សម្គាល់ នូវបាតុភាពមួយ ដែលអង្គជំនុំជម្រះសម្រេច សម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ហើយ ហើយមេធាវីរូបនោះ នៅតែចុចក្បាលមីក្រូនិយាយ ដើម្បីជម្រាបជូនភាគី និងសាធារណជនលើបញ្ហានេះឲ្យបានច្បាស់លាស់ ជៀសវាងមានការភ័ន្តច្រឡំលើបញ្ហានេះផ្សេងៗទៅថ្ងៃមុខទៀត។

សូមអញ្ជើញលោកស្រីចៅក្រម!

[១៣:៤៨:០២]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ សូមទោស ដែលខ្ញុំចុចមីក្រូ ខ្ញុំបើកអត់បាន។

លោកប្រធានបានបញ្ជាក់រួចមកហើយថា បន្ទាប់ពីលោកប្រធានបានផ្អាកសវនាការ ដើម្បីសម្រាកអាហារថ្ងៃត្រង់ គឺលោក អ៊ីនូហ្ស៊ី នៅតែបន្តធ្វើការថ្លែងមតិ ហើយយើងសូមធ្វើការបញ្ជាក់នៅពេលនេះថា សំណើសុំជាផ្ទាល់មាត់ដែលលោកបានធ្វើនេះ ត្រូវបានយើងពិចារណារួចទៅហើយ។ ដូច្នេះហើយលោកមិនចាំបាច់ត្រូវធ្វើការយល់ ឬក៏ដាក់បង្ហាញអ្វីបន្ថែមទៀត។ ដូច្នេះលោកក៏មិនចាំបាច់ត្រូវធ្វើការងារបែបនេះដែរ។ អង្គជំនុំជម្រះបានពិចារណា អំពីទឡ្ហីករណ៍ផ្ទាល់មាត់ ដែលលោកបានលើកឡើងពាក់ព័ន្ធទៅនឹងចម្លើយសារភាពនៅស-២១ ដែលត្រូវបានដកស្រង់ នៅក្នុងចម្លើយ -- នៅក្នុងការស្តាប់ចម្លើយសាក្សី TCW-428 គឺ E លេខ E3/80។ អង្គជំនុំជម្រះបានកត់សម្គាល់នៅនាទីចុងក្រោយបំផុតនៃការដាក់សំណើសុំនេះ គឺយើងដឹងថា លោកមេធាវីបានដឹងអំពីបញ្ហានេះតាំងពីមុន មុនពេលឈប់សម្រាកបាយថ្ងៃត្រង់នេះ។ ដោយសារតែលោកមេធាវីបានកត់សម្គាល់រួចទៅហើយ អង្គជំនុំជម្រះក៏យល់ស្រប ហើយយល់ស្របជាឯកច្ឆន្ទថា យើងសម្រេចថា ចម្លើយសារភាពដែលទទួលបានដោយការធ្វើទារុណកម្ម ដែលស្របតាមអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម មិនអាចធ្វើជាមូលដ្ឋាន នៃការចោទសួរ ឬក៏ជាភស្តុតាងឡើយ។

[១៣:៤៩:៥៨]

ដូច្នេះអង្គជំនុំជម្រះសូមជម្រាបដល់ភាគីនានាឲ្យបានជ្រាបថា មិនអនុញ្ញាតឲ្យមានការចោទសួរ

សំណួរពាក់ព័ន្ធទៅនឹងចម្លើយសារភាព ហើយក៏មិនប្រើប្រាស់នូវព័ត៌មានទាំងអស់នេះនៅក្នុងសាលក្រមដែរ។ ដូច្នេះ នេះគឺជាអ្វីដែលអង្គជំនុំជម្រះបានសម្រេចជារហូត -- ជារៀងរហូតមកហើយ។ ហើយយើងសង្ឃឹមថា យើងនឹង -- ហើយភាគីនឹងយល់ច្បាស់អំពីបញ្ហានេះអំពីកិច្ចដំណើរការនៃនីតិវិធីដែលយើងអនុវត្តនៅទីនេះ។ គឺគោលការណ៍ច្បាប់ដែលយើងប្រើប្រាស់នោះ គឺយើងគោរពទៅតាមគោលការណ៍ទាំងអស់នេះ ហើយយើងមិនមានការលើកលែង ឬមិនមានការទូទាត់សងអ្វីនោះឡើយ។ ហេតុដូច្នេះហើយ សំណើសុំនេះត្រូវបានអង្គជំនុំជម្រះពិចារណា។ ហើយជាចុងក្រោយគឺវាបានបញ្ជាក់ច្បាស់ថា អង្គជំនុំជម្រះបានសម្រេចជាឯកច្ឆន្ទថា មិនចាំបាច់ឲ្យមានការដាក់ស្នើសុំពីភាគីនានាទាក់ទងទៅនឹងសំណើនៅក្នុងថ្ងៃនេះទេ។

**លោក អេនទ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកស្រីចៅក្រម ខាតរ៉ាយច៍។ ខ្ញុំសូមលើកនូវចំណុច៣ ទី១១ គឺថា--

[១៣:៥១:១៨]

**ចៅក្រម ស៊ីលវៀ ខាតរ៉ាយច៍៖**

លោកដឹងថាការសម្រេចរបស់យើងគឺបានធ្វើស្របគ្នានេះ ហើយៗខ្ញុំកត់សម្គាល់ឃើញថាអំពីការលើកឡើងអំពី ភាពយុត្តិធម៌របស់លោក។

**លោក អេនទ្រូ អ៊ីនូហ្វ៊ី៖**

ខ្ញុំគ្រាន់តែចង់បង្ហាញពីការកត់ត្រារបស់ខ្ញុំ។

**ចៅក្រម ស៊ីលវៀ ខាតរ៉ាយច៍៖**

គឺមិនចាំបាច់ធ្វើការកំណត់ត្រានៅក្នុងប្រតិចារឹកនោះឡើយ គឺថាយើងបានចេញសេចក្ដីសម្រេចហើយយើងក៏ផ្ដល់ឱកាសឲ្យលោកធ្វើការដាក់នូវសំណើ។ ដូច្នេះបើសិនជាលោកចង់អាចលោកធ្វើការប្ដឹងសាទុក្ខបាន គឺយើងផ្ដល់ឱកាសជូនលោក។

សូមអរគុណលោកប្រធាន តើលោកប្រធានមានអ្វីចង់បន្ថែមដែរឬទេ?

[១៣:៥១:៥៨]

**លោក អេនទ្រូ អ៊ីនូហ្វ៊ី៖**

ដោយសារតែនេះជាបញ្ហាបន្ទាន់ ដូច្នេះយើងគិតថានេះជាសំណើសុំដែលយើងដាក់ជាលក្ខណៈបណ្ដោះអាសន្ន វាមិនមែនសំណើរយៈពេល ៦ខែ ឬក៏១ឆ្នាំអ្វីនោះឡើយ។ ដោយសារហេតុផលទាំងអស់

នេះខ្ញុំសូមលើកនូវចំណុចតូចៗចំនួន២។ ទី១ ខ្ញុំគិតថាសំណើរបស់យើងគឺថា ក្របខ័ណ្ឌផ្លូវច្បាប់ដែលយើងបានដាក់នៅក្នុងតុលាការនេះ គឺបានបង្ហាញច្បាស់ថា ជាការដាក់សំណើសុំតាមរយៈអត្ថន័យ។ ហើយការដាក់សំណើសុំនេះមិនត្រូវបានហាមឃាត់ដោយវិធានណាមួយឡើយ។ ដូច្នេះ ខ្ញុំទទួលយកនូវការសម្រេចនេះ។ ទី២ ចំពោះការឆ្លើយតប និងការដាក់ចម្លើយតបហ្នឹង គឺអនុញ្ញាតឲ្យភាគីដាក់នូវ -- បង្ហាញនូវគោលជំហររបស់ខ្លួននៅក្នុងកំណត់ត្រាប្រតិចារឹក ដូចដែលមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏ព្រះរាជអាជ្ញាបានធ្វើអ៊ីចឹង។ ខ្ញុំយល់ថា មតិចុងក្រោយរបស់លោកប្រធានមុនពេលឈប់សម្រាកគឺបដិសេធនូវសំណើសុំនេះ ដោយសារតែគាត់គិតថា ជាសំណើសុំដែលនិយាយអំពីៗ ឱនភាព ឬក៏វិការៈនៃកិច្ចដំណើរការនីតិវិធី។ ដូច្នេះខ្ញុំគិតថា អ្វីដែលលើកឡើងគឺវាហាក់ដូចជាការបដិសេធ ប៉ុន្តែខ្ញុំសូមថ្លែងអំណរគុណដែលអង្គជំនុំជម្រះបានសម្រេច ទៅ -- ដែលបានធ្វើរួចមកហើយនេះ។ ដូច្នេះអ្វីដែលខ្ញុំបានលើកឡើងស្នើឡើងគឺវាស្របទៅតាមក្របខ័ណ្ឌច្បាប់ ហើយភាគីទាំងអស់គួរតែមានសិទ្ធិនៅក្នុងការពិចារណាក្នុងការពិភាក្សាដេញដោលទាំងអស់នេះ។ សូមអរគុណ។

[១៣:៥៣:៤១]

**ប្រធានអង្គជំនុំ៖**

លោកមើលឡើងវិញ ប្រហែលជាលោកច្រឡំហើយ យើងមិនបានសម្រេចចេញសម្រេចទេ យើងគ្រាន់តែធ្វើការកត់សម្គាល់នូវសំណើសុំរបស់លោក ដោយលោកខ្លួនឯងបានបង្ហាញច្បាស់លាស់ថា លោកមិនធ្វើប្ដឹងសុំមោឃភាពទេ។ យើងគ្រាន់តែបញ្ហានេះគឺបើសិនបើអាច -- លោកអាចធ្វើទៅបាន គឺលោកអាចធ្វើតាំងពីដំណាក់កាលស៊ើបអង្កេតឯណោះ មុនពេលចេញដីកាដំណោះស្រាយ។ នេះតាមច្បាប់។ ទី២ បទពិសោធន៍នៃដំណើរការនូវបញ្ហានេះដែលអង្គជំនុំជម្រះមានបទពិសោធន៍ និងការជួបប្រទះតាំងពីសំណុំរឿង០០១ មកហើយជាហូរហែមក លោកមានឱកាសនៅក្នុងការជំទាស់តវ៉ាទៅលើសំណួរទាំងឡាយណាដែលផ្អែកលើមូលដ្ឋាននៃកំណត់ហេតុ។ ចម្លើយបានមកពីធ្វើទារុណកម្ម ដើម្បីបង្ហាញថាការជំទាស់របស់ខ្លួននោះគឺត្រឹមត្រូវ អង្គជំនុំជម្រះនឹងធ្វើការបដិសេធ ហើយបញ្ហានេះកើតជាហូរហែ យើងបានប្រាប់អំពីបទពិសោធន៍នៃការគ្រប់គ្រងកិច្ចដំណើរការសវនាការនេះ អំពីបញ្ហាការប្រើប្រាស់កំណត់ហេតុឯកសារដែលបានមកធ្វើទារុណកម្មហ្នឹង ច្រើនលើកច្រើនសាហើយ។ យើងមិនបានសម្រេចអំពីបញ្ហាហ្នឹងទេ ពីព្រោះយើងអត់ទាន់បានពិភាក្សាជាមួយនឹងក្រុមប្រឹក្សាទេ។ យើងគ្រាន់តែធ្វើការកត់សម្គាល់ប៉ុណ្ណោះលើអ្វីដែលលោកបាននិយាយដោយខ្លួនឯង។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា នេះ -- លោកប្រធានបាននិយាយថា បញ្ហានេះ គួរតែលើកឡើងនៅក្នុងដំណាក់កាលស៊ើបអង្កេត ហើយនេះគឺជាអ្វីដែលយើងបានធ្វើ។ វាមិនមែនជាបញ្ហាដែលយើងមិនបានធ្វើនៅក្នុងកិច្ចដំណើរ -- កិច្ចស៊ើបអង្កេតនោះឡើយ។ ការពិតនេះជាសំណើរបស់យើង ដែលស្នើឱ្យមានការដកចេញ ឬក៏កាត់បន្ថយនូវផ្នែកណាមួយ។

**ប្រធានអង្គជំនុំ៖**

យើងបានជម្រាបរួចហើយ បញ្ហាហ្នឹង គឺគ្រាន់តែជាការ -- គ្រាន់តែលោកមានការភន្តច្រឡំ។ បើសិនជាយើងសម្រេចហើយ យើង -- ក្រុមប្រឹក្សាសម្រេចអំមិញ ក៏មិនអាចសម្រេចបានរឿងក្ដីមួយពីរ -- រឿងសំណើមួយ សម្រេចពីរដងផ្ទុយគ្នាទេ។ យើងគ្រាន់តែកត់សម្គាល់លើអ្វីដែលលោកបានលើកឡើងប៉ុណ្ណោះ។ ព្រោះលោក ក៏ខ្លួនឯង ក៏បាននិយាយបញ្ហាហ្នឹងដែរ យើងមិនអនុញ្ញាតឱ្យលោកនិយាយបញ្ហានេះទៀតទេ។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សី TCW-428 រួមទាំងមេធាវីប្រឹក្សាសាក្សីផង ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៣:៥៧:៤១]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីសាក្សី តើលោកសាក្សីឈ្មោះអី?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ មាស វឿន។

**ស៖** ហើយមានឈ្មោះហៅក្រៅទេ លោក មាស វឿន?

សាក្សីកុំអាលទាន់ឆ្លើយតប! សាក្សី ពេលដែលស្ដាប់នូវសំណួរដែលសួរ សាក្សីត្រូវបង្អង់បន្ដិចរហូតដល់ក្បាលមីក្រូហ្វូន នៅមុខសាក្សីហ្នឹង មានសញ្ញាក្រម នៅអារង្វង់មូលខាងក្រោមហ្នឹង ឬមួយក៏នៅក្បាលមីក្រូហ្វូនហ្នឹង មានសញ្ញាភ្លើងក្រហម ដែលជាសញ្ញាបញ្ជាក់ថា ឧបករណ៍ហ្នឹង ប្រតិបត្តិការអាចនិយាយបានហើយ ដើម្បីឱ្យប្រព័ន្ធសំឡេងរបស់លោកហ្នឹង គឺចូលនឹងប្រព័ន្ធស្ដាប់សំឡេងនៅក្នុង

អង្គសវនាការនេះ ក៏ដូចជាទៅដល់អ្នកបកប្រែភាសា ព្រោះប្រើប្រាស់ភាសាបីភាសា នៅទីនេះ។

**ស៖** តើមានឈ្មោះហៅក្រៅទេ លោក មាស រឿន?

[១៣:៥៨:៥២]

**ឆ៖** បាទ មាន ឈ្មោះ ស្វាយ រឿន។

**ស៖** បាទ អរគុណ។ ហើយលោក មាស រឿន តើលោកមានអាយុប៉ុន្មាន?

**ឆ៖** បាទ ខ្ញុំមានអាយុ៦៨។

**ស៖** បាទ អរគុណ។ ហើយសព្វថ្ងៃនេះ លោកមានទីលំនៅកន្លែងណា?

**ឆ៖** បាទ ខ្ញុំនៅខេត្តបន្ទាយមានជ័យ។

**ស៖** បាទ អរគុណ។ ហើយលោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរ?

**ឆ៖** បាទ ខ្ញុំធ្វើស្រែ។

**ស៖** អរគុណ។ ហើយឪពុករបស់លោក គាត់ឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំឈ្មោះ ស្វាយ មាស។

**ស៖** បាទ អរគុណ។ ចុះម្ដាយរបស់លោក គាត់ឈ្មោះអី?

[១៤:០០:០៥]

**ឆ៖** ម្ដាយខ្ញុំឈ្មោះ ប៉ែន អ៊ឹម ស្លាប់ ទាំងពីរ។

**ស៖** ចុះប្រពន្ធរបស់លោក គាត់ឈ្មោះអី?

**ឆ៖** ប្រពន្ធខ្ញុំឈ្មោះ អ៊ឹម យឹម (នឹម យឹម)។

**ស៖** បាទ អរគុណ។ ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** បាទ ខ្ញុំមានកូនប្រាំបីនាក់ ស្លាប់មួយ។

**ស៖** លោក មាស រឿន តើលោកមានជំនឿសាសនាអី?

**ឆ៖** បាទ ខ្ញុំមានជំនឿសាសនា យេស៊ូ។

**ស៖** អរគុណ។ ហើយលោក មាស រឿន តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការ កាលពីព្រឹកមិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងបុគ្គលដែលត្រូវទទួលយកធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះទេ ហើយក៏មិនជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីនាក់ដែរ គឺលោក នួន ជា, លោក អៀង

សារី និងលោក ខៀវ សំផន។ តើជាការពិតមែនដែរឬទេ?

[១៤:០១:២៤]

**ឆ៖** បាទ អត់មានទេ។

**ប្រធានអង្គជំនុំ៖**

លោកស្រី សែ កុលវុឌ្ឍី ឡើងធ្វើការណែនាំដល់សាក្សី មាស រឿន ក្នុងការធ្វើសម្បថតាមជំនឿសាសនារបស់គាត់។

**ក្រឡាបញ្ជី៖**

ចាស លោក មាស រឿន លោកឃើញព្រះគម្ពីរនៅខាងមុខលោកដែរទេ?

ចាស សូមលោកដាក់ដៃឆ្វេងនៅលើព្រះគម្ពីរ ហើយលើកដៃស្តាំឡើងលើ។ ចាស ហើយលោកថានិយាយតាមខ្ញុំ។ ខ្ញុំសូមប្រកាសជាឱឡារិកថា ខ្ញុំនឹងនិយាយតែការពិត ការពិតទាំងអស់ ហើយនិងមិននិយាយអ្វីក្រៅតែពីការពិតនោះទេ។

[១៤:០២:១៨]

**លោក មាស រឿន៖**

ខ្ញុំសូមប្រកាសជាឱឡារិកថា ខ្ញុំសូមនិយាយតែការពិត ការពិតទាំងអស់ ហើយនឹងមិននិយាយៗពីក្រៅតែពីការពិតនោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ សូមអង្គុយចុះ!

បាទ ជាបន្តលោក មាស រឿន អង្គជំនុំជម្រះប្រាប់អំពីសិទ្ធិ និងករណីយកិច្ចរបស់លោកក្នុងនាមលោកជាសាក្សី។ នៅក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធនៅក្នុងការឆ្លើយទៅនឹងសំណួរ ឬការធ្វើអត្ថាធិប្បាយ ឬធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថាដោយសារតែចម្លើយ ឬសេចក្តីអត្ថាធិប្បាយ ឬអំណះអំណាងរបស់លោក នោះហើយនាំឲ្យលោកនឹងត្រូវទទួលការចោទប្រកាន់។

ហើយទន្ទឹមនឹងនេះក្នុងនាមលោកជាសាក្សី ក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវតែឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរ

ចំពោះលោក។ លើកលែងតែសំណួរ ឬអំណះអំណាងណាមួយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ហើយលោកជាសាក្សីត្រូវតែឆ្លើយការណ៍ណាដែលពិត ដែលខ្លួនបានដឹង បានឮ បានឃើញ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមសួរលោក។

[១៤:០៤:០៩]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក មាស វឿន តើលោកដែលធ្លាប់ផ្តល់បទសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ? ហើយបើសិនបើមាន តើការធ្វើសម្ភាសនោះប្រព្រឹត្តទៅប៉ុន្មានលើក? នៅទីកន្លែងណា? នៅពេលណា?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំបាទ ជួបអ្នកសម្ភាសខ្ញុំនៅផ្ទះ បីដង។ម្តងខ្ញុំមិនបានចាំថ្ងៃខែទេ អស់។

**ស៖** បាទ អរគុណ។ ហើយមុននឹងពេលចូលមកផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះលោកបានពិនិត្យមើល ឬក៏បានអាន ឬក៏បានស្តាប់ការអានពីបុគ្គលណាម្នាក់នូវកំណត់ ដែលលោកផ្តល់សក្ខីកម្មកាលពីបីលើក លើកមុននោះដែរឬទេ ដើម្បីរំឭកការចងចាំនោះ?

[១៤:០៥:១៥]

**ឆ៖** បាទ ខ្ញុំបានមើលខ្លះដែរ ក៏ប៉ុន្តែចាំមិនអស់ទេ។

**ស៖** តាមសមត្ថភាពដែលលោកអាចដឹង និងចងចាំ តើលោកអាចបញ្ជាក់បានដែរទេថា កំណត់ស្តាប់សក្ខកម្មីរបស់លោកដែលបានលោកបានអាន ដើម្បីរំឭកការចងចាំនេះ គឺវាស៊ីសង្វាក់គ្នា ឬក៏វាស្របគ្នាទៅនឹងចម្លើយដែលលោកបានធ្វើសម្ភាស ឬក៏ការផ្តល់ចម្លើយរបស់លោកហ្នឹង កាលពីបីលើកលើកមុនដែរឬទេ?

**ឆ៖** បាទ ចូលគ្នាៗ ខ្លះដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយថ្ងៃនេះគឺលោកបានស្នើសុំឲ្យមានមេធាវីប្រឹក្សា ហើយអង្គជំនុំជម្រះបានចាត់តាំងមេធាវីប្រឹក្សាតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនលោករួចហើយ។ លោកមេធាវីអាចប្រាប់ជម្រាបដល់អង្គសវនាការអំពីឈ្មោះ អត្តលេខ និងការិយាល័យរបស់លោកបានដែរឬទេ

លោកមេធាវី?

[១៤:០៦:៣៤]

**លោក សេង រិទ្ធី៖**

បាទ សូមគោរពលោកប្រធាន។ ខ្ញុំបាទឈ្មោះ សេង រិទ្ធី ជាមេធាវីអត្តលេខ៤៧០ នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ អង្គជំនុំជម្រះសូមជម្រាបជូនទៅតំណាងសហព្រះរាជអាជ្ញាថា ក្នុងកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាស្ដាប់សក្ខីកម្មរូបនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា តាំងសំណួរដេញដោលចំពោះសាក្សីនេះ មុនភាគីដទៃទៀតនៃរឿងក្ដី។

ហើយអង្គជំនុំជម្រះក៏សូមជម្រាបថា តំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលអតិបរមា គឺ១ថ្ងៃកន្លះ នេះអង្គជំនុំជម្រះបានចែកជូនរួចហើយ។

សូមអញ្ជើញ!

**លោក វ៉េង ហ៊ត់៖**

អរគុណលោកប្រធាន។ សូមគោរពលោកប្រធាន សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ និងសូមគោរពលោក លោកស្រីទាំងអស់ដែលបានអញ្ជើញមកក្នុងអង្គសវនាការនេះ។ សួស្ដីលោក មាស វឿន ខ្ញុំមកពីក្រុមការងារពីការិយាល័យសហព្រះរាជអាជ្ញា។ ប្រសិនបើខ្ញុំសួរទៅលោកយល់ថា សំណួរខ្ញុំមិនច្បាស់ទេ លោកអាចអនុញ្ញាតឲ្យខ្ញុំសួរលោកមួយសាទៀត ហើយ -- ឬក៏សុំការស្នើសុំពីលោកប្រធានដើម្បីសុំឲ្យខ្ញុំសួរមួយសាទៀត។

[១៤:០៨:២៤]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉េង ហ៊ត់៖**

**ស៖** សំណួរទី១ របស់ខ្ញុំសួរលោក ចង់ដឹងពីប្រវត្តិការងាររបស់លោក ដែលបានចូលរួមនៅក្នុងចលនាបដិវត្តន៍។ អ៊ីចឹងខ្ញុំចង់សុំឲ្យលោកជួយបំភ្លឺ ថាតើលោកចូលរួមនៅក្នុងចលនាបដិវត្តន៍នេះចាប់ពីឆ្នាំណាមក បាទ?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំសូមគោរពលោកប្រធាន។ ខ្ញុំសូមរួមធ្វើបដិវត្តន៍តាំងពីឆ្នាំ១៩៦៨។

**ស៖** អរគុណលោក មាស វឿន។ តើនៅពេលដែលលោកចូលដំបូងនោះ លោកចូលធ្វើអ្វីដែរ? សូមលោកជួយបំភ្លឺផងបាទ។

**ឆ៖** បាទ កាលចូលដំបូងខ្ញុំជាយុវជននៅជនបទ ហើយមានអ្នកដឹកនាំចូល។

[១៤:១០:០៩]

**ស៖** ពេលនោះលោកមានតួនាទីធ្វើអ្វីខ្លះនៅតាមជនបទ ដែលលោកចូលដំបូងនោះ?

**ឆ៖** ដំបូង ខ្ញុំបាទបានចូលក្នុងក្រុមយុវជននៅជនបទ ដើម្បីថា ប្រទេសមិនទាន់បានឯករាជ្យ។

**ស៖** ខ្ញុំចង់ដឹងពីលោកថា តើលោកធ្វើអ្វីចូលដំបូងនោះ?

**ឆ៖** ធ្វើជាតំណាងយុវជនតាមភូមិ។

**ស៖** អរគុណលោក។ ពេលដែលលោក មាស វឿន លោកចូលដំបូង តើមានកម្មាភិបាល ឬមួយក៏ថ្នាក់ដឹកនាំណាខ្លះដែលលោកបានស្គាល់ ហើយនិងលោកជួយធ្វើការគាត់នៅពេលនោះដែរទេ?

**ឆ៖** បាទ នៅពេលនោះមានកម្មាភិបាលដឹកនាំម្នាក់ តែឥឡូវគាត់ស្លាប់ហើយ។ ខ្ញុំមិនបានចាំឈ្មោះ។

**ស៖** នៅមុនឆ្នាំ១៩៧០ ដែលលោកថា នៅឆ្នាំ១៩៦៨នេះ តើលោកដែលធ្លាប់ឮ លោក ខៀវ សំផន ទៅចូលរួមនៅក្នុងចលនាដែលលោកបានធ្វើការជាមួយបដិវត្តន៍នោះដែរទេ?

**ឆ៖** បាទ មុនឆ្នាំ១៩៧៨ ខ្ញុំបាទឮឈ្មោះ លោក ខៀវ សំផន តាមវិទ្យុ តែមិនបានឃើញរូបគាត់ផ្ទាល់នៅឡើយទេ។ គាត់ប្រឆាំងជាមួយនឹងសម្តេច សីហនុ។

**ស៖** ក្រៅពីឮតាមវិទ្យុ តើលោកបានទទួលសំបុត្រ ឬក៏ទទួលឯកសារផ្សេងៗ ទាក់ទងជាមួយនឹងលោក ខៀវ សំផន ដែរទេបាទ?

**ឆ៖** បាទ គ្មានទេ។

[១៤:១៣:៣៣]

**ស៖** អរគុណលោក។ នៅក្នុងចម្លើយរបស់លោក ដែលបានឆ្លើយនៅចៅក្រមស៊ើបអង្កេត ឯកសារ E3/424 ERN ជាភាសាខ្មែរ 00418518, ERN ជាភាសាអង់គ្លេស 00784178, ERN ជាភាសាបារាំង 00784186។ លោកបានប្រាប់ក្រុមអ្នកស៊ើបអង្កេតថា "នៅឆ្នាំ១៩៧០ លោកបានចូល

ក្រុមយុវជនស្នេហាជាតិ ក្នុងការតស៊ូរំដោះជាតិឲ្យរួចផុតពីអាណានិគមនិយម មូលធននិយម។ ពេលនោះលោកជាកងការពារ និងជាអ្នកនាំផ្លូវរបស់កម្មាភិបាល"។ ខ្ញុំមានសំណួរសួរលោក តើលោកជាកងការពារ ឬនីរសារនេះឲ្យអ្នកណាដែរបាទ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

[១៤:១៥:០៦]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមសោកស្តាយ ដែលកាត់ផ្តាច់នេះ។ សហព្រះរាជអាជ្ញា -- ខ្ញុំគិតថា មានបញ្ហាយោងលេខ ERN ជាភាសាបារាំងហើយ អ៊ីចឹង សូមឲ្យលោកសហព្រះរាជអាជ្ញា ឲ្យលេខ ERN នេះឡើងវិញម្តងទៀត។ សូមអរគុណលោកប្រធាន។

**លោក វ៉េង ហ៊ាត់៖**

ខ្ញុំសូមបង្ហាញ ERN ជាភាសាបារាំងសាជាថ្មី 00784186។

**សួរដោយលោក វ៉េង ហ៊ាត់៖**

**ស៖** សាក្សីលោក មាស វឿន ខ្ញុំ -- លោកនៅចាំសំណួរខ្ញុំទេ បើចាំ សូមលោកឆ្លើយនូវសំណួរហ្នឹងបាទ។

**លោក មាស វឿន៖**

**ឆ៖** បាទ អត់ទាន់ចាំនៅឡើយទេ។

**ស៖** អរគុណលោក។ ខ្ញុំអានជូនលោកមួយសាទៀតណ៎ា។ តាមឯកសារដែលខ្ញុំបានរៀបរាប់ខាងលើ លោកបានប្រាប់ក្រុមអ្នកស៊ើបអង្កេតថា "នៅឆ្នាំ១៩៧០ លោកបានចូលក្រុមយុវជនស្នេហាជាតិ ក្នុងការតស៊ូរំដោះប្រទេសជាតិ ឲ្យរួចផុតពីអាណានិគមនិយមបារាំង និង មូលធននិយម។ ពេលនោះ លោកជាកងការពារ និងជាអ្នកនាំផ្លូវរបស់កម្មាភិបាល"។ អ៊ីចឹង ខ្ញុំសួរថាតើលោកនៅចងចាំទេ លោកជាកងការពារឲ្យកម្មាភិបាលមួយណាដែរបាទ?

[១៤:១៧:២៦]

**ឆ៖** បាទ ដំបូង ខ្ញុំបានការពារកម្មាភិបាល ដែលបានបែកចេញពីទីក្រុងភ្នំពេញ ទៅនៅជនបទ

ហើយនាំគាត់នៅក្នុងព្រៃ ការពារគាត់ បាទ។

**ស៖** ខ្ញុំចង់ដឹងពីលោក វឿន វិញថា បញ្ហាដាក់ស្តែងនោះ តើកម្មាភិបាលហ្នឹង គាត់ឈ្មោះអី លោកស្គាល់ទេ កាលពីឆ្នាំ៧០ហ្នឹង? ហើយបន្ទាប់មកទៀត លោកនាំកម្មាភិបាលណាខ្លះផ្សេងទៀត ដែលទៅទីនុ៎ង បាទ?

**ឆ៖** បាទ មានលោក វន វ៉េត, នង សួន នេះដែលខ្ញុំចាំ ហើយលោក ខៀវ សំផន ផងដែរ។

[១៤:១៩:០៣]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន។ ខ្ញុំសូមអភ័យទោស ដែលអន្តរាគមន៍ម្តងទៀតនេះ។ ខ្ញុំសូមអន្តរាគមន៍ មុនពេលដែលមានធ្វើយោងផ្សេងទៀត ប្រសិនបើខ្ញុំយល់មិនខុសនោះទេ សហព្រះរាជអាជ្ញាដកស្រង់នូវឯកសារ E3/424។ ជាភាសាបារាំងនោះ លេខ ERN ហើយចំពោះឯកសារ E3/424 នោះ ខ្ញុំមានឯកសារដែលចាប់ផ្តើមដោយលេខ 00455266 ហើយដែលចប់នៅលេខ 00509789។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា បើសិនជាមានយោងផ្សេងទៀតនោះ គឺថាយើងនិយាយពីឯកសារដដែលនេះ។ ពីព្រោះថាលេខ ERN ដែលគាត់ផ្តល់ឲ្យនោះ គឺថាវាមិនដូចគ្នានឹងលេខ ERN ដែលខ្ញុំមាននោះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហមេធាវីអន្តរជាតិការពារ -- នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំគ្រាន់តែចង់បញ្ជាក់លើអ្វីដែលសហភាតាខ្ញុំបានលើកឡើងនេះ គឺថា ERN របស់ឯកសារនេះហ្នឹងគឺថា E3/424 ERN ជាភាសាបារាំងនោះថានៅចម្លើយទី១ គឺថា 00455267។ ខ្ញុំគ្រាន់តែចង់បញ្ជាក់លើលេខយោងនេះទេ លោកប្រធាន។

**លោក វ៉េង ហ៊ាត់៖**

ត្រឹមត្រូវហើយលោកប្រធាន ខ្ញុំអានខុសអំមិញបាទ។ សូមអធ្យាស្រ័យបាទ។

**សួរដោយលោក វ៉េង ហ៊ាត់៖**

**ស៖** លោកសាក្សី លោកបានឆ្លើយអម្បាញ់មិញថា "លោកជាកងការពារ ហើយជាអ្នកនាំផ្លូវ

ឲ្យ វន វ៉េត, សួន ជាមួយនឹង ខៀវ សំផន"។ ខ្ញុំសូមសួរលោកបន្តទៀត ក្រៅពីការនាំផ្លូវ តើលោកមានទទួលបានសំបុត្រ ឬក៏ឯកសារផ្សេងៗពីលោក ខៀវ សំផន ដែរទេបាទ?

[១៤:២១:៤៩]

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំមិនបានទទួលសំបុត្រពីគាត់ទេកាលណោះ។

**ស៖** អរគុណលោក ខ្ញុំសូមទៅមុខបន្តិចទៀត។ នៅក្នុងចម្លើយដដែល លោកបានប្រាប់ថា លោកបានប្រើពាក្យថា "តស៊ូរំដោះជាតិ ហើយចូលនៅក្នុងយុវជនស្នេហាជាតិ" តើពាក្យ "រំដោះជាតិ ហើយជាមួយនឹងយុវជនស្នេហាជាតិ" នេះ អ្នកណាបង្រៀនលោកដែរបាទ?

**ឆ៖** បាទ កម្មាភិបាលដែលគ្រប់គ្រងលើខ្ញុំឈ្មោះ មឿន តែស្លាប់ហើយឥឡូវនេះ។

**ស៖** សូមអធ្យាស្រ័យលោកប្រធាន។ ឥឡូវសំណួរបន្តទៅទៀត នៅក្នុងឯកសារ E3/424 ERN ជាភាសាខ្មែរ 00418518, ERN ជាភាសាអង់គ្លេស 00784179, ERN ជាភាសាបារាំង 00455267។ លោកបានប្រាប់អ្នកស៊ើបអង្កេតថា "នៅឆ្នាំ១៩៧១ លោកបានចូលទ័ពដោយហាត់រៀនបច្ចេកទេសយោធា"។ ខ្ញុំចង់បានថា តើលោកជួយផ្តល់យោបល់ តើក្រៅពីការហាត់បច្ចេកទេសយោធា លោកបានរៀនវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជាបក្សអ្វីផ្សេងដែរទេបាទ?

**ឆ៖** បាទ មុននឹងបានហាត់បច្ចេកទេសយោធា ខ្ញុំបានរៀនសូត្រពីសិក្សានយោបាយរបស់ប្រទេសដែលមានកម្មាភិបាលយោធាបង្ហាត់អំពីប្រទេសរបស់ខ្លួនមិនបានឯករាជ្យ ពិសេសគឺសេដ្ឋកិច្ចនៅក្រោមអំណាចរបស់អាណានិគមបារាំង។

**ស៖** អរគុណលោក។ សំណួរបន្ទាប់ នៅក្នុងឯកសារដដែលលោកបានប្រាប់អ្នកស៊ើបអង្កេតថា "តាសឿង បានឡើងជាប្រធានយោធាភូមិភាគ ចំណែកលោកបានឡើងជាវរសេនាតូចលេខ ១៣៦ ក្នុងកងពលសេនាធំលេខ១៦ កងពលលេខ១"។ អ៊ីចឹងខ្ញុំពិនិត្យមើលរចនាសម្ព័ន្ធកងទ័ពភូមិភាគនិរតីនាពេលនោះ តើរចនាសម្ព័ន្ធខ្ពស់បំផុត ប្រធានយោធាភាគ ឬក៏ប្រធានកងពលលេខ១? បាទ សូមលោក វឿន ជួយបញ្ជាក់ផងបាទ។

[១៤:២៦:១៣]

**ឆ៖** បាទ តាសឿង គាត់ឆ្នាំ -- នៅភូមិភាគ ខ្ញុំស្តាប់មិនទាន់បាន សំណួរហ្នឹងមិនច្បាស់ លោកបញ្ជាក់ម្តងទៀត។

**ស៖** ខ្ញុំសួរលោកទាក់ទងរចនាសម្ព័ន្ធម្តងទៀត។ រចនាសម្ព័ន្ធកងទ័ព គឺឋានានុក្រមដែលលោកបានដឹងនោះ ប្រធានយោធាភូមិភាគ ឬក៏ប្រធានកងពល? មួយណាធំជាងបាទ?

**ផ៖** បាទ រចនាសម្ព័ន្ធធំជាង គឺភូមិភាគធំជាង។

**ស៖** តើប្រធានយោធាភូមិភាគពេលនោះឈ្មោះអ្វីដែរ?

**ផ៖** ប្រធានភូមិភាគ គឺឈ្មោះ តាស៊ី។

**ស៖** ភូមិភាគនិរតី មិនមែនភូមិភាគបស្ចិមទេ? ភូមិភាគនិរតី ប្រធានភូមិភាគអ្នកណាបាទ?

**ផ៖** ប្រធានភូមិភាគនិរតីពីមុនដំបូង គឺតាម៉ុក។

**ស៖** តើប្រធានកងពលកាលនោះ កងពលលេខ១ ហ្នឹងឈ្មោះអីដែរបាទ?

**ផ៖** បាទ ប្រធានកងពលលេខ១ គឺឈ្មោះ តាសឿង។

[១៤:២៨:៣០]

**ស៖** សំណួរខ្ញុំបន្ទាប់ នៅក្នុងឯកសារដដែល លោកបានប្រាប់អ្នកស៊ើបអង្កេតថា "លោកគឺជាប្រធានវរសេនាធំក្នុងកងពលលេខ១"។ ខ្ញុំចង់សួរលោកថា តើលោកបានឡើងជាប្រធានកងវរសេនាធំនៅឆ្នាំណាដែរ?

**ផ៖** បាទ ខ្ញុំប្រធានវរសេនាធំ ឆ្នាំ៧៥។

**ស៖** លោកអាចប្រាប់បានទេថា លោកមានទាហានប៉ុន្មាននាក់ដែរ?

**ផ៖** បាទ ទាហានក្នុងមួយវរសេនាធំហ្នឹង ប្រហែលជា ៦០០នាក់។

**ស៖** តើអ្នកណាមានអំណាចក្នុងការតែងតាំងលោក ដើម្បីបានឋានៈជាប្រធានវរសេនាធំហ្នឹង?

**ផ៖** បាទ តាសឿង។

[១៤:២៩:៤៥]

**ស៖** លោកអាចដឹងទេថា តើប្រធានវរសេនាធំចាស់ហ្នឹង គេយកគាត់ទៅណាដែរបាទ?

**ផ៖** ប្រធានវរសេនាធំចាស់ស្លាប់ហើយ។

**ស៖** នៅក្នុងកងវរ អ៊ំ! នៅក្នុងប្រធាន នៅក្នុងកងវរសេនាធំរបស់លោក តើខាងណាដែលបំពាក់អាវុធ ឲ្យកងវរមួយវរសេនាធំរបស់លោកតែម្តង?

**ផ៖** បាទ តាសឿង។

**ស៖** ខ្ញុំចង់សួរទាក់ទងខ្សែបញ្ជាវិញ តើការអនុវត្តជាក់ស្តែង លោកទទួលបញ្ជាពីគណៈភូមិភាគ

អាចនិយាយថា លេខាភូមិភាគ ឬលោកទទួលបញ្ជាពីប្រធានយោធាភាគ ឬក៏កងពលលេខ១?

**ឆ៖** បាទខ្ញុំទទួលបញ្ជាពីប្រធានកងពលលេខ១។

**ស៖** សូមលោកជួយពន្យល់អំពីរបៀបបង្កើតកងទ័ពដូចជា អ្នកណាមានសិទ្ធិបង្កើតកងវរសេនាតូច ទី១។ អ្នកណាមានសិទ្ធិចាត់តាំងកងវរសេនាធំ។ សូមលោកជួយពន្យល់ផងបាទ។

**ឆ៖** បាទ ការបង្កើតកងវរសេនាធំ រហូតមកដល់កងវរសេនាតូច គឺភូមិភាគរួមជាមួយនឹងលេខាកងពល។

**ស៖** ចុះចំពោះប្រធានកងពល និងប្រធានយោធាភាគ តើលោកដឹងថា អ្នកណាមានសិទ្ធិចាត់តាំងគាត់ទេ?

**ឆ៖** បាទ អ្នកទាំងពីរហ្នឹងប្រហាក់ប្រហែលគ្នា គេពិគ្រោះគ្នា គេជួបគ្នា។

**ស៖** ខ្ញុំចង់សួរលោក សឿន ថា នៅពេលដែលឡើងជាតំណែងប្រធានកងពល ឬក៏ប្រធានយោធាភាគ តើអ្នកណាមានសិទ្ធិឲ្យគាត់ ចាត់តាំងគាត់ឲ្យឡើងជាប្រធានភូមិភាគ ឬក៏ប្រធានកងពលនុ៎ង ចង់ដឹងអ៊ីចឹង?

**ឆ៖** ខ្ញុំស្តាប់មិនទាន់បាន។

**ស៖** អរគុណលោក។ ខ្ញុំសួរមួយសាទៀត។ ដើម្បីឡើងបានជាប្រធានកងពល តើអ្នកណាដែលចាត់តាំងគាត់ឲ្យធ្វើជាប្រធានកងពល នៅក្នុងភូមិភាគនីមួយៗហ្នឹង លេខាភូមិភាគមានសិទ្ធិចាត់តាំងគាត់ជាប្រធានកងពល ឬមួយក៏មជ្ឈិម ឬមួយក៏អគ្គសេនាធិការក្នុងការចាត់តាំងហ្នឹង?

[១៤:៣៣:៤២]

**ឆ៖** បាទ កន្លែងត្រង់នោះ ខ្ញុំមិនបានដឹងទេ ទៅបន្តទៀត ខ្ញុំដឹងតែត្រឹមភូមិភាគប៉ុណ្ណឹងឯង។

**ស៖** អរគុណលោក។ ឥឡូវខ្ញុំសួរលោកបន្តទៀត ស្តីពីលក្ខខណ្ឌចូលទ័ព។ ខ្ញុំសួរថាតើដើម្បីបានឡើងជាប្រធានកងវរសេនាធំ ដូចរូបលោក តើក្នុងរបបកម្ពុជាប្រជាធិបតេយ្យគេមានជ្រើសរើសមនុស្សក្នុងវណ្ណភាពដូចម្តេចដែរបាទ?

**ឆ៖** បាទ មុននឹងគេជ្រើសរើសធ្វើក្នុងតំណាងកងពល ឬក៏វរសេនាធំ ឬក៏វរសេនាតូច គេត្រូវជ្រើសរើសអ្នកស្មោះត្រង់ ត្រឹមត្រូវ។

**ស៖** តើគេមានជ្រើសរើសពីវណ្ណៈផ្សេងៗ នៅក្នុងសង្គមដែរទេ?

[១៤:៣៥:០៤]

**ឆ៖** បាទ បើប្រសិនណានៅក្នុងសង្គម បើសិនណាគេមានសកម្មភាពល្អ ក៏គេជ្រើសរើសដែរ។

**ស៖** អរគុណលោក។ ខ្ញុំសូមឱ្យលោកប្រាប់រឿងជាក់ស្តែង តើមុនពេលវាយចូលទីក្រុងភ្នំពេញនោះ លោកធ្លាប់ប្រយុទ្ធតាមសមរភូមិណាខ្លះដែរទេ?

**ឆ៖** បាទ មុននឹងចូលសមរភូមិភ្នំពេញ គឺសមរភូមិដែលខ្ញុំត្រូវចូលប្រយុទ្ធពីផ្លូវលេខ៥ ឆ្នាំ៧០ ផ្លូវលេខ៥ ពីត្រឹមក្រគរ មកទាល់គ្នាកំពង់ឆ្នាំង ទាល់គ្នាភ្នំពេញ។

**ស៖** តើពេលនោះ អ្នកណាបញ្ជាក្នុងការប្រយុទ្ធបាទ?

**ឆ៖** បាទ អ្នកបញ្ជាផ្ទាល់ គឺតាម៉ុក។

**ស៖** ចុះនៅពេលដែលយើងប្រយុទ្ធចប់ម្តងៗ លោករាយការណ៍ ហើយលោកទទួលបទបញ្ជាថ្មីៗពីអ្នកណាដែរ?

**ឆ៖** បាទ ចប់ពីការប្រយុទ្ធ បញ្ជាផ្ទាល់ប្រាប់ពី តាសឿង។

**ស៖** ខ្ញុំមានចម្ងល់ត្រង់ហ្នឹងមួយដែរ។ លោកប្រាប់ថា រាល់ការបញ្ជាក្នុងការប្រយុទ្ធជាមួយនឹងកងទ័ព លន់ នល់ ឬក៏កងទ័ពហ្នឹង គឺតាម៉ុក អ្នកបញ្ជា។ ចុះហេតុអីបានជាលោកមិនរាយការណ៍ទៅតាម៉ុក បែរជាលោករាយការណ៍ទៅ តាសឿង វិញ តើប្រព័ន្ធហ្នឹង យ៉ាងម៉េចដែរបាទ?

**ឆ៖** បាទ ក្នុងការបញ្ជាផ្ទាល់ពី តាម៉ុក មក តាសឿង ពីតាសឿង មកវរសេនាធំ ឬក៏អនុកងពល តាសឿង បញ្ជាផ្ទាល់ក្នុងសមរភូមិក្តៅ។

[១៤:៣៨:០៧]

**ស៖** អរគុណលោក។ លោកថាមានការប្រយុទ្ធនៅតាមផ្លូវជាតិលេខ៥ ពីពោធិ៍សាត់ ក្បែរកំពង់ឆ្នាំងនេះ តើនៅពេលដែលយើងប្រយុទ្ធម្តងៗ ឬក៏ទទួលបានជ័យជម្នះយ៉ាងដូចម្តេចនោះ តើមានការជម្លៀសប្រជាជនចេញពីតំបន់នុ៎ងដែរឬទេ?

**ឆ៖** បាទ ក្នុងការប្រយុទ្ធគ្នា មានគ្រាប់លើអាកាសផង ហើយគ្រាប់ពីដីផង ក្នុងប្រជាជនឥតបាច់ប្រាប់គាត់ថា ជម្លៀសទេ គាត់ចេញខ្លួនឯង ទៅរកកន្លែងដែលក្រៅពីសមរភូមិត្រូវប្រយុទ្ធគ្នា។

**ស៖** អរគុណលោក។ ខ្ញុំពិនិត្យមើលចម្លើយដែលលោកបានផ្តល់ ទៅឱ្យចៅក្រមស៊ើបអង្កេតនៅក្នុងឯកសារ E3/424, ERN ជាភាសាខ្មែរ 00418519, ជាភាសាអង់គ្លេស 00784179, ជាភាសាបារាំង 00455268។ លោកបានមានប្រសាសន៍ប្រាប់អ្នកស៊ើបអង្កេតថា "មុនពេលវាយចូលភ្នំពេញ មុខព្រួញខាងភូមិភាគនិរតីជាដើម បានប្រជុំជាមួយអគ្គសេនាធិការ។ មាន តាសុន សេន

និងតានួន ជា ជាអ្នកដឹកនាំប្រជុំ ជាមួយមេកងពលគ្រប់ភូមិភាគ ហើយប្រធានកងពលបានមកផ្សព្វផ្សាយបន្តដល់កងវរសេនាធំ"។ សំណួររបស់ខ្ញុំមានដូចខាងក្រោម៖ តើអគ្គសេនាធិការប្រជុំនៅកន្លែងណា?

[១៤:៤០:២៦]

**ឆ៖** បាទ កន្លែងត្រង់អគ្គសេនាធិការ ខ្ញុំអត់បានដឹងកន្លែងទេ ខ្ញុំដឹងត្រឹមតែប្រធានកងពលប្រាប់ខ្ញុំប៉ុណ្ណោះ។

**ស៖** តើប្រធានកងពលប្រាប់នេះ ប្រាប់ប៉ុន្មានខែមុនវាយចូលទីក្រុងភ្នំពេញ?

**ឆ៖** បាទ មិនយូរប៉ុន្មានទេ ប្រាប់ប្រហែលជា១អាទិត្យប៉ុណ្ណឹង ដើម្បីរៀបចំផែនការវ៉ៃប៉ុណ្ណឹងឯង។

**ស៖** នៅក្នុងនេះ ខ្ញុំចង់ដឹងថា លោកថាប្រធានកងពលប្រាប់លោកអំពីការវាយចូលទីក្រុងភ្នំពេញ ដែលដឹកនាំដោយ សុន សេន និង នួន ជា។ ខ្ញុំចង់ដឹងថា តើនៅពេលដែលប្រជុំនោះ ប្រធានកងពលមានបានប្រាប់លោកទេថា គេប្រជុំពីរបៀបវារៈអ្វីដែរបាទ?

[១៤:៤១:៥៧]

**ឆ៖** បាទ ខ្ញុំបានទទួលផែនការពីប្រធានកងពល គាត់រៀបចំប្រជុំនោះ គឺឲ្យកម្លាំងគ្រប់មុខព្រួញទាំងអស់ ក៏ប៉ុន្តែខ្ញុំដឹងថាតែកម្លាំងខាងនិរតីឲ្យវ៉ៃពីខាងលិចផ្លូវពោធិ៍ចិនតុង ហើយស្ទឹងមានជ័យ និងបឹងបាយ៉ាប បឹងទន្លេសាប ចូលពីខាងលិច ហើយដឹងតែចំនួនផែនការរៀបចំឲ្យវ៉ៃ។ ក៏ប៉ុន្តែក្នុងការដែលវ៉ៃនោះ កម្លាំងធំឲ្យជីកត្រង់សេទុក ក៏ប៉ុន្តែអូសកម្លាំងតូចៗវ៉ៃទៅខាងមុខ ហើយរំកិលកម្លាំងធំពីក្រោយទៅបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកដល់សាក្សី និងមេធាវីប្រឹក្សាសាក្សីនៅបន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះ នៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៣ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**សួរដោយលោក វ៉េង ហ៊ត់៖**

**ស៖** សួស្តីលោក មាស វឿន ជាថ្មីម្តងទៀត។ ខ្ញុំតពីសំណួរអម្បាញ់មិញ ឥឡូវនេះខ្ញុំសួរថា នៅក្នុងរបៀបវារៈស្តីពីការប្រជុំនោះ គេប្រជុំឲ្យវាយចូលទីក្រុងភ្នំពេញ។ តើមានការប្រជុំស្តីពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរទេ?

**លោក មាស វឿន៖**

**ឆ៖** បាទ ក្នុងការដែលប្រជុំវ៉ៃទីក្រុងភ្នំពេញនោះ ពេលនោះមិនបានមានឮផែនការថា អ្ហ៎! ឈ្មោះប្រជុំជម្លៀសប្រជាជននោះ ខ្ញុំបាទអត់បានឮក្នុងគម្រោងការគេប្រជុំនោះទេ។ ឮគ្រាន់ថា ឲ្យវ៉ៃទីក្រុងភ្នំពេញ ឲ្យរំដោះថ្ងៃ១៨ មេសា តែដល់គម្រោងវ៉ៃនោះគឺត្រូវឈ្មោះ វ៉ៃឈ្មោះ១៧ មេសា វិញ បាទ។

**ស៖** ខ្ញុំពិនិត្យឃើញថា នៅក្នុងឯកសារដដែលនេះ លោកបាននិយាយថា ការប្រជុំស្តីពីការវាយចូលទីក្រុងភ្នំពេញ គឺការជម្លៀសប្រជាជន។ ពេលដែលដំណាក់កាលលោកចូលវ៉ៃទីក្រុងភ្នំពេញ ពេលហ្នឹងលោកដឹកនាំទ័ព ៦ ទៅ ៧ពាន់នាក់ដដែល ឬមួយក៏ទ័ពរបស់លោកបានផ្លាស់ប្តូរហើយបាទ?

[១៥:០៥:៤១]

**ឆ៖** បាទ ក្នុងពេលនោះគេប្រាប់តែឲ្យវ៉ៃមុខសញ្ញា តាមវរសេនាធំ មួយមុខតាមវរសេនាធំមួយមុខតាមវរសេនាធំ ក៏ប៉ុន្តែបញ្ជាដោយកងពលប៉ុណ្ណោះបាទ។

**ស៖** ខ្ញុំចង់ដឹងថា តើលោកកាន់ទ័ពប៉ុន្មានពេលដែលចូលទីក្រុងភ្នំពេញ នេះទី១? ទី២ ខ្ញុំថែមសំណួរមួយទៀត លោកបានប្រាប់អ្នកស៊ើបអង្កេតថា "មុខព្រួញបីដែលលោកវ៉ៃចូលទីក្រុងភ្នំពេញ។ ទី១ ពោធិចិនតុង, ទី២ អូរបែកក្អម, ទី៣ ស្ទឹងមានជ័យ"។ អ៊ីចឹង ខ្ញុំថា ខ្ញុំសួរលោកម្តងទៀត លោកកាន់ទ័ពប៉ុន្មានចូលមកទីក្រុងភ្នំពេញ ហើយចូលតាមមុខព្រួញណាក្នុងចំណោមមុខព្រួញទាំងបីនេះ?

**ឆ៖** បាទ កាលណោះ ខ្ញុំទទួលតែមួយវរសេនាធំទេ។ ឯមួយវរសេនាធំដទៃទៀត មានពីរទៀតខាងស្ទឹងមានជ័យ ឯខ្ញុំទទួលតែខាងមុខព្រួញពោធិចិនតុងទេ។ ឯមុខព្រួញមួយទៀត មួយវរសេនាធំទៀត នៅខាង ន៏ៃ ភូមិភ្នំបឹងប៉ាយ៉ាបបាទ។

**ស៖** អរគុណលោក។ នៅក្នុងឯកសារលេខ E3/428 សំណួរចម្លើយទី៣ លោកបានប្រាប់ថា "ចំពោះកងទ័ពដែលវាយចូលភ្នំពេញត្រូវបានថ្នាក់លើណែនាំ មិនឲ្យវាយតបជាមួយខ្មាំងពេលដែលគេលើកទង់សសុំចុះចាញ់"។ ខ្ញុំសួរលោកថា តើស្ថានភាពជាក់ស្តែងលោកធ្លាប់ដែលឮការផ្សាយតាមវិទ្យុស្តីពីការឃោសនា ឲ្យកងទ័ព លន់ នល់ ចុះចាញ់លើកទង់សដែរទេ?

[១៥:០៨:០៣]

**ឆ៖** បាទ នៅពេលនោះ ខ្ញុំអត់បានស្តាប់វិទ្យុទេ ពីព្រោះនៅការកំពុងតែប្រយុទ្ធគ្នា ឯវិទ្យុអត់បានស្តាប់ទេ ដោយបានទទួលតែពីផែនការពីប្រធានកងពលហើយ រួចហើយក៏ចាប់តាមដំណើរការតាមមុខព្រួញទៅបាទ។

**ស៖** អរគុណ។ តើស្ថានភាពជាក់ស្តែងទាហាន ដែលលើកទង់ លោកបានឃើញទាហានលើកទង់សដែរទេបាទ?

**ឆ៖** បាទ ក្នុងពេលដែលវ៉ៃចូលទៅដល់ហើយ ឃើញនៅតាមផ្ទះថ្ម ឃើញមានទង់សទាំងអស់ពេលនោះ គឺអាវុធដែលត្រូវស្វាត់ទាំងអស់បាទ។

**ស៖** ខ្ញុំចង់សួរថាតើលើកទង់សហ្នឹង ទាហានរបស់លោកមានបានចាប់បានទាហាន លន់ នល់ ដែលលើកទង់សហ្នឹងដែរទេ?

[១៥:០៩:២៧]

**ឆ៖** បាទ នៅពេលដែលឈ្នះហើយ អត់មានចាប់ៗទេ ទាំងអស់អត់មានចាប់។ ខ្ញុំ -- មុខសញ្ញាខ្ញុំអត់មានចាប់ទេបាទ។

**ស៖** ខ្ញុំចង់ដឹង ន័យនៃពាក្យមួយទៀត។ នៅក្នុងខ្លឹមសារនេះ លោកបានប្រាប់ថា "មេណែនាំថា

ខ្មាំង លើកទង់ស"។ តើពាក្យនេះ គេសំដៅឲ្យតែទាហាន លន់ នល់ ទាំងអស់ គឺជាខ្មាំង តើអ៊ីចឹងមែនទេ បាទ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** តើមានការណែនាំពីថ្នាក់ថា នៅពេលដែលចាប់ខ្មាំងលើកទង់សនេះបានហ្នឹង តើពីថ្នាក់លើថាឲ្យយកទៅណាដែរ?

**ឆ៖** បាទ ពេលដែលចាប់ គឺបញ្ជូនទៅតាមប្រធានកងពល។ ប្រធានកងពលបញ្ជូនទៅណាទៀត អាហ្នឹង ខ្ញុំអត់បានដឹងទេ។

**ស៖** អរគុណលោក ខ្ញុំទៅសំណួរមួយទៀត។ នៅក្នុងឯកសារ E3/424 សំណួរចម្លើយលេខ៣ដដែល លោកបានប្រាប់ថា "ដល់បីថ្ងៃ បន្ទាប់ពីថ្ងៃរំដោះភ្នំពេញ ក៏បានឃើញប្រជាជនជម្លៀសចេញពីទីក្រុង"។ ខ្ញុំសូមសួរលោកថា សូមលោកជួយប្រាប់ ពេលដែលចូលទីក្រុងៗភ្លាមៗនោះ។ តើពេលនោះប្រជាជនទីក្រុងមានសភាពដូចម្ដេចដែរបាទ?

[១៥:១១:២៧]

**ឆ៖** បាទក្នុងពេលដែលចូលដល់ទីក្រុង នោះប្រជាជននៅក្នុងទីក្រុងស្ងាត់ជ្រាបទាំងអស់។ គាត់អត់បានចុះដី អត់បានដើរឆ្វេចឆ្វាច គឺនៅស្ងាត់ស្ងៀមទាំងអស់។

**ស៖** ចុះទាហានលោក ធ្វើសកម្មភាពយ៉ាងដូចម្ដេចដែរ?

**ឆ៖** បាទខាងទាហានពួកខ្ញុំថយមកនៅខាងក្រោយវិញ មកនៅត្រឹមស្ទឹងមានជ័យវិញ ក្រៅវិញតាមផ្លូវមកលិច ថយមកក្រោយទាំងអស់ បាទ។

**ស៖** សំណួរខាងលើដដែល លោកបានប្រាប់ថា លោកក៏បានឃើញប្រជាជនជម្លៀសចេញពីទីក្រុងភ្នំពេញ តើការជម្លៀសប្រជាជននេះ អង្គការបានប្រគល់ភារកិច្ចទៅឲ្យអង្គភាពស៊ីវិល ឬក៏អង្គភាពកងទ័ព ដើម្បីជម្លៀសប្រជាជន?

**ឆ៖** បាទ ក្នុងការជម្លៀសប្រជាជន ខ្ញុំអត់ដឹងពីផែនការពីថ្នាក់ណា ដែលថាឲ្យជម្លៀសប្រជាជននោះ ខ្ញុំអត់បានដឹងទេ។ ក៏ប៉ុន្តែដឹងតាមរយៈដែលប្រជាជនគាត់ចេញហើយ គាត់ប្រាប់ថា គេឲ្យចេញ។ ហើយខ្ញុំនៅខាងៗក្រៅ ក៏ឲ្យគាត់ចេញតាមដំណើរគាត់មក។

**ស៖** អរគុណលោក។ ខ្ញុំបន្តសំណួរទៅទៀត នៅក្នុងឯកសារ E3/424 ដដែល នៅក្នុងសំណួរចម្លើយលេខ៣ដដែល លោកបានប្រាប់ថា "កងទ័ពរបស់លោក បានដកចេញទាំងអស់"។ ខ្ញុំចង់សួរថា

តើការដកទ័ពចេញ គឺលោកជាអ្នកដកដោយឯកឯង ឬមួយក៏លោកទទួលបញ្ជាពីថ្នាក់ណាដែរ?

**ឆ៖** បាទ ក្នុងការដែលដកកងទ័ពចេញពីភ្នំពេញ ក្រោយរំដោះនោះ គឺកងខ្ញុំអត់បាននៅជាប់ទេ ក្នុង១អាទិត្យ គឺបញ្ជាពីតាម៉ុក ឲ្យដកថយចេញ។

[១៥:១៤:៣០]

**សៈ** តើការបញ្ជានេះ មានការប្រជុំ ឬមួយក៏បញ្ជាតាមរយៈអី?

**ឆ៖** បាទ អត់បានប្រជុំទេ តាមរយៈមេកងពល ប្រធានកងពល គាត់ប្រាប់។

**សៈ** ពេលដែលលោកបញ្ជា -- លោកដកទ័ពចេញនោះ តើប្រជាជននៅទីក្រុងហ្នឹងចេញអស់ហើយនៅ?

**ឆ៖** បាទ ពេលនោះ គាត់អត់ទាន់ចេញអស់ទេ នៅតរហូត។

**សៈ** ខ្ញុំបន្តសំណួរទៅទៀត។ នៅក្នុងឯកសារលេខ E3/424 សំណួរចម្លើយលេខ២ ហើយវាមានជាប់ទាក់ទងនឹងសំណួរចម្លើយលេខ៦ លោកប្រាប់ថា "លោកមានឋានៈជាប្រធានវរសេនាធំ ក្នុងកងពលលេខ១ និងជួយការពារ តាសឿង ជាប្រធានយោធាភូមិភាគនិរតី"។ តាមចម្លើយបំភ្លឺរបស់លោកដដែលនេះ ត្រង់ឆ៦ លោកបានប្រាប់ថា "ថ្នាក់ៗលើផ្លាស់កងវរសេនាធំរបស់លោកទៅប្រចាំការនៅខេត្តកោះកុង"។ ខ្ញុំសួរថា តើថ្នាក់លើនេះ សំដៅទៅលើលេខាភូមិភាគ ឬក៏ប្រធានយោធាភូមិភាគ?

[១៥:១៦:២១]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី ការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមអធ្យាស្រ័យ សូមកាត់ខ្លីទេ។ ដោយសារការអានរបស់តំណាងសហព្រះរាជអាជ្ញាជាតិប្រើពាក្យខុស គឺថា "ជួយការងារ" មិនមែន "ជួយការពារ តាសឿង" ទេ បាទ។ គ្រាន់តែកត់សម្គាល់ប៉ុណ្ណេះ។ សូមអរគុណ។

**លោក វ៉េង ហ៊ត់៖**

ត្រឹមត្រូវហើយលោកប្រធាន ខ្ញុំអាន -- ក្រែងលោ ខ្ញុំអានច្រឡំអំមិញ។

**សួរដោយលោក វ៉េង ហ៊ត់៖**

**សៈ** អ៊ីចឹង ខ្ញុំសួរសាក្សីម្តងទៀត តើថ្នាក់លើនេះ លោកសំដៅទៅលើលេខាភូមិភាគ ឬក៏

ប្រធានយោធាភូមិភាគ?

**លោក មាស វឿន៖**

**ឆ៖** បាទ ថ្នាក់លើសំដៅប្រធានកងពល និងភូមិភាគ។

**ស៖** អរគុណលោក។ នៅក្នុងរចនាសម្ព័ន្ធនេះ ខ្ញុំឃើញមានភូមិភាគចំនួនពីរ គឺភូមិភាគនិរតី និងភូមិភាគបស្ចិម ខេត្តកោះកុង។ តើហេតុអ្វីលោកនាំកងទ័ពមួយកងវរសេនាធំចេញទៅភូមិភាគបស្ចិមបាន ដោយងាយដូច្នេះបាទ?

[១៥:១៨:០៧]

**ឆ៖** បាទ នេះក្នុងការរៀបចំរបស់ភូមិភាគ និងកងពល គាត់រៀបចំអ៊ីចឹង។

**ស៖** តើលោកអាចជួយពន្យល់ថាតើវាមានការយល់ព្រមពីគណៈមជ្ឈិម ឬក៏អគ្គសេនាធិការទេ? ពីព្រោះកងវរសេនាធំរបស់លោកមាន៦.០០០នាក់ ហើយលោកបញ្ជូន ៦.០០០នាក់ទៅភូមិភាគបស្ចិមនោះ តើមជ្ឈិម ឬក៏អគ្គសេនាធិការហ្នឹងអាចដឹងពីបញ្ហាហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំត្រង់សំណួរត្រង់នេះ ខ្ញុំមិនទាន់ស្តាប់បានទេ។

**ស៖** នេះចម្លើយរបស់លោកទេ ខ្ញុំអានចម្លើយលោកសាជាថ្មី លោកថា "លោកនៅភូមិភាគនិរតីហើយលោកកាន់កង មួយកងវរសេនាធំ បន្ទាប់មកលោកផ្លាស់ទៅកោះកុង ទៅភូមិភាគបស្ចិមវិញហើយកងពលរបស់លោកហ្នឹង អំ! កងវរសេនាធំរបស់លោក បើតាមលោកឆ្លើយខាងដើមថាមាន៦ទៅ ៧ពាន់នាក់ណោះ។ អ៊ីចឹងការផ្លាស់មនុស្ស ៦-៧ពាន់នាក់ ឆ្លងកាត់ពីៗភូមិភាគនិរតីទៅភូមិភាគបស្ចិមហ្នឹង តើត្រូវឆ្លងកាត់អគ្គសេនាធិការ ឬក៏ឆ្លងកាត់គណៈមជ្ឈិមដែរទេ?

[១៥:២០:០២]

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកអ៊ីចេះ ក្នុងពេលដែលរំដោះហើយនោះ ភូមិភាគនិរតី និងបស្ចិមមិនទាន់ៗបែងចែកភ្លាមទេ។ ដល់ការបែងចែករំដោះបានប្រហែលជា៥-៦ខែ បានបែងចែកភូមិភាគនិរតីបស្ចិមជាពីរ។ ហើយក្នុងពេលនោះបានមានកងទ័ពនិរតីផ្សេង កងទ័ពបស្ចិមផ្សេង។ ដូច្នេះ ខ្ញុំមកខាងកងទ័ព ខាងបស្ចិម។ ហើយក្នុងពេលដែលគេបញ្ជូនខ្ញុំទៅកាន់សមរភូមិផ្សេងៗនោះ អាហ្នឹងខ្ញុំមិនដឹងថាខាងភូមិភាគ ពិគ្រោះគ្នា ឬប្រជុំគ្នាយ៉ាងណានោះទេ។ ខ្ញុំអត់បានដឹងដល់ថ្នាក់ ដល់មជ្ឈិមនោះទេ ខ្ញុំដឹងត្រឹមតែឋានៈភូមិភាគ ហើយពេលនោះខ្ញុំដឹងថា ពេលនោះបានបែងចែកកងទ័ពរបស់បស្ចិមផ្សេងហើយខ្ញុំមួយវរសេនាធំ អំ! មួយកងពលខាងបស្ចិម ខ្ញុំមកនៅខាងភូមិភាគបស្ចិម។ ហើយពេលនោះ គេបញ្ជូន

ខ្ញុំមួយវរសេនាធំកន្លះទៅកោះកុង។ ហ្នឹងក៏ដោយសារពីភូមិភាគដែរបាទ។

[១៥:២១:៥៩]

**ប្រធានអង្គជំនុំ៖**

បើក១ ក្បាលមេក្រូផង!

**លោក វ៉េង ហ៊ត់៖**

អរគុណលោកប្រធាន!

**សួរដោយលោក វ៉េង ហ៊ត់៖**

**ស៖** អរគុណដែលលោកបានបំភ្លឺថា លោកមិនបានដឹងច្បាស់ទាក់ទងជាមួយនឹងគណៈមជ្ឈិម និងអគ្គសេនាធិការនៅក្នុងការបែងចែករវាងភូមិភាគមួយ ទៅភូមិភាគមួយ។ ប៉ុន្តែខ្ញុំមានសំណួរជូនលោកបន្តទៀត នៅពេលដែលលោកបានទៅភូមិភាគបស្ចិម លោកបានក្លាយជាអនុប្រធាន កងពលលេខ១។ ឋានៈរបស់លោកបានឡើងហើយនៅខេត្តកោះកុង ហើយលោកបានមានប្រសាសន៍ថា "លោកមានតួនាទីការពារព្រំដែនសមុទ្រ និងព្រំដែនគោក។ លោកថា ធ្លាប់ប្រយុទ្ធជាមួយកងទ័ពថៃរយៈពេល១សប្ដាហ៍"។ ហើយចម្លើយ សំណួរចម្លើយនេះនៅក្នុងលេខរៀងទី៧។ ខ្ញុំចង់សួរលោកថា តើលោកទទួលបញ្ជាឲ្យប្រយុទ្ធពីអ្នកណាដែរនៅក្នុងការប្រយុទ្ធជាមួយទ័ពថៃហ្នឹង?

[១៥:២៣:២៩]

**លោក មាស វឿន៖**

**ឆ៖** បាទ ក្នុងការដែលខ្ញុំទទួលបញ្ជាទៅកាន់ព្រំដែនសមុទ្រជាប់ជាមួយនឹងថៃនោះ ក្នុងពេលដែលមានការប៉ះពាល់ខាងយោធាជាមួយថៃនោះ ដោយបានទទួលបញ្ជាពីប្រធានកងពល។ ហើយក្នុងនោះ ក៏ឃើញថា កងពលក៏ទទួលពីអគ្គសេនាធិការដែរ ហ្នឹងគាត់បានប្រាប់អ៊ីចឹង។ ហើយក្នុងការដែលប៉ះពាល់ជាមួយថៃនោះ ដោយថៃឈ្លានពានរំលោភលើដែនទឹករបស់យើង ពិសេសគឺអូសត្រី និងកៅឡាក់ព្រំដែនបាទ។

**ស៖** តាមឯកសារនេះ ឃើញថាការប្រយុទ្ធគ្នាហ្នឹង១សប្ដាហ៍ឯណោះ។ អ៊ីចឹងខ្ញុំចង់សួរថាតើលោកមានបានចាប់បានកងទ័ព ឬក៏ចាប់បានជនបរទេសនៅក្នុងអំឡុងពេលនៃការប្រយុទ្ធនោះដែរទេ?

**ឆ៖** បាទ ក្នុងពេលប្រយុទ្ធគ្នានោះ មិនបានចាប់បានរៀងខ្លួនទេ ដោយប្រើយន្តហោះ ថៃប្រើយន្តហោះទម្លាក់លើកោះច្រើន ហើយយើងដកថយខ្លះមក ហើយយើងក៏បាញ់កាំភ្លើងធំដាក់វាខ្លះទៅ

ក៏ដកថយរៀងខ្លួន ប្រហែលជា១អាទិត្យបានមានការស្ងប់ស្ងាត់ បាទ។

**ស៖** តើក្រោយពីការប្រយុទ្ធ ដែលលោកការពារនៅដែនសមុទ្រហ្នឹង តើមានចាប់បានជនបរទេសដែរទេ?

[១៥:២៥:៤៩]

**ឆ៖** បាទ អត់មានបានចាប់បានទេ។

**លោក វ៉េង ហ៊ាត់៖**

ខ្ញុំសូមអរគុណលោក វឿន ដែលបានមកជួយបំភ្លឺនៅក្រុមការងារខាងសហព្រះរាជអាជ្ញាជាតិ ហើយសហព្រះរាជអាជ្ញាបរទេសអន្តរជាតិ គាត់នឹងសួរលោកបន្តទៀត។

អរគុណលោកប្រធាន និងក្រុមប្រឹក្សាទាំងអស់បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព។ សួស្តីភាគីទាំងអស់ សូមជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ថារីក ហើយខ្ញុំមានសំណួរមួយចំនួនបន្ថែមទៀតចង់សួរលោកអំពីបទពិសោធន៍ដែលលោកធ្លាប់មានពីមុនមក។ ជាពិសេសបទពិសោធន៍មុន និងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំសូមថ្លែងអំណរគុណលោកដែលលោកមកទីនេះ ជួយស្វែងរកការពិតដល់អង្គជំនុំជម្រះសាលាដំបូង នូវអ្វី ហើយបង្ហាញនូវអ្វីដែលលោកដឹង។ យើងខ្ញុំសូមថ្លែងអំណរគុណដែលលោកបានចំណាយពេលនៅទីនេះ។

[១៥:២៧:៥៣]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្ញុំសូមចាប់ផ្តើមសួរលោក ដោយសួរបន្តសំណួរបន្ថែមទៀត។ ជាពិសេសក្នុងអំឡុងពេលដែលលោកទើបតែឆ្លើយប្រាប់សហសេវិកតំណាងសហព្រះរាជអាជ្ញាជាតិ គឺអំឡុងពេលដែលលោកធ្វើការងារក្នុងជួរបដិវត្តន៍។ លោកបានប្រាប់តំណាងសហព្រះរាជអាជ្ញាជាតិថា លោកបានចូលរួមបដិវត្តន៍នៅក្នុងឆ្នាំ៦៨ ហើយនៅពេលនោះលោកជាតំណាងយុវជននៅក្នុងភូមិរបស់លោក។ តើលោកអាចជម្រាបយើងខ្ញុំបន្ថែមបានដែរទៀតដែរឬទេ? តើនៅពេលចូលបដិវត្តន៍ធ្វើតំណាងយុវជននោះ លោកធ្វើ

ការងារអ្វីខ្លះដែរ ឲ្យជាក់លាក់?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំតំណាងឲ្យយុវជនតាមភូមិនោះ ខ្ញុំបានប្រាប់ -- បានអប់រំគេឲ្យគេស្គាល់ពីរឿងប្រទេសយើងមិនបានឯករាជ្យ ហើយដោយសារអាណានិគមបារាំង ហើយសេដ្ឋកិច្ចដែលនៅក្រោមអាណានិគមបារាំងគ្រប់គ្រងទាំងអស់ ហើយខ្មែរយើងគ្មានការឯករាជ្យ និងបានផ្សព្វផ្សាយដល់ក្រុមយុវជនតាមភូមិឲ្យគេដឹងយល់ ហៅថាអប់រំឲ្យគេដឹងយល់ពីប្រទេសរបស់ខ្លួនអ៊ីចឹងបាទ។

**ស៖** សូមអរគុណ។ ក្នុងអំឡុងឆ្នាំនេះដដែល គឺមុនរដ្ឋប្រហារ លោកបានប្រាប់តំណាងសហព្រះរាជអាជ្ញាជាតិថា "មុនរដ្ឋប្រហារនោះគឺ លោកជាកងការពាររបស់កម្មាភិបាលរត់ពីភ្នំពេញចូលទៅតាមទីជនបទ"។ តើលោកនៅចាំដែរឬទេថា នៅក្នុងឆ្នាំណាដែរ ដែលលោកក្លាយជាកងការពាររត់ទៅជនបទ ជាមួយនឹងកម្មាភិបាលនោះ ដោយលោកបញ្ជាក់មើលនៅក្នុងមុនរដ្ឋប្រហារហ្នឹងគឺឆ្នាំណា ៦៨ ឬក៏៦៩?

[១៥:៣០:១៨]

**ឆ៖** បាទ ការដែលកម្មាភិបាលបែកពីក្នុងក្រុងភ្នំពេញទៅនោះ គឺឆ្នាំ១៩៦៨ដែរ តែវាពាក់កណ្ដាលជិតដាច់ហើយ ដែលគាត់រត់ចេញទៅ ហើយគាត់ទៅចូលព្រៃ។ ហើយខ្ញុំការពារថែរក្សាគាត់ កុំឲ្យគាត់មានការលំបាកចិត្ត ការពារគ្រោះថ្នាក់របស់គាត់បាទ។

**ស៖** សូមអរគុណ។ ភូមិកំណើតរបស់លោក គឺនៅកំពង់ស្ពឺ នៅក្នុងស្រុកភ្នំស្រួច តើលោកធ្វើជាអ្នកការពារសម្រាប់កម្មាភិបាល នៅក្នុងស្រុកនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំកាលនោះអត់ទាន់ៗ កើតជាកម្មាភិបាលនឹងគេទេ ខ្ញុំកើតជាយុវជនបាទ។

**ស៖** សូមអធ្យាស្រ័យប្រហែលជាមានការបកប្រែច្រឡំ។ ខ្ញុំមិនមែនលើកឡើងថា លោកជាកម្មាភិបាលនោះទេ ខ្ញុំគ្រាន់តែថា លោកធ្វើជាកងការពារសម្រាប់កម្មាភិបាលនៅក្នុងស្រុកនុ៎ង។ ខ្ញុំគ្រាន់តែចង់សួរលោកថា នៅពេលដែលលោកធ្វើជាអ្នក -- ធ្វើជាកងការពារនោះ គឺលោកធ្វើកងការពារនៅក្នុងស្រុករបស់លោក ក្នុងឃុំរបស់លោក ឬក៏លោកធ្វើកងការពារនៅឃុំស្រុកផ្សេង មិនមែនស្រុកកំណើតរបស់លោក?

[១៥:៣២:១៧]

**ឆ៖** បាទ នៅក្នុងការពារកម្មាភិបាលនោះ ជំនាន់នោះនៅក្នុងស្រុកខ្ញុំខ្លះ ហើយក៏នៅស្រុកគេខ្លះ

តាមខេត្តគេខ្លះ ដូចជាខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង ដែលមានការជាប់គ្នាបាទ។

**ស៖** លោកបានឆ្លើយប្រាប់អំពីលោក វន វ៉េត ហើយនិងលោក ខៀវ សំផន ក្នុងអំឡុងឆ្នាំនោះ តើលោកមាននៅជាមួយនឹង វន វ៉េត និង ខៀវ សំផន ដែរឬទេក្នុងពេលដែលលោកធ្វើជាការពារនោះ?

**ឆ៖** បាទ ខ្ញុំក្នុងការដែលពេលការពារគាត់នោះ យូរៗខ្ញុំឃើញគាត់ម្តង។ មិនមែនជានៅជាមួយជាប់រាល់ថ្ងៃទេ ប៉ុន្តែគាត់កន្លែងគាត់នៅដោយផ្សេងទេ។ ក៏ប៉ុន្តែខ្ញុំនៅឆ្ងាយ ដូចថា ការពារតាមផ្លូវ តាមអី កុំឲ្យគេដើរទៅក្រែងលោគេធ្វើបាបធ្វើអីគាត់។ ខ្ញុំអត់បាននៅជាមួយរាល់ថ្ងៃនោះទេបាទ។

**ស៖** សូមអរគុណ។ ខ្ញុំសូមបញ្ជាក់បំភ្លឺចំណុចតូចមួយ។ តើពួកគាត់ទាំងពីរនោះ ស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ ឬក៏កំពង់ឆ្នាំង? ពួកគាត់ទាំងពីរនោះ គឺនៅក្នុងខេត្តមួយណាដែរ នៅពេលដែលលោកធ្វើជាកងការពារឲ្យពួកគាត់?

**ឆ៖** បាទ ជួនកាលគាត់នៅកំពង់ស្ពឺ គាត់មិនបាននៅតាមភូមិទេ គាត់នៅក្នុងព្រៃ ហើយនៅកំពង់ស្ពឺនៅម្តុំក្នុងព្រៃធំ គេហៅព្រៃធំៗ នៅព្រៃធំ ហើយកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង គាត់ចង់ -- គេចង់យកគាត់ទៅនៅឱរ៉ាល់ទៅ ក៏ទៅនៅឱរ៉ាល់ នៅក្នុងព្រៃមិនបាននៅក្នុងភូមិទេបាទ។

[១៥:៣៤:៥៥]

**ស៖** តើលោកទទួលភារៈការពារអ្នកផ្សេងទៀតដែរឬទេ ក្រៅពី វន វ៉េត និង ខៀវ សំផន នៅក្នុងអំឡុងឆ្នាំនោះ?

**ឆ៖** បាទ ទាំងអស់ ឲ្យតែអ្នកដែលមកចេញពីភ្នំពេញ ឬក៏នៅក្នុងស្រុករបស់គាត់មិនបាន គាត់ចេញមក ខ្ញុំការពារទាំងអស់។ ព្រោះក្រុមខ្ញុំមានប្រហែលជាៗសាមសែសិបនាក់ សម្រាប់នាំផ្លូវរក កន្លែងរកអីឲ្យគាត់ ទុកគាត់អីហ្នឹង បាទ។

**ស៖** តើអ្នកទាំងអស់នុ៎ង មានរួមទាំង ហ៊ូ នឹម និង ហ៊ូ យន់ ដែរឬទេ?

**ឆ៖** បាទ រួមមានទាំងអស់ ហ៊ូ យន់, ហ៊ូ នឹម, ខៀវ សំផន, ប៉ុក ដឹសកុមារ, ទីវ អុល និងច្រើនទៀត ខ្ញុំមិនបានចាំអស់ បាទ។

[១៥:៣៦:១៩]

**ស៖** សូមអរគុណ។ យើងកំពុងតែនិយាយអំពីក្រុម ដែលលោកជាតំណាងនៅក្នុងហ្នឹងផងដែរ តើនៅក្នុងក្រុមរបស់លោក ក្រុមការពាររបស់លោក គឺមានសមាជិកចំនួនប៉ុន្មានដែរ?

**ឆ៖** បាទ កាលឆ្នាំ៦៨ ខ្ញុំមានតែមួយក្រុមទេ ប្រហែលជា២០នាក់ តែឆ្នាំ៧០ ខ្ញុំមានប្រហែល

ជាៗ ១៥០នាក់។ នៅឆ្នាំ១៩៧០ រដ្ឋប្រហារ បាទ។

**ស៖** តើលោកអាចជម្រាបអង្គសវនាការបានដែរឬទេ ថាតើនរណាគេជាប្រធានក្រុមដែលមានគ្នា២០នាក់ ដូចដែលលោកបានបញ្ជាក់អម្បាញ់មិញនេះ ប្រធានគឺនរណាដែរ?

**ឆ៖** បាទ ប្រធាន គឺឈ្មោះ មឿន គាត់ជាកម្មាភិបាល តែស្លាប់ហើយ។ ហើយបីនាក់ទៀត ខ្ញុំមិនបានចាំ អ៎! ប៊ុនៗ មួយទៀត ដែលខ្ញុំចាំ។ ហើយម្នាក់ទៀត ខ្ញុំមិនបានចាំ ស្លាប់អស់ហើយ។

**ស៖** សូមអរគុណ។ តើលោកអាចជម្រាបប្រាប់តុលាការផងដែរឬទេ ថាតើនរណាគេជាអ្នកចាត់តាំងលោកឲ្យចូលទៅធ្វើការនៅក្នុងក្រុមដែលមានសមាជិក២០នាក់នេះ?

**ឆ៖** បាទ កាលណោះមាន តាម៉ុក។

**ស៖** នៅក្នុងអំឡុងពេលនោះ តើលោកបានដឹងអ្វីខ្លះ ជាពិសេសតួនាទីរបស់លោក ខៀវ សំផន នោះ តើគាត់មានតួនាទីអ្វីដែរ?

**ឆ៖** បាទ ខ្ញុំអត់ដឹងតួនាទីរបស់គាត់ថាជាអ្វីទេ។ គាត់នៅក្នុងព្រៃ ដឹងថាគាត់ជាអ្នកដែលស្នេហាជាតិប៉ុណ្ណឹង ដឹងតែប៉ុណ្ណឹងបាទ។ តួនាទីភារកិច្ចរបស់គាត់ ខ្ញុំអត់បានដឹង។

[១៥:៣៩:២៥]

**ស៖** ក្រៅពីចំណុចហ្នឹង ដែលលោកដឹង។ តើលោកអាចជម្រាបជូនយើងខ្ញុំបានដែរទេ ថាតើនៅពេលនោះ អំឡុងឆ្នាំ៦៨ ទៅដល់៦៩ មុនរដ្ឋប្រហារនោះ លោក ខៀវ សំផន ធ្វើការងារអ្វីដែរ?

**ឆ៖** បាទ ខ្ញុំដឹងថា ជំនាន់នោះ ខ្ញុំមិនបានស្គាល់គាត់ច្បាស់លាស់ទេ ក៏ប៉ុន្តែខ្ញុំស្តាប់តាមតែវិទ្យុដែលពេលគាត់ប្រជុំសមាជជាមួយនឹងសម្តេចឪម្តងៗហ្នឹង គាត់ធ្វើជាកុង្សីសេដ្ឋកិច្ច។

**ស៖** នៅក្នុងរយៈកាលដែលលោកជាសមាជិកកងការពារនៅក្នុងអង្គភាព និងក្រុមហ្នឹង តើគាត់ធ្វើការងារអីដែរ?

**ឆ៖** បាទ ខ្ញុំអត់ទាន់ស្តាប់បាន។

**ស៖** សូមអរគុណ។ នៅក្នុងអំឡុងឆ្នាំមុនរដ្ឋប្រហារ ដែលលោកធ្វើការងារនៅក្នុងកងការពារក្នុងព្រៃ។ តើលោក ខៀវ សំផន គាត់ធ្វើការអ្វីខ្លះនៅក្នុងព្រៃ?

**ឆ៖** បាទ គាត់នៅក្នុងព្រៃ គាត់អត់មានធ្វើអីផង ប៉ុន្តែបើខ្ញុំស្តាប់តាមប៉ុស្តិ៍ គេថា គាត់បានទទួល -- ខ្ញុំស្តាប់តែតាមប៉ុស្តិ៍ទេ គាត់បានទទួលធ្វើជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា។

[១៥:៤១:៥៤]

**ស៖** ខ្ញុំគ្រាន់តែសួរបញ្ជាក់លោកឲ្យបានច្បាស់ដែលថាពេលដែលខ្ញុំសួរនេះគឺក្នុងអំឡុងពេលអំមិញដដែលទេ គឺក្នុងអំឡុងពេលនៅក្នុងព្រៃមុនរដ្ឋប្រហារ។ ខ្ញុំដឹងថារយៈពេលហ្នឹងកន្លងហួសយូរមកហើយ តើនៅក្នុងអំឡុងដែលនៅក្នុងព្រៃមុនរដ្ឋប្រហារហ្នឹង តើលោកនៅចាំទេ ថាលោក ខៀវ សំផន នោះធ្វើការងារអ្វីខ្លះដែរ?

**ឆ៖** បាទ គាត់អត់បានធ្វើការងារអ្វីផង គាត់នៅតែតាមតែកន្លែងរបស់គាត់ ខ្ញុំមិនបាននៅជាប់ជាមួយគាត់ទេ គាត់មិនដឹងជាគាត់ធ្វើការងារអីគាត់ទេ ខ្ញុំមិនសូវដឹងដែរ។

**ស៖** សូមអរគុណ។ តើនៅពេលនោះៗមានការប្រជុំរវាង ខៀវ សំផន, តាម៉ុក, និងអ្នកផ្សេងទៀតដែលលោកការពារដែរឬទេ?

**ឆ៖** បាទ ខ្ញុំពេលគាត់ប្រជុំកិច្ចការងារ ខ្ញុំអត់បានដឹងទេ។ ការងាររបស់គាត់ខាងលើអ៊ីចឹង ខ្ញុំអត់បានទទួលដឹងទេ។

**ស៖** ក្នុងនាមលោកជាកងការពារ តើគេមានដែលធ្លាប់ស្នើសុំឲ្យលោកនេះចាត់តាំងឲ្យលោកនេះយកសារណាមួយទៅឲ្យពួកគេដែរឬទេ?

[១៥:៤៣:៣២]

**ឆ៖** បាទ អត់មានទេ។

**ស៖** ហើយតើគោលបំណងនៃការផ្លាស់កន្លែង ដូចដែលលោកបានរៀបរាប់ថាម្ដងគេឲ្យនៅកំពង់ស្ពឺ ម្ដងឲ្យនៅកំពង់ឆ្នាំងនោះ តើហេតុអ្វីបានជាគេឲ្យធ្វើអ៊ីចឹង? ហើយពេលខ្លះទៅនៅដល់ភ្នំ លើភ្នំឱរ៉ាល់នោះ? ហេតុអ្វីបានជាគេចាត់តាំងឲ្យមានការផ្លាស់ទីកន្លែងដូច្នេះ?

**ឆ៖** បាទ កាលដែលផ្លាស់ទីកន្លែងនោះ គឺខ្លាចខ្មាំងរកគាត់ឃើញ។

**ស៖** តើនរណាគេជាអ្នកចេញសេចក្ដីសម្រេច ថាត្រូវតែធ្វើការផ្លាស់ទីកន្លែង ពីកន្លែងមួយទៅកន្លែងមួយទៀតដូច្នេះ?

**ឆ៖** បាទ តាម៉ុក។

**ស៖** តើខ្ញុំយល់ត្រឹមត្រូវដែរឬទេថា តាម៉ុក ជាអ្នកនៅ -- ជាបញ្ជាការក្រុមកងការពាររបស់លោកដដែលនោះ ក្នុងពេលដែលលោកធ្វើការការពារ ខៀវ សំផន និងអ្នកផ្សេងនោះ។ គឺគាត់នៅតែជាមេបញ្ជាការដដែល អ៊ីចឹងដែរឬទេ?

**ឆ៖** បាទ គាត់ តាម៉ុក គាត់ក្ដាប់រហូតតាំងពីក្រុមការ កងការពារ តាំងពីកកើតកងទ័ពរៀបចំកងទ័ព ពីដើម ពីមុន គឺលើ តាម៉ុក ទាំងអស់បាទ។

[១៥:៤៦:00]

**ស៖** សូមអរគុណ។ តើលោកធ្វើការជាកងការពារឲ្យលោក ខៀវ សំផន និងអ្នកផ្សេងទៀតដែលលោកនៅជាមួយនោះ គឺធ្វើការងារហ្នឹងយូរប៉ុនណាដែរ?

**ឆ៖** បាទ ខ្ញុំធ្វើពីឆ្នាំ៦៨ ដល់ឆ្នាំ៦៩។ ៧០ ខ្ញុំធ្វើការកងទ័ពវិញ ខ្ញុំបានបែកចេញពីគាត់ អស់ហើយ។

**ស៖** នៅពេលដែលលោកបែកទៅធ្វើកងទ័ពនៅក្នុងឆ្នាំ៧០ តើអ្នកទាំងអស់ដូចជា ខៀវ សំផន វន វេត, ហ៊ូ នឹម នេះទៅណាវិញ នៅពេលដែលលោកបែកទៅធ្វើកងទ័ពនោះ?

**ឆ៖** បាទ ត្រង់នេះខ្ញុំមិនដឹងថា តាម៉ុក យកគាត់ទៅដាក់កន្លែងណាទេ ខ្ញុំមិនបានដឹងទេ ព្រោះខ្ញុំនៅចេញពីគាត់ទៅនៅក្នុងជួរកងទ័ពទៅ។ ខ្ញុំគិតក្នុងកិច្ចការងារសមរភូមិ អត់ទៅបានការពារគាត់វិញទៀតទេបាទ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកនិយាយថា លោកមិនដឹងថា តាម៉ុក យកពួកគាត់ទៅណាអស់នោះ។ ដូច្នេះចំណុចហ្នឹងមានន័យថា នៅពេលនោះ ពួកគាត់ទាំងអស់ហ្នឹងគឺនៅជាមួយ តាម៉ុក ដដែល។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ បើតាម -- ខ្ញុំមិនបានឃើញទេ ប៉ុន្តែតាមគិតមើលនៅលើ តាម៉ុក ដដែល។

**ស៖** សូមអរគុណលោកច្រើន។ យើងបានស្ដាប់ពីមុននេះអំពីការពិពណ៌នារៀបរាប់របស់លោកអំពីសមរភូមិ ដែលលោកចូលរួមវៃក្នុងសមរភូមិនោះផងដែរ។ ខ្ញុំសូមសួរបញ្ជាក់នូវចំណុចមួយ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយសហព្រះរាជអាជ្ញា ឯកសារ E3/424, សំណួរទី១ លោកបានរៀបរាប់ថា នៅក្នុងឆ្នាំ៧០ និរតីបានបែងចែកកងវរសេនាធំចំនួន៣ តាសុង គឺជាមេបញ្ជាការ ហើយលោកត្រូវបានធ្វើឲ្យ ធ្វើកង ធ្វើជាមេកងវរសេនាធំលេខ១៦។

[១៥:៥០:០១]

នៅក្នុងឆ្នាំ១៩៧៣ នោះគឺលោកបានតែងតាំងឲ្យធ្វើកងវរសេនាធំ -- កងវរសេនាតូច១៣៦។ ដូច្នេះហើយខ្ញុំសូមសួរបញ្ជាក់ទៅត្រង់ចំណុចនេះ ដែលមានលក្ខណៈខុសគ្នា។ ថាតើលោកនៅពេលនោះត្រូវបានតែងតាំងជាប្រធានកងវរសេនាតូច ឬក៏ជាកងវរសេនាធំ?

**ឆ៖** បាទ មិនមែន ខ្ញុំអត់ដឹងថាឈ្មោះ តាសុង នោះទេ ខ្ញុំដឹងតែឈ្មោះ តាសឿង។ ហើយក្នុងឆ្នាំ ១៩៧០, ៧០ ខ្ញុំជាវរសេនាតូចនៅឡើយទេ។ ដល់ពេលឆ្នាំ៧៥ ខ្ញុំបានជាវរសេនាធំ តែក៏មិនទាន់មាន ពេញសិទ្ធិដែរ។ ក្នុងហ្នឹងគឺ តាសឿង គាត់តែងតាំងខ្ញុំ មិនមែន តាសុង ទេ។

[១៥:៥១:០៧]

**ស៖** សូមអរគុណដែលបានកែតម្រូវ ការអានឈ្មោះរបស់ខ្ញុំ ខ្ញុំចង់និយាយថា សឿង តែខ្ញុំអាន មិនត្រូវ។ នៅពេលនោះគឺលោកត្រូវបានដំឡើងជាប្រធានវរសេនាធំ នៅក្នុងឆ្នាំ៧៥។ ដូច្នេះ គឺការដំឡើង នេះ គឺមុនការវាយប្រហារចូលទីក្រុងភ្នំពេញ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ។

**ស៖** តើលោកនៅចាំខែទេ? ខែណាដែរ ដែលគេចាត់តាំងដំឡើងជាប្រធានវរសេនាធំដល់លោក នោះ?

**ឆ៖** ខ្ញុំមិនបានចាំខែថ្ងៃទេ ព្រោះក្នុងសមរភូមិមិនសូវបានគិតគូរពីថ្ងៃខែបាទ។

**ស៖** សូមអរគុណ។ ចំណុចមួយទៀតដែលលោកបានឆ្លើយប្រាប់តំណាងសហព្រះរាជអាជ្ញា ជាតិ ហើយខ្ញុំចង់សួរសំណួរបន្តិចផងដែរ។ នៅតាមផ្លូវជាតិលេខ៥ ប្រសិនបើខ្ញុំស្ដាប់មិនខុសនោះទេ គឺ លោក១ ចូលរួមសមរភូមិនៅក្រគរ តាមផ្លូវទៅកំពង់ឆ្នាំង ហើយចូលរួមសមរភូមិនេះនៅក្នុងទីនោះ វាយចូលទីក្រុងភ្នំពេញ។ តើលោកមានចូលរួមវាយសមរភូមិនៅតំបន់ម្ដុំឧដុង្គដែរឬទេ?

[១៥:៥៣:០៥]

**ឆ៖** បាទ មាន។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានដែរឬទេថា ឬក៏លោកអាចជួយពិពណ៌នារៀបរាប់ សមរភូមិនោះបន្តិចទៅមើល? តើនៅក្នុងឆ្នាំណាដែរ នៅពេលណាដែលលោកចូលរួមវាយសមរភូមិនៅ ម្ដុំឧដុង្គ? ហើយនៅពេលណាដែរ ដែលខ្មែរក្រហមចាប់យកឧដុង្គនោះ?

**ឆ៖** បាទ ក្នុងការប្រយុទ្ធគ្នានៅលើផ្លូវលេខ៥ នោះ គឺកងទ័ព កាលនោះកងទ័ពនិរតីចាប់ពីត្រឹម ខាងកើតក្រគរ មកទល់គ្នាកំពង់ឆ្នាំង ហើយមកទល់គ្នាឧដុង្គនោះ បញ្ចូលរួមមកដោយ តាម៉ុក ហើយនិង តាសឿង។ ហើយវ៉ៃតាមផ្លូវហ្នឹងមករហូត មកដល់ឧដុង្គ ក៏ប៉ុន្តែវ៉ៃក្នុងពេលនោះវាមានឈ្មះមានចាញ់ៗ ទម្រាំបានដល់ឧដុង្គ ហ្នឹងគឺថាវាស្លាប់ របួសច្រើន ដោយសារគ្រាប់យន្តហោះពីលើផង ហើយកាំភ្លើង ផ្គោងពីក្រោមផង។ ដូច្នេះពេលនោះរំដោះឧដុង្គ ខ្ញុំមិនដឹងថ្ងៃខែប៉ុន្មានទេ ប៉ុន្តែប្រហែលជាឆ្នាំ៧៣, ៧៣-

៧៤ អីប៉ុណ្ណឹងឯង។ ហើយក្នុងការវ៉ៃផ្លូវលេខ៥ នោះ អត់មានថ្ងៃសម្រាកទេ ចប់រដូវប្រាំង តរដូវវស្សា ចប់រដូវវស្សាតរដូវប្រាំង ចប់អត់មានពេលសម្រាក។ ៦ខែ វស្សា ៦ខែ ប្រាំង។ បាទ ប៉ុណ្ណេះ។

[១៥:៥៥:៣៥]

**ស៖** តើនៅចុងក្រោយនោះ នៅពេលណាចុងក្រោយ ដែលលោកខាងលោកនេះ វាយដណ្ដើមយកឧដុង្គបាន? តើលោកនៅចាំទេមានអ្វីកើតឡើងចំពោះប្រជាជន ដែលរស់នៅក្នុងឧដុង្គតំបន់ឧដុង្គនោះ? តើប្រជាជននៅបន្តរស់នៅទីនោះដដែល ឬក៏ប្រជាជនធ្វើដំណើរផ្លាស់ប្ដូរកន្លែងទៅរស់នៅកន្លែងផ្សេង?

**ឆ៖** បាទ ចុងក្រោយក្នុងសមរភូមិផ្លូវលេខ៥ នេះ ពេលដែលវ៉ៃគ្នាហើយ ប្រជាជនរត់តំបន់រំដោះ។ ភាគច្រើនគេ អត់នៅតាមផ្លូវនេះទេ។ នៅចេញទៅតំបន់រំដោះអស់ ទៅក្រោយៗអស់។ ដូច្នេះនៅតែទាហានខ្មែរក្រហម និងទាហាន លន់ នល់ ដែលមានការប្រយុទ្ធគ្នាបាទ។ មិនដឹងជាថ្ងៃខែប៉ុន្មានខ្ញុំអត់បានចាំទេ។

**ស៖** បើមិនចាំក៏មិនអីដែរ ក៏ប៉ុន្តែខ្ញុំអាចយល់តាមចម្លើយរបស់លោកនេះគឺថា ប្រជាជនរត់ទៅរស់នៅក្នុងតំបន់រំដោះៗ។ តើលោកចង់ឲ្យខ្ញុំសួរសំណួរឡើងវិញដែរឬទេ? តើប្រជាជននោះគាត់រត់ទៅនៅតំបន់រំដោះ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ។

**ស៖** ខ្ញុំគិតថា លោកប្រហែលជាហត់ហើយ យើងជិតដល់ម៉ោងបួន ជិតដល់ពេលសម្រាក។ យើងបាននិយាយ អំពីស្ថានភាពដែលប្រជាជននេះ រត់ទៅរស់នៅក្នុងតំបន់រំដោះ គេចពីសមរភូមិ។ ដូច្នេះ ខ្ញុំចង់សួរបញ្ជាក់លោកម្ដងទៀត ថាតើនៅពេលនោះ ប្រជាជនដែលរស់នៅក្នុងតំបន់ឧដុង្គនោះ ក៏រត់ទៅរស់នៅក្នុងតំបន់រំដោះផងដែរ នៅពេលដែលកន្លែងនៅទីក្រុងឧដុង្គនោះ ត្រូវបានវាយដណ្ដើមយកដោយខ្មែរក្រហមនោះ? តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

[១៥:៥៨:២៤]

**ស៖** តើប្រជាជននៅក្នុងតំបន់ឧដុង្គនោះ មានចំនួនប្រហែលប៉ុន្មានដែរ?

**ឆ៖** បាទ ខ្ញុំមិនបានដឹងចំនួនទេ។ ត្រង់ដែលប្រជាជនចេញទៅតំបន់រំដោះនោះ វាស្ថិតនៅលើអ្នកកាន់កាប់ទទួលខុសត្រូវប្រជាជននៅខាងក្រោយ។ ឯខាងមុខ អត់បានដឹងថាប៉ុន្មានៗអត់ដឹងទេបាទ។

**ស៖** តើមាននរណាម្នាក់ ដែលទទួលភារៈ ទទួលបន្ទុកចាត់តាំងរៀបចំប្រជាជនយកពីកន្លែងសមរភូមិនេះ ទៅដាក់នៅតំបន់រំដោះដែរឬទេ? តើមាននរណាម្នាក់ទទួលបន្ទុកការងារហ្នឹងដែរឬទេ?

**ឆ៖** បាទ ក្នុងនោះមានៗប្រធានកងពល ហើយក៏មានប្រធានភូមិ សហការគ្នា។ បើប្រធានភូមិខ្ញុំមិនស្គាល់អស់ទេក្នុងនោះ វាមានប្រធានភូមិច្រើន ដែលសម្រាប់ទទួលប្រជាជនដែលចេញពីឧដុង្គទៅតំបន់រំដោះ។ ហ្នឹង ខ្ញុំមិនបានចាំឈ្មោះទេ អ្នកដែលទទួលខាងក្រោយៗ ខ្ញុំដឹងថា ចេញពីកងពល ចេញពីតាសឿង ទៅគឺចូលទៅដល់ភូមិគេ គឺមានប្រធានភូមិគេយកទៅដាក់ត្រង់ណាៗ ខ្ញុំមិនបានដឹងទេ។ ដឹងតែអ៊ីចឹង ក៏ប៉ុន្តែការស្គាល់មេភូមិមិនច្បាស់ទេ ហ្នឹងបាទ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ដោយខ្ញុំពិនិត្យទៅមើលលើម៉ោង គឺខ្ញុំអាចបន្តសួរសំណួរទៅមុខទៀតបាន ក៏ប៉ុន្តែគឺអាស្រ័យទៅលោកប្រធាន តើលោកប្រធាន ចង់ឲ្យខ្ញុំបន្តទៀត ឬក៏យើងឈប់សម្រាកត្រង់នេះសិន។

[១៦:០០:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទ កិច្ចដំណើរការសវនាការថ្ងៃនេះ ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី០៤ ខែតុលា ឆ្នាំ២០១២ ចាប់ពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី មាស វឿន ដែលនឹងសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមភាគី និងសាធារណជនជ្រាប។

លោក មាស វឿន កិច្ចដំណើរការស្តាប់សក្ខីកម្មរបស់លោក នៅមិនទាន់ចប់នៅឡើយទេ សវនាការត្រូវបន្តធ្វើនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោក មកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមនៅវេលាម៉ោងប្រាំបួនព្រឹក ហើយមេធាវីប្រឹក្សាសាក្សី ក៏អញ្ជើញមកដូចគ្នានឹងសាក្សីដែរ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងជំនាញ ក្នុងការជូនសាក្សីរូបនេះ ត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។

[១៦:០១:៥៣]

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំង នៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនពួកគាត់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*